# ទស្សនាវដ្តី កសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ១២ ត្រីមាសទី ៣ (កក្កដា-កញ្ញា) ឆ្នាំ ២០១៣ លេខ ៤៧

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh





**សហការឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ**
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគម្រោងកម្មវិធីខ្សែចង្វាក់ផលិតកម្មតម្លៃកសិកម្ម កម្ពុជា **(CAVAC)**

# ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

# មាតិកា ទំព័រ

- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........................................................................................០១
- ព្រះរាជសារ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ** ផ្ញើជូន ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ......................០២
- លិខិតសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ................................................................................................................០៣
- លិខិតសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន H.E Jose Graziano da silva Director-General Food and Agricuture Organization..........០៤
- លិខិតសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធ្មារ **គង់ សំអុល** ផ្ញើជូនឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ............................................០៥
- ព្រះរាជសុន្ទរកថាព្រះករុណាព្រះបាទ**សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិ១ ឃុំអូរត្រេះស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ.........................................................................................................០៦
- សុន្ទរកថាឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស"ទិវាមច្ឆជាតិ"នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ...........................................................១០
- របាយការណ៍ថ្លែងដោយឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ "រុក្ខទិវា" នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ.........................................................................................................១៧
- របាយការណ៍ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធ "ទិវាមច្ឆជាតិ "នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ.........................................................................................................២២
- បច្ចេកទេសដាំដំណាំប៉េងប៉ោះ ម្ទេស និងត្រប់...................................................................២៧
- បច្ចេកទេសដាំដំណាំម្រះ ននោង ឃ្លោក និងត្រប់...............................................................៣០
- បច្ចេកទេសដាំដំណាំត្រសក់ស្រូវ....................................................................................៣៣
- បច្ចេកទេសដាំដំណាំពោត............................................................................................៣៦
- បច្ចេកទេសដាំដំណាំត្រសក់ផ្អែម....................................................................................៣៨
- បច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង....................................................................................៤១
- បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ (តពីលេខ៤៦)...................................................៤៣
- បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ (តពីលេខ៤៦)...................................................៥២
- សារាចរណែនាំស្តីពីវត្តមានសមាសភាពចង្រៃ និងវិធានការកម្ចាត់ក្នុងរដូវវស្សាឆ្នាំ២០១៣..........៥៩
- សេចក្តីថ្លែងការណ៍ដោយឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងវេទិការណ៍ពិសេសស្តីពីការទទួលស្គាល់នូវវឌ្ឍនភាពដ៏ប្រសើរក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី.....................៦១
- លិខិត WWF ផ្ញើជូនឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.........................................................................................................៦៧
- លក្ខណៈជីវសាស្ត្ររបស់បង្កងខ្លឹង.....................................................................................៦៨
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ...........................................៦៩

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **ចំន្ទ សារុន**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំ បានទទួលរួចហើយ នូវលិខិតរបស់ឯកឧត្តម ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ដែលបានថ្វាយសព្ទសាធុការពរចំពោះខ្ញុំ នៅក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនជន្មាយុខ្ញុំ ។

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ និងសូមជូនពរឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មន្ត្រីរាជការនិយោជិត កម្មករទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣

**សម្ដេចព្រះមហាក្សត្រ ព្រះវររាជបិតា**
**នរោត្ដម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្ដម ច័ន្ទ សារុន
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្ដម

ខ្ញុំបានទទួលនូវលិខិតថ្វាយពរដ៏ល្អប្រសើរ នៅក្នុងឱកាសពិធីបុណ្យចំរើនជន្មាយុខ្ញុំ ហើយសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះយុត្តិធម៌ដែលឯកឧត្ដមផ្ដល់ដល់ខ្ញុំ ក្នុងការបំរើប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា

ខ្ញុំសូមជូនពរឯកឧត្ដម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មន្ត្រីរាជការ និយោជិត និងកម្មករទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្ដម ទទួលនូវសេចក្ដីរាប់អាន អំពីខ្ញុំ។

ន មុនិនាថសីហនុ

**នរោត្ដម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ផ្ញើជូន
ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

*ឯកឧត្តមរដ្ឋមន្ត្រី ជាទីរាប់អាន !*

ខ្ញុំ និង ភរិយា បានទទួលរួចហើយ នូវលិខិតលេខ ២៦២៣ កសក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ដែលក្នុងនាម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឯកឧត្តម បានផ្តល់ជូន ខ្ញុំ និង ភរិយា នូវអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ សរុបចំនួន ១៥០ កន្លែង សម្រាប់ឆ្នាំសិក្សាថ្មី២០១៣-២០១៤ ខាងមុខនេះ។

សកម្មភាពសប្បុរសធម៌ដ៏ថ្លៃថ្លានេះ គឺបង្ហាញនូវការយកចិត្តទុកដាក់ ក្នុងការចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍធនធានមនុស្ស ពិសេសការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ ដែលគ្មានលទ្ធភាពបង់ថ្លៃសិក្សាឲ្យកូនចៅបន្តការសិក្សានៅកម្រិតឧត្តមសិក្សា។

ឆ្លៀតក្នុងឱកាសដ៏រីករាយនេះ ខ្ញុំ និង ភរិយា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និង សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ កើតមានដល់ ឯកឧត្តមរដ្ឋមន្ត្រី ក៏ដូចជា គណៈគ្រប់គ្រង បុគ្គលិក និង សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម និង សហការី ទទួលការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ និង ភរិយា។

រាជធានីភ្នំពេញ, ថ្ងៃទី៣១ខែ ៥ ឆ្នាំ២០១៣

ហ៊ុន សែន

Samdech Akka Moha Sena Padei Techo HUN SEN
Prime Minister of the Kingdom of Cambodia

*Phnom Penh, 05 June 2013*

***H.E. José Graziano da Silva***
***Director-General***
***Food and Agriculture Organization***

***Rome***

***Excellency,***

*I have the honour to acknowledge receipt with thanks of your letter dated 23 May 2013 inviting me to attend the special event to be held in Rome on Sunday, 16 June 2013 from 15:00 to 18:00 hours, during the 38th Session of the Food and Agriculture Organization Conference.*

*While expressing my sincere thanks for your kind invitation, I very much regret to inform you that due to my tight schedule, I will not be able to attend the above-said important event. However, I have designated His Excellency Chan Sarun, Minister of Agriculture, Forestry and Fisheries to represent me at this Conference.*

*May I wish the event a great success and fruitful results.*

*Please accept, **Your Excellency**, the assurances of my high consideration.*

***HUN SEN***

Kh 059 In/07.2013

**ព្រះរាជាណាចក្រកម្ពុជា**

**ROYAUME DU CAMBODGE**

**ព្រះបរមរាជវាំង**

លេខ : ៣៣១/១៣ វវ.សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣

**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

សូមជំរាបជូន

**ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឯកឧត្តម ជាទីរាប់អាន

ខ្ញុំមានកិត្តិយស សូមជំរាបជូនឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជ្រាបថា **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត **ព្រះអង្គ** សព្វព្រះរាជហឫទ័យប្រោស ព្រះរាជទានសេចក្តីថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តម ព្រមទាំងមន្ត្រីរាជការទាំងអស់ ដែលបានរៀបចំព្រះរាជដំណើរដ៏ខ្ពង់ខ្ពស់ ថ្វាយស្តេចយាងទតរោងម៉ាស៊ីនកិនស្រូវរបស់ក្រុមហ៊ុន **អង្គរកសិកម្មរុងរឿង. ចំការដូងប្រេង** និង **រោងចក្រកែច្នៃប្រេងដូង** របស់ក្រុមហ៊ុន **ម៉ុង ឫទ្ធី** និង ប្រារព្ធព្រះរាជពិធី**បុណ្យរុក្ខទិវា** នៅខេត្តព្រះសីហនុ នាថ្ងៃទី ០៨-០៩ ខែ កក្កដា ឆ្នាំ ២០១៣ នេះ បានល្អប្រសើរ ។

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត **ព្រះអង្គ** សព្វព្រះរាជហឫទ័យប្រទានពរ បវរមហាប្រសើរ ចំពោះ ឯកឧត្តម ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមបានប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាត ឡើយ ។

សូម ឯកឧត្តម មេត្តាទទួលនូវការរាប់អានដ៏ស្មោះ អំពីខ្ញុំ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវរ៉ា គង់ សំអុល**

# ព្រះរាជសុន្ទរកថា

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

(ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣)




*ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

- សូមក្រាបថ្វាយបង្គំព្រះមេគណ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី និងប្រិយមិត្តបរទេសទាំងអស់ជាទីមេត្រី
- ជនរួមជាតិ លោកតា លោកយាយ មាមីង បងប្អូន និង ក្មួយៗ ជាទីនឹករលឹក និងគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ជាបឋម នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកប្បការដោយបានមកចូលរួមប្រារព្ធពិធីបុណ្យរុក្ខទិវា ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ ត្រូវនឹងថ្ងៃ២កើត ខែអាសាឍ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧ នៅលើទឹកដីខេត្តព្រះសីហនុដែលជាទីក្រុងឆ្នេរដ៏ស្រស់បំព្រងរបស់ប្រទេសកម្ពុជា ព្រមទាំងមានឱកាសបានមកក្រាបថ្វាយបង្គំទូលសួរសុខទុក្ខព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខបងប្អូនជនរួមជាតិដែលបាននិមន្ត និងអញ្ជើញចូលរួមយ៉ាងកុះករក្នុងពិធីបុណ្យរុក្ខទិវាដ៏មានអត្ថន័យនាថ្ងៃនេះ។

ស្ថិតក្នុងបរិយាកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំសូមពាំនាំមកនូវព្រះរាជទានសេចក្តីនឹករលឹក និងព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ និងសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពីសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតមកប្រគេនព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូននិងក្មួយៗជាជនរួមជាតិទាំងអស់ដែលបាននិមន្ត និងអញ្ជើញមកចូលរួមក្នុងពិធីបុណ្យរុក្ខទិវាដ៏មហោឡារិកនេះ និងសូមប្រគេនពរបវរមហាប្រសើរថ្វាយចំពោះព្រះមេគណ ព្រះករុណាគ្រប់ព្រះអង្គនិងបងប្អូនជនរួមជាតិទាំងអស់ទោះនៅទីនេះក្តីក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលក្តី សូមបានប្រកបទៅដោយសេចក្តីសុខ សេចក្តីចម្រើន និងទទួលនូវសុភមង្គលគ្រប់ប្រការដើម្បីកសាងជីវភាពរស់នៅឱ្យបានរុងរឿងតរៀងទៅ។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅចំពោះព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមអរគុណចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត រដ្ឋទូត លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ដែលបានធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដល់ខ្ញុំព្រះករុណាខ្ញុំ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំ សូមកោតសរសើរចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងខេត្តព្រះសីហនុដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយ និងប្រាជ្ញាស្មារតីដើម្បីរៀបចំប្រារព្ធពិធីបុណ្យរុក្ខទិវាដ៏មានសារសំខាន់នេះនៅលើទឹកដីឆ្នេរសមុទ្រដ៏ស្រស់បំព្រងនៃភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្នុងគោលបំណងស្តារ និងបង្កើនធនធានព្រៃឈើឡើងវិញ សំដៅប្រែក្លាយតំបន់នេះឱ្យទៅជាតំបន់ដែលមានទេសភាពល្អស្អាតប្រកបដោយគម្របពណ៌បៃតងកាន់តែស្រស់ត្រកាលឡើងថែមទៀត និងរៀបចំរមណីយដ្ឋានដ៏មនោរម្យនេះដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ធម្មជាតិឱ្យមកកំសាន្តកាន់តែច្រើនឡើងថែមទៀត និងជាពិសេសរក្សាប្រភពពូជ

ភាពទឹកសាបសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋនៅក្នុងខេត្តព្រះសីហនុនេះផង។

ទន្ទឹមនឹងនេះដែរ ខ្ញុំព្រះករុណាខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ដែលបានថ្លែងនូវសុន្ទរកថាស្វាគមន៍មានអត្ថន័យដ៏ជ្រាលជ្រៅ និងខ្លឹមសារច្បាស់លាស់បង្ហាញនូវវឌ្ឍនភាពលើគ្រប់វិស័យ និងការអនុវត្តនូវរាល់ភារកិច្ចរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្តព្រះសីហនុបានធ្វើឱ្យទឹកដីឆ្នេរសមុទ្រធម្មជាតិដ៏ត្រកាលនេះមានភាពរីកចម្រើន មានសេចក្តីសុខស្និទ្ធភាពដែលសកម្មភាពទាំងនេះជាការរួមចំណែកមួយដ៏ល្អប្រពៃដើម្បីជួយលើកស្ទួយកម្រិតជីវភាពជូនបងប្អូនប្រជារាស្ត្រទូទៅឱ្យកាន់តែប្រសើរឡើងថែមទៀត ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញនូវការដឹកនាំប្រកបដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់សមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីរីករាយ និងមានចំណាប់អារម្មណ៍ចំពោះរបាយការណ៍ដ៏មានអត្ថន័យរបស់ឯកឧត្តម **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានលើកឡើងឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវសមិទ្ធផលជាច្រើន ដែលសម្រេចបានក្នុងវិស័យព្រៃឈើ និងការខិតខំយកចិត្តទុកដាក់ខ្ពស់បំពេញភារកិច្ចតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំដ៏ឆ្នើមបំផុត ជាពិសេសការអភិវឌ្ឍវិស័យកសិកម្ម ដែលរាជរដ្ឋាភិបាលបានចាត់ទុកថាជាវិស័យមួយមានអាទិភាពគ្រប់កាលៈទេសៈ ដែលស្របនឹងពាក្យដែលគេតែងតែនិយាយថាប្រទេសកម្ពុជា ជាប្រទេសកសិកម្ម តាំងពីយូរលង់ណាស់មកហើយដែលបច្ចុប្បន្ននេះ យើងបានកត់សម្គាល់ឃើញថា អត្រានៃភាពក្រីក្របានធ្លាក់ចុះពី២២,៩% ក្នុងឆ្នាំ២០០៩ មកនៅក្នុងរង្វង់២០%នៅឆ្នាំ២០១២ ហើយរំពឹងថា អត្រានៃភាពក្រីក្រនេះនឹងចុះមកនៅក្រោម១៩%នៅឆ្នាំ២០១៣។ ដោយឡែកថ្មីៗនេះ ប្រទេស៣៨ក្នុងចំណោម១៩៤ប្រទេស ហើយក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាមួយផងដែរបានទទួលដោយផ្ទាល់ពីអង្គការ FAO នូវប័ណ្ណទទួលស្គាល់សមិទ្ធផលប្រយុទ្ធនិងភាពអត់ឃ្លាននៃគោលដៅសហសវត្សគិតត្រឹមចុង



*ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងថ្លែងក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ឆ្នាំ២០១២នេះ ពោលគឺ៣ឆ្នាំមុនឆ្នាំគោលដៅ២០១៥ដែលព្រឹត្តិការណ៍នេះជាមោទនភាពមួយធំធេងណាស់សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

- ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិ ជាទីមេត្រី

យើងទាំងអស់គ្នាបានជ្រាបរួចហើយថា ពិធីបុណ្យរុក្ខទិវា ជាប្រពៃណីវប្បធម៌ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជាតិយើងតាំងពីសម័យសង្គមរាស្ត្រនិយមមកម្លេះ។ ទិវាដ៏ឧត្តុង្គឧត្តមនេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីលើកកម្ពស់ការដាំដើមឈើនៅព្រះរាជាណាចក្រកម្ពុជាយើងហើយដែលធនធានព្រៃឈើបានផ្តល់នូវពហុប្រយោជន៍មិនអាចប៉ាន់ប្រមាណបានដល់មនុស្សជាតិ ហើយព្រៃឈើមិនត្រឹមតែមានតម្លៃខាងសេដ្ឋកិច្ច និងសង្គមជាតិប៉ុណ្ណោះទេ ថែមទាំងបានជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ធ្វើឲ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើង រក្សានិយ័តភាពប្រភពទឹកការពារទីជម្រាល និងការពារជីវចម្រុះពោលគឺ ព្រៃឈើជាប្រភពមិនអាចខ្វះបានក្នុងការទាក់ទាញទឹកភ្លៀងឲ្យធ្លាក់មកលើភពផែនដី។ ក្រៅពីនេះព្រៃឈើមានតួនាទី ជួយទប់ស្កាត់ការហូរច្រោះដីហើយជួយសម្រួលឲ្យបរិមាណទឹកភ្លៀងយ៉ាងច្រើន ជ្រាបចូលជ្រៅទៅក្នុងស្រទាប់ដីបង្កបានជាខ្សែទឹកក្រោមដី ដែលប្រជាពលរដ្ឋយើងយកមកប្រើប្រាស់ប្រចាំថ្ងៃវិញតាមរយៈការជីកអណ្តូង



*មន្ត្រីរាជការអញ្ជើញចូលរួមក្នុងពិធីបុណ្យរុក្ខទិវាស្ថិត នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ជីកស្រះជាដើម។ លើសពីនេះទៅទៀតបរិមាណទឹកក្រោមដីដ៏ច្រើនសន្ធឹកសន្ធាប់នៅក្រោមព្រៃឈើក្នុងតំបន់ក្បាលឆាយយើងនេះបានបង្កជាសម្ពាធទឹកក្រោមដីខ្ពស់អាចទប់ទល់នឹងការជ្រាបចូលទឹកប្រៃនៃសមុទ្រមកក្នុងខ្សែទឹកក្រោមដីបានទៀតផង។ យ៉ាងណាមិញប្រសិនបើមានការជ្រាបចូលទឹកប្រៃមកក្នុងខ្សែទឹកក្រោមដីក្នុងតំបន់ខេត្តព្រះសីហនុនឹងបង្កជាបញ្ហាមួយដ៏គ្រោះថ្នាក់ដល់ការអភិវឌ្ឍ និងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ។ ដូច្នេះដើម្បីទប់ទល់នឹងទឹកប្រៃជ្រាបចូលមកក្នុងដីគោកនេះចាំបាច់យើងទាំងអស់គ្នា ត្រូវរួមគ្នាការពារឲ្យបាននូវព្រៃដែលនៅសេសសល់នេះនឹងខិតខំដាំដើមឈើរយៈពេលវែងបន្ថែមទៀតឲ្យបានច្រើនទៅក្នុងព្រៃ និងនៅលើដីដែលមិនទាន់មានគម្របរុក្ខជាតិធំៗគ្របដណ្តប់នៅឡើយឲ្យក្លាយទៅជាតំបន់មានគម្របពណ៌បៃតងធម្មជាតិដ៏ស្រស់បំព្រង។

សរុបមក ព្រៃឈើគឺជាប្រភពដង្ហើមរស់នៅលើភពផែនដី ជីវិតមនុស្ស និងសត្វលោកទូទៅ។ ការបាត់បង់នូវព្រៃឈើបានធ្វើឱ្យមានការកើនឡើងនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស និងធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ និងការឡើងកំដៅពិភពលោក ហើយបានជះឥទ្ធិពលអាក្រក់យ៉ាងច្រើនដល់ភពផែនដីយើងដូចជា ទឹកជំនន់ ការរាំងស្ងួតជាញឹកញាប់ ការផុតពូជនៃប្រភេទសត្វ និងរុក្ខជាតិមួយចំនួន និងការថយចុះនៃទិន្នផលកសិកម្មផងដែរ។ បញ្ហានេះបានក្លាយជាប្រធានបទមួយដ៏សំខាន់ដែលពិភពលោកកំពុងផ្តោតការយកចិត្តទុកដាក់សិក្សាស្វែងយល់ពីមូលហេតុ និងរិះរកគ្រប់មធ្យោបាយដើម្បីទប់ស្កាត់ និងលុបបំបាត់។ ជារួមព្រៃឈើគឺជាប្រភពផ្តល់នូវការរស់រានមានជីវិតដល់សត្តនិករទាំងឡាយនៅលើភពផែនដីយើងនេះ។ ដូចនេះព្រៃឈើមានអត្ថប្រយោជន៍ដ៏ជ្រាលជ្រៅមិនអាចខ្វះបានសម្រាប់យើងទាំងអស់គ្នាហើយដែលយើងទាំងអស់គ្នាត្រូវរួមចំណែកការពារ និងអភិរក្សព្រៃឈើ និងជីវចម្រុះដោយវៃឆ្លាត។

សូមបងប្អូនប្រជាពលរដ្ឋយើងទូទាំងប្រទេស មេត្តារួមគ្នាបន្តថែរក្សាការពារព្រៃឈើ និងដាំកូនឈើល្អៗគ្រប់ប្រភេទឲ្យកាន់តែសកម្មខ្លាំងក្លាថែមទៀតនៅលើដីទំនេរតាមទីអារាម ភូមិដ្ឋាន និងនៅទីកន្លែងផ្សេងៗទៀតឲ្យបានច្រើនជាអតិបរមារួមទាំងការដាំដុះដំណាំផ្សេងៗ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម សិប្បកម្មផ្សេងៗ។ល។ ដើម្បីអភិវឌ្ឍមាតុភូមិយើង និងធ្វើឱ្យបរិយាកាសកាន់តែល្អប្រសើរឡើង។ ជាមួយគ្នានេះយើងទាំងអស់គ្នាត្រូវដាំឈើដើម្បីកែលម្អដីបង្កើតធនធានឈើសម្រាប់ប្រើប្រាស់ថែរក្សា និងបង្កើនគម្របព្រៃឈើ ព្រមទាំងជួយសម្អាតភាពកខ្វក់ក្នុងបរិយាកាសព្រមទាំងត្រូវរួមគ្នាចូលរួមចំណែកបន្សាំ និងកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់សេវាកម្មមានគុណភាព កាន់តែខ្ពស់ដែលនាំដល់ការបង្កើនសមត្ថភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើវិធានការសមស្រប និងមានប្រសិទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងគ្រប់គ្រងធនធានធម្មជាតិព្រៃឈើ និងជលផលប្រកបដោយចីរភាព។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់គ្រប់ដៃគូពាក់ព័ន្ធទាំងអស់ មេត្តាចូលរួមវិភាគទានដោយផ្ទាល់ ដើម្បីជួយលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ព្រៃឈើមូលដ្ឋានទាំងឡាយឱ្យមានភាពម្ចាស់ការចូលរួមគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍព្រៃឈើឱ្យមាននិរន្តរភាពតាមរយៈការទទួលផលប្រយោជន៍ប្រកបដោយសមធម៌ និងធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើងដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ ដោយបង្វែរជីវភាពរស់នៅពីការពឹងអាស្រ័យលើផល អនុផលព្រៃឈើ មកធ្វើកសិកម្មចម្រុះវិញ។ និយាយរួមធនធានព្រៃឈើបានផ្តល់នូវពហុ-ប្រយោជន៍មិនអាចប៉ាន់ប្រមាណបានដល់មនុស្សជាតិតាំងពីដើមរៀងរហូតមក ពីព្រោះថា ព្រៃឈើជាសរសៃឈាមក្នុងវិស័យកសិកម្ម ជាអាយុជីវិតរបស់ប្រជាកសិករនិងជាប្រភពនៃកំណើនសេដ្ឋកិច្ចជាតិ ដូច្នេះយើងត្រូវតែរួមគ្នាថែរក្សាការពារព្រៃឈើ ដាំដើមឈើឱ្យបាន








*ព្រះរាជសកម្មភាពព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ* ***នរោត្ដម សីហមុនី*** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

គ្រប់ៗគ្នានិងរួមគ្នាទប់ស្កាត់នូវរាល់បទល្មើសព្រៃឈើនិងការកាប់រានព្រៃឈើ ព្រៃលិចទឹក យកដីល្មើសច្បាប់តាមគ្រប់រូបភាព។

នៅក្នុងបរិយាកាសដ៏រីករាយនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវចំពោះព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ក្រសួង- ស្ថាប័ននានា អាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ គ្រប់គ្រឹះស្ថានសិក្សា ទីវត្តអារាមទាំងអស់ និងបងប្អូនជនរួមជាតិទូទាំងប្រទេសសូមព្រះមេត្តា និងមេត្តារួមគ្នាបន្តថែរក្សា និងការពារព្រៃឈើសម្រាប់មនុស្សជាតិជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថារដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំបណ្ដុះកូនឈើគ្រប់ប្រភេទ ឱ្យបានច្រើនថែមទៀតនៅគ្រប់ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីចែកជូនជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងតម្រូវការផ្សេងៗ។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវចំពោះសហគមន៍អ្នកផ្ដល់ជំនួយជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍរបស់កម្ពុជាទាំងអស់ សូមបន្តជួយឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដល់សកម្មភាពកែទម្រង់វិស័យព្រៃឈើដ៏ត្រឹមត្រូវ និងល្អប្រពៃរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីការពារព្រៃឈើរបស់យើងសម្រាប់កូនចៅជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀតឱ្យស្ថិតស្ថេរចីរកាលតរៀងទៅ។

ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសឱ្យពិធី បុណ្យរុក្ខទិវា នេះជាបេសកកម្មប្រវត្តិសាស្ត្រស្ថិតនៅជាអចិន្ត្រៃយ៍របស់មនុស្សជាតិព្រោះថាយើងទាំងអស់គ្នាចូលរួមដាំដើមឈើ ហើយដើមឈើនឹងជួយទ្រទ្រង់ជីវិតយើង និងភពផែនដីយើងឱ្យរួចផុតពីគ្រោះថ្នាក់គ្រោះមហន្តរាយធម្មជាតិនានាដែលអាចនឹងកើតឡើងជាយថាហេតុនាអនាគតកាល។

ជាអវសាន ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះព្រះវត្តមាន និងវត្តមានក្នុងព្រះរាជពិធីបុណ្យដ៏ថ្លៃថ្លានេះ និងសូមប្រគេនពរព្រះមេត្តា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការនៃក្រសួង-ស្ថាប័នទាំងអស់ ព្រមទាំងសូមជូនពរប្រិយមិត្តបរទេស លោកតា លោកយាយ មាមីង បងប្អូន ជនរួមជាតិ និងក្មួយៗសិស្សានុសិស្សទាំងអស់សូមបានប្រកបតែនឹងសុភមង្គល និងការរីកចម្រើន ព្រមទាំងទទួលនូវព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃៀងឃ្លាតឡើយ។

***សូមអរព្រះគុណ និង សូមអរគុណ!***

# សុន្ទរកថា

## របស់ឯកឧត្ដម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស “ទិវាមច្ឆជាតិ “ នៅអាងទឹក ១មករា ភូមិតាគោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ

ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៣




*ឯកឧត្ដម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាគោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

- សូមក្រាបថ្វាយបង្គំ ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្ដម លោកជំទាវ សមាជិកសមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល
- ឯកឧត្ដម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ
- បងប្អូន ជនរួមជាតិ លោកតា លោកយាយ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីនឹករលឹក!

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវសេចក្ដីសោមនស្សរីករាយ ជាអនេកប្បការ ដោយបានមកចូលរួមក្នុង “ ទិវាមច្ឆជាតិ ” លើកទី១១ នេះ និងមានឱកាសបានមកថ្វាយបង្គំទូលសួរសុខទុក្ខ ព្រះតេជព្រះគុណ ព្រះមេគណ ព្រះគ្រូចៅអធិការ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខបងប្អូនជនរួមជាតិទាំងអស់ដែលបាននិមន្ត និងអញ្ជើញមកចូលរួមយ៉ាងច្រើនកុះករក្នុងទិវាដ៏នក្ខត្តឫក្សនាថ្ងៃនេះ។ ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ ឯកឧត្ដម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល ឯកឧត្ដម លោកជំទាវឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រិយមិត្តបរទេស លោក លោកស្រី មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកតា លោកយាយ បងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សទាំងអស់ដែលបានធ្វើបដិសណ្ឋារកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅបំផុតដល់ខ្ញុំព្រះករុណាខ្ញុំ នាពេលនេះ។

ក្នុងឱកាសដ៏ប្រពៃណីនេះ ខ្ញុំព្រះករុណាខ្ញុំ សូមពិតពុទ្ធដីកា និងជម្រាបជូនថា ការប្រារព្ធ ទិវាមច្ឆជាតិលើកទី១១ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣នៅអាងទឹក ១មករានេះ ពិតជាមានអត្ថន័យយ៉ាងជ្រាលជ្រៅ ហើយដែលពិធីនេះប្រព្រឹត្តទៅចំថ្ងៃប្រកាសបិទនេសាទទូទាំងប្រទេស(លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ) ដើម្បីបង្កលក្ខណៈឱ្យហ្វូងមច្ឆជាតិទាំងឡាយ ជាពិសេសពពួកមេត្រីមានលទ្ធភាពពងកូនបន្តពូជពង្សទុកសម្រាប់ឆ្នាំក្រោយៗបន្តទៅទៀត នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។

ម្យ៉ាងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវការកោតសរសើរចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំ មន្ត្រីរាជការរដ្ឋបាលជលផលគ្រប់ជាន់ថ្នាក់ដែលបានរៀបចំ ទិវាមច្ឆជាតិ ជារៀងរាល់ឆ្នាំ



*ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ថ្លែងក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាកោត ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ដែលមានអត្ថន័យយ៉ាងក្រៃលែង។ ដូចក្នុងរបាយការណ៍របស់ឯកឧត្តម **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិតពុទ្ធដីកា និងជម្រាបជូនរួចហើយថា ទិវាមច្ឆជាតិនេះ ពិតជាមានអត្ថន័យទូលំទូលាយគួរឲ្យចាប់អារម្មណ៍ ជាពិសេស ក្នុងន័យបំផុសមហាជនឱ្យមានស្មារតីចូលរួមការពារ អភិរក្ស និងអភិវឌ្ឍធនធានជលផលឱ្យបានយល់ជ្រួតជ្រាបដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋ មន្ត្រីរាជការ ស្ថាប័នរដ្ឋ និងឯកជន ជាពិសេសកូនចៅជំនាន់ក្រោយ សំដៅធានាដល់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាពតាមយុទ្ធសាស្ត្រកំណែទម្រង់វិស័យជលផលដ៏ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា នាសម័យកាលនេះ។

- ព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ បងប្អូនជនរួមជាតិជាទីស្នេហា!

បច្ចុប្បន្ននេះ វិស័យកសិកម្មនៅតែបន្តតួនាទីដ៏សំខាន់ក្នុងការជំរុញកំណើនផលិតកម្មក្នុងស្រុក ការបង្កើតការងារ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ដោយឡែកវិស័យកសិកម្មក៏នឹងបន្តតួនាទីជាមូលដ្ឋានដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍សង្គមកម្ពុជាក្នុងទសវត្សរ៍ខាងមុខ ទោះជាកម្ពុជាបានធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន រួមទាំងឧស្សាហូបនីយកម្មផងនោះ។ ជាក់ស្តែងវិស័យកសិកម្មមិនត្រឹមតែធានាបាននូវសន្តិសុខស្បៀងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចជាតិទៀតផង។ ក្នុងន័យនេះ បើយើងពិនិត្យមើលផលនៃសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១២កន្លងទៅនេះ កម្ពុជាសម្រេចបានកំណើនប្រមាណ៧,៣% ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ៗបានកើនឡើងពី៧៦០ដុល្លារនៅក្នុងឆ្នាំ២០០៨ ដល់ប្រមាណ១.០០០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ ហើយយើងរំពឹងថានៅក្នុងឆ្នាំ២០១៣នេះនឹងអាចឡើងដល់ជាង១.០០០ដុល្លារអាមេរិក។ លទ្ធផលនេះជាសំខាន់គឺបានមកពីកំណើនប្រចាំឆ្នាំនៃវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ជាការកត់សម្គាល់ការនាំចេញផលិតផលកសិកម្ម ជាពិសេសការនាំចេញអង្ករនិងកសិផលសំខាន់ៗផ្សេងទៀតក៏បានកើនឡើងផងដែរ។ ដូច្នេះការរីកលូតលាស់នៃវិស័យកសិកម្ម គឺមិនត្រឹមតែធ្វើឱ្យសេដ្ឋកិច្ចរបស់យើងកើនឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងប្រែក្លាយតំបន់ដីស្ងួតក្រៀមឱ្យក្លាយទៅជាតំបន់មានពណ៌បៃតងគ្រប់រដូវកាលនិងអនុញ្ញាតឱ្យយុវជននៅជនបទមានការងារធ្វើ កាត់បន្ថយចំណាកស្រុកនិងលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួនទៀតផង។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់**តេជោសែន** បានធ្វើឱ្យអត្រានៃភាពក្រីក្រធ្លាក់ចុះជាបន្តបន្ទាប់ តាំងពីប្រជាជនមានតែបាតដៃទទេនៅឆ្នាំ១៩៧៩មក ហើយថ្មីៗនេះ អត្រានៃភាពក្រីក្របានធ្លាក់ចុះពី២២,៩%ក្នុងឆ្នាំ២០០៩ មកនៅក្នុងរង្វង់២០% នៅឆ្នាំ២០១២ ហើយយើងរំពឹងថា អត្រានៃភាពក្រីក្រនេះនឹងចុះមកនៅក្រោម១៩% នៅឆ្នាំ២០១៣នេះ។ បន្ថែមលើនេះ កម្ពុជាត្រូវបានវាយតម្លៃថាបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី១ លើផ្នែកកង្វះអាហារូបត្ថម្ភដែលអត្រាប្រេវ៉ាឡង់បានថយចុះពី៣៩,៩ភាគរយនៅក្នុងចន្លោះឆ្នាំ១៩៩០-៩២ មកត្រឹមតែ១៧,១ភាគរយក្នុងចន្លោះឆ្នាំ២០១០-២០១២។ តទៅអនាគតយើងនឹងខិតខំប្រឹងប្រែងទាញទម្លាក់អត្រានៃភាពក្រីក្រនេះឱ្យកាន់តែទាបទៅៗ រហូតដល់ការលុបបំបាត់ចោលនូវភាពក្រីក្រនេះតាមរយៈការបន្តអភិវឌ្ឍន៍វិស័យកសិកម្មនេះផង និងការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជាផង។ នៅក្នុងចំណុចនេះខ្ញុំសូមបញ្ជាក់ម្តងទៀតថា ទោះ

បើវិស័យកសិកម្មកម្ពុជារីកចម្រើនខ្លាំងយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលដែលមានតេជោសែនជានាយករដ្ឋមន្ត្រី នោះគឺមិនអនុវត្តការយកពន្ធលើដីធ្លីកសិកម្មនោះឡើយ។

ដោយឡែកបើយើងក្រឡេកមើលអំពីកិច្ចការកំណែទម្រង់ក៏ដូចជាការអភិវឌ្ឍន៍ក្នុងវិស័យជលផលបានបង្ហាញឱ្យឃើញថា វិស័យនេះបានចូលរួមចំណែកដ៏សំខាន់នៅក្នុងផលទុនជាតិសរុបក្នុងស្រុកហើយក៏ជាបណ្ដាញមួយនៃសុវត្ថិភាពសង្គមដែលមនុស្សប្រមាណជាង៦លាននាក់មានមុខរបរពាក់ព័ន្ធនឹងវិស័យជលផលត្រូវបានធានាសុវត្ថិភាព។ ជាពិសេស វិស័យជលផលបានចូលរួមចំណែកក្នុងការផ្គត់ផ្គង់ស្បៀងអាហារ និងផ្ដល់ការងារជាច្រើនដល់ប្រជាពលរដ្ឋផងដែរ។ លើសពីនេះទៀត ក្រៅពីបម្រើសេចក្ដីត្រូវការ ផ្នែកម្ហូបអាហារក្នុងស្រុក ប្រទេសកម្ពុជាក៏បាននាំចេញផលិតផលជលផលទៅប្ដូរយករូបិយប័ណ្ណបរទេស ហើយសព្វថ្ងៃនេះប្រទេសយើងក៏នៅតែនាំចេញផលនេសាទមួយចំនួនជាបន្តបន្ទាប់ផងដែរ។ តាមការពិត រាជរដ្ឋាភិបាលបានចាត់ទុកថា វិស័យកសិកម្ម គឺជាវិស័យអាទិភាពមួយនៅគ្រប់កាលៈទេសៈ សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជាទាំងមូល ដែលក្នុងនោះវិស័យជលផលក៏បានស្ថិតនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលផងដែរ។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមបញ្ជាក់ផងដែរថា ព្រះរាជាណាចក្រកម្ពុជាយើងមានមរតកធម្មជាតិដ៏សម្បូរបែបតាំងពីបុរាណកាលមកម្លេះ ដូចជា បឹងទន្លេសាប និងប្រព័ន្ធទន្លេ បឹងបួរ ស្ទឹងជាច្រើន និងទំនាបវាលស្រែដែលអាចផ្ដល់បរិមាណត្រីដ៏ច្រើនក្រៃលែងដល់ប្រជាជនយើង លើសពីនេះទៀត យើងក៏សម្បូរទៅដោយត្រីសមុទ្រស្ថិតក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានព្រៃភក់ តំបន់ដីសើម ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាងជាច្រើនកន្លែងទៀត ដែលជាជម្រកមច្ឆជាតិ និងវារីសត្វសមុទ្រពងកូន និងរីកលូតលាស់ធំធាត់។ ហេតុនេះហើយ ទើបគេអាចចាត់ទុកថា ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាយើងជាសង្គមបរិភោគត្រីយ៉ាងច្រើន បើប្រៀបធៀបជាមួយ បណ្ដាប្រទេសនានា លើសកលលោក។ ម្យ៉ាងទៀត យើងក៏អាចចាត់ទុកថាត្រីនិងវារីសត្វផ្សេងៗទៀត ជាអាហារយ៉ាងសំខាន់ក្នុងរបបអាហារប្រចាំថ្ងៃ





*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួម ក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាកោត ឃុំបល្ល័ង្ក ស្រុក បារាយណ៍ ខេត្តកំពង់ធំ*

របស់ប្រជាពលរដ្ឋខ្មែរ បន្ទាប់ពីស្រូវ-អង្ករ ពោលគឺត្រីជាទំនិញ ដែលពាក់ព័ន្ធដល់ជីវភាពប្រចាំថ្ងៃ ជាប្រពៃណីរបស់ប្រជាពលរដ្ឋយើងដែលមិនអាចខ្វះបានតាំងពីយូរលង់ណាស់មកហើយ។

- អង្គពិធីទាំងមូលជាទីមេត្រី

នាបច្ចុប្បន្ននេះ យើងទាំងអស់គ្នាបានសង្កេតឃើញថា បញ្ហានៃការប្រែប្រួលអាកាសធាតុដែលចេះតែកើតមានកាន់តែធ្ងន់ធ្ងរទៅៗនៅលើពិភពលោក បានជះឥទ្ធិពលដល់ប្រជាជនក្រីក្រនៅក្នុងសង្គមរបស់យើង ប្រសិនបើយើងប្រើប្រាស់ធនធានធម្មជាតិយើងមិនមាននិរន្តរភាព នោះយើងនឹងជួបប្រទះនូវការខ្វះខាតយ៉ាងធ្ងន់ធ្ងរនាពេលអនាគត ពីព្រោះជីវិត និងរបរចិញ្ចឹមជីវិតរបស់ប្រជាជនទាំងនោះពិតជាពឹងផ្អែកទាំងស្រុងទៅលើទឹក ដី សមុទ្រ ព្រៃឈើ និងធនធានដ៏សម្បូរបែបនេះ។ ទោះជាយ៉ាងណាក្ដី រាជរដ្ឋាភិបាលក៏មិនបានព្រងើយកន្តើយដែរដោយបានប្ដេជ្ញាចិត្តលើកកម្ពស់សេដ្ឋកិច្ចបៃតងដើម្បីឲ្យសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍



*ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ថ្លែងក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាគោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

កម្ពុជា ២០១៥ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ រួមជាមួយផែនទីចង្អុលផ្លូវយ៉ាងច្បាស់លាស់ សម្រាប់ការអភិវឌ្ឍបៃតងជាតិ។ ជាក់ស្តែងនៅចំពោះមុខ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញមានភ្លៀងធ្លាក់ខុសពីធម្មតា ខ្យល់ព្យុះ ផ្គររន្ទះ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាច្រើនករណី ដែលបានបំផ្លិញបំផ្លាញផលដំណាំ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋអស់យ៉ាងច្រើនសន្ធឹកសន្ធាប់។ ប្រការដែលមិនអាចជឿបាន ប៉ុន្តែបានកើតមានរួចហើយនោះ គឺយើងទាំងអស់គ្នាតែងកត់សម្គាល់ឃើញថា ឆ្នាំរាំងទឹកធំ តែនៅឆ្នាំកន្លងមកនេះ បែរជាទឹកតូចខុសធម្មតា ដែលធ្វើឱ្យយើងលើកគម្រោងខុសទាំងការដាំដុះស្រូវ និងដំណាំផ្សេងៗ ក៏ដូចជាការចិញ្ចឹមត្រីផងដែរ។ ជាការពិត ប្រជាពលរដ្ឋជនបទភាគច្រើនបានប្រើប្រាស់នូវធនធានធម្មជាតិ ដើម្បីបម្រើជីវភាពប្រចាំថ្ងៃរបស់ខ្លួនតាមតម្រូវការចាំបាច់ ដោយមិនបានគិតគូរដល់និរន្តរភាពឡើយ ដែលជាហេតុបណ្តាលឱ្យមានការបាត់បង់ និងរេចរឹលធនធានធម្មជាតិ និងខូចបរិស្ថានជលផលផងដែរ។ ទន្ទឹមនឹងនេះដែរ កំណើនប្រជាពលរដ្ឋក៏ដូចជាកំណើនប្រជានេសាទដែលរស់នៅជុំវិញបឹងទន្លេសាបក៏មានការកើនឡើងយ៉ាងឆាប់រហ័សបានដាក់សម្ពាធយ៉ាងធ្ងន់បន្ថែមទៀត ធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ធនធានជលផល និងធនធានធម្មជាតិផ្សេងៗទៀត ដែលស្ថិតនៅតែជាឧបសគ្គចម្បងនៅក្នុងការធ្វើឱ្យបានសម្រេចតាមផែនការប្រើប្រាស់ និងអភិវឌ្ឍធនធានជលផល និងធនធានធម្មជាតិដទៃទៀតប្រកបដោយចីរភាព។ ដោយហេតុនេះហើយ ទើបកន្លងមកថ្មីៗនេះរាជរដ្ឋាភិបាលបានរៀបចំកម្មវិធីកំណែទម្រង់គោលនយោបាយវិស័យជលផលដ៏ស៊ីជម្រៅមួយជាប្រវត្តិសាស្ត្រ ដោយបានលុបឡូត៍នេសាទទាំងអស់ ហើយបានប្រគល់សិទ្ធិអំណាចទៅឱ្យសហគមន៍គ្រប់គ្រង និងប្រើប្រាស់ធនធានដោយផ្ទាល់នោះ បានធ្វើឱ្យប្រជាកសិករអាចមានលទ្ធភាពចូលរួមបានយ៉ាងសកម្មនៅក្នុងការសម្រេចចិត្ត និងរៀបចំផែនការ និងកម្មវិធីអភិវឌ្ឍន៍នានារបស់មូលដ្ឋានរៀងៗខ្លួន ហើយរួមចំណែកទទួលខុសត្រូវ និងធ្វើជាម្ចាស់លើការគ្រប់គ្រងធនធានធម្មជាតិដោយខ្លួនឯង។ ជាក់ស្តែង រហូតមកដល់ពេលនេះយើងបានរៀបចំបង្កើតសហគមន៍នេសាទចំនួនសរុប ៥១៦ សហគមន៍ ជាមួយគ្នានេះដែរយើងក៏បានរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន ៧៦៥ កន្លែងថែមទៀត ព្រមទាំងបានលើកកម្ពស់លទ្ធភាពប្រើប្រាស់ធនធានជលផលដ៏មានសារសំខាន់នេះ សម្រាប់ប្រជាជនក្រីក្រដោយផ្ទាល់តែម្តង ហើយសម្រេចបាននូវសកម្មភាពផ្សេងៗជាច្រើនទៀតគួរឲ្យកត់សម្គាល់ ដូចក្នុងរបាយការណ៍លម្អិតរបស់ឯកឧត្តមរដ្ឋមន្ត្រី ច័ន្ទ សារុន ជម្រាបជូនអម្បាញ់មិញនេះ។ តាមរយៈការបង្កើត និងលើកកម្ពស់គុណភាពនៃសហគមន៍នេសាទនេះ បានធ្វើឱ្យធនធានជលផល ត្រូវបានកែលម្អឡើងវិញមួយកម្រិតទៀត។ នេះគឺជាចំណុចសំខាន់ដែលបញ្ជាក់យ៉ាងច្បាស់ថា ការចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍មូលដ្ឋាន តាមបែបវិមជ្ឈការគឺមានប្រសិទ្ធភាពយ៉ាងពិតប្រាកដ ហើយអាចចាត់ទុកជាសមិទ្ធផលដែលសម្រេចបានយ៉ាងជោគជ័យពីគោលនយោបាយកែទម្រង់វិស័យជលផលដ៏ស៊ីជម្រៅនេះ ក៏ដូចជា ការអនុវត្តទៅតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលផងដែរ។ ជាការពិតណាស់ នេះគឺជាកំណែទម្រង់មួយដ៏សំខាន់ បន្ទាប់ពីកំណែទម្រង់លើកទី១ ដែលរាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយផ្ទៃឡូត៍នេសាទជាងកន្លះលានហិកតា នៅកំឡុងចុងឆ្នាំ២០០០ មក។យើងក៏ត្រូវដឹងដែរថា នៅពេលដែលសហគមន៍

នេសាទបានទទួលសិទ្ធិប្រើប្រាស់ធនធានទាំងនោះ ពួកគាត់ក៏នៅតែត្រូវការជំនួយបច្ចេកទេស សម្រាប់ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍ ដើម្បីធានាបាននូវការប្រើប្រាស់ធនធានទាំងនោះ ប្រកបដោយចីរភាព ហើយជួយបង្កើនជីវភាពរស់នៅរបស់សហគមន៍ឱ្យកាន់តែសំបូរធូរធារ និងកាត់បន្ថយការដាក់សម្ពាធទៅលើការប្រើប្រាស់ធនធានធម្មជាតិបានមួយកម្រិតថែមទៀតផងដែរ។ ជារួមសកម្មភាពទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងយ៉ាងធំធេងរបស់រាជរដ្ឋាភិបាល នៅក្នុងនយោបាយកាត់បន្ថយភាពក្រីក្រ ដើម្បីជំរុញការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនិងការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ តាមរយៈការពង្រឹងការគ្រប់គ្រងធនធានជលផលដោយផ្អែកលើសហគមន៍។

- ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិជាទីមេត្រី !

ឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះរដ្ឋបាលជលផល ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន អង្គការជាតិ-អន្តរជាតិ ដែគូពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមទប់ស្កាត់បទល្មើសនេសាទ ការដាំព្រៃលិចទឹក ការអភិរក្សធនធានធម្មជាតិ ក៏ដូចជាកិច្ចសហការក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដល់គណៈកម្មការសហគមន៍នេសាទទូទាំងប្រទេស ស្តីពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងការគ្រប់គ្រង សហគមន៍នេសាទជាដើម។ ខ្ញុំព្រះករុណាខ្ញុំមានចំណាប់អារម្មណ៍ជាពិសេសចំពោះការចាត់វិធានការយាម ការពារកន្លែងអភិរក្សជលផលដែលខ្ញុំបានប្រគល់ភារកិច្ចជូនក្នុងការរៀបចំផ្ទះផែសាឡាង ឬកាណូត និងកងកម្លាំងយាមកាមកន្លែងអភិរក្សទាំងអស់បានលទ្ធផលល្អ ដោយសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងសហគមន៍នៅមូលដ្ឋាន ដែលសង្ឃឹមថា ត្រីមេពូជទាំងនេះកំពុងពងកូនបន្តពូជធ្វើឱ្យសម្បូរផលត្រីទៅឆ្នាំក្រោយទៀត។ ម៉្យាងវិញ



*ទិដ្ឋភាពរួម ក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ទៀតដើម្បីសម្រេចនូវគោលដៅខាងលើនេះ គឺយើងពិតជាមិនអាចកាត់ផ្តាច់ ការគាំទ្រពីគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ខាងលើនេះបានឡើយ។នៅក្នុងឱកាសប្រារព្ធ ទិវាមច្ឆជាតិ លើកទី១១ ថ្ងៃទី១ ខែកក្កដា នៅអាងទឹក១មករា នៅក្នុងខេត្តកំពង់ធំដ៏មានអត្ថន័យនេះ និងបន្ថែមពីលើអនុសាសន៍ទាំងឡាយដែលខ្ញុំព្រះករុណាខ្ញុំតែងបានផ្តល់ជាបន្តបន្ទាប់មកនោះ ជាពិសេស អនុសាសន៍ដ៏មានតម្លៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបានលើកឡើងក្នុងឱកាសបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ កន្លងមកនេះ ខ្ញុំព្រះករុណាខ្ញុំ សូមផ្តល់នូវអនុសាសន៍បន្ថែមទៀត សម្រាប់យកទៅអនុវត្តនាពេលខាងមុខដូចតទៅ៖

ទី១- រដ្ឋបាលជលផលត្រូវបន្តការងារបង្ក្រាបបទល្មើសនេសាទឱ្យមានប្រសិទ្ធភាពថែមទៀតដោយសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក៏ដូចជាស្ថាប័នពាក់ព័ន្ធបន្តកិច្ចការការពារ អភិរក្សធនធានជលផលឱ្យបានល្អប្រសើរក្នុងស្មារតីទទួលខុសត្រូវសាមគ្គីភាព និងរាយការណ៍ឱ្យបានទាន់ពេលវេលា។

ទី២- ត្រូវបំផុសការអភិវឌ្ឍវារីវប្បកម្ម ដោយត្រូវជំរុញការបង្កាត់ត្រីនៅតាមអាងបង្កាត់-ភ្ញាស់នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។ ម៉្យាងទៀតត្រូវលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុង និងក្រៅប្រទេសឲ្យវិនិយោគលើការងារចិញ្ចឹមត្រី និងបង្កង ការកែច្នៃផលិតផលជលផល ជាពិសេសចិញ្ចឹមប្រភេទត្រី









*សកម្មភាពក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ក្នុងស្រុក ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដើម្បីបម្រើទីផ្សារ និងការនាំចេញ បង្កើនប្រាក់ចំណូល ជួយកាត់បន្ថយការធ្វើនេសាទត្រីក្នុងដែនទឹកធម្មជាតិ និងជំរុញផ្សព្វផ្សាយសកម្មភាពវារីវប្បកម្មឲ្យកាន់តែរីកចម្រើនថែមទៀត ជាពិសេសត្រូវយកចិត្តទុកដាក់បំផុតចំពោះខេត្តដែលខ្សត់ទឹក និងខ្សត់ត្រី។

ទី៣- រដ្ឋបាលជលផល ត្រូវពង្រីកសកម្មភាពលែងកូនបង្កងទៅក្នុងទំនាបលិចទឹកឲ្យបានច្រើនលានក្បាលថែមទៀត ដើម្បីឲ្យប្រទេសយើងសម្បូរបង្កងនៅគ្រប់ទីកន្លែង។ បន្ថែមលើនេះទៀតត្រូវខិតខំពង្រឹងសមត្ថភាពសហគមន៍នេសាទ ដែលបានបង្កើតឡើងរួចហើយ ឱ្យបានរឹងមាំ ដើម្បីក្លាយជាសហគមន៍នេសាទ ដែលគ្មានបទល្មើសជលផលព្រមទាំងត្រូវជំរុញការចិញ្ចឹមត្រីក្នុងស្រះ បៃ និងក្នុងស្រែ និងខិតខំបង្កើតស្រះ ជម្រកត្រីសហគមន៍ឱ្យបានគ្រប់ឃុំនៅទូទាំងប្រទេស។ ក្រៅពីនេះ ក៏ត្រូវជំរុញបន្ថែម ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទឱ្យងាកមកការធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនត្រូវពឹងអាស្រ័យតែលើធនធានជលផលមួយមុខនោះឡើយ។ រីឯការបញ្ជ្រាបចំណេះដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដល់ប្រជាពលរដ្ឋនោះ គឺជាភារកិច្ចមួយបន្ថែមទៀតរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមទៀតដែលត្រូវតែចូលរួមនិងមិនអាចមើលរំលងកិច្ចការនេះបានឡើយ។

ទី៤- ត្រូវបន្តបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស និងកន្លែងនេសាទគ្រួសារឲ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងធ្វើសកម្មភាពគ្រប់គ្រងកន្លែងអភិរក្សជលផល ប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្ដល់ថវិកាសម្រាប់ការបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

ទី៥- ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរដែនដីមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ជាពិសេសថ្នាក់ស្រុក ឃុំ ភូមិ ដែល

មានព្រៃលិចទឹក នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសនៅជុំវិញបឹងទន្លេសាបត្រូវបញ្ឈប់ការអនុញ្ញាតឲ្យធ្វើទំនប់អាងទឹក ដោយគ្មានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទន្ទឹមនឹងនេះ រដ្ឋបាលជលផលត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់បំផុតបន្ថែមទៀត ចំពោះជនល្មើសបំផ្លាញព្រៃលិចទឹកនៅគ្រប់ទីកន្លែង និងការពារព្រៃលិចទឹកឲ្យបានគង់វង្ស ពីព្រោះព្រៃលិចទឹកមានសារសំខាន់បំផុតដល់អាយុជីវិតនៃវិស័យជលផលទាំងមូល។

- អង្គពិធីទាំងមូលជាទីមេត្រី

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលទាំងឡាយដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារដ្ឋបាលជលផលសម្រេចបានថ្មីៗទៀតក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ និងសូមបន្តនូវប្រពៃណីនៃកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធថែមទៀត ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិនានា ក៏ដូចជាបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផងដែរ។ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថា តំបន់នេះពិតជានឹងក្លាយជាតំបន់សម្បូរធនធានមច្ឆជាតិដ៏សម្បូរបែប បន្ទាប់ពីបានប្រារព្ធពិធីដ៏មានអត្ថន័យនាថ្ងៃនេះ។

ឆ្លៀតក្នុងឱកាសដ៏មានសារសំខាន់នេះ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំសូមពិតពុទ្ធដីកា និងជម្រាបជូនថា សម្តេចតេជោ នាយករដ្ឋមន្ត្រីតែងតែមានមនោសញ្ចេតនា ផ្សារភ្ជាប់ជាមួយប្រជាកសិករ និងវិស័យកសិកម្មគ្រប់កាលៈទេសៈ គួបផ្សំនឹងការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ ផ្នែកឯកជន និងពីគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ទាំងអង្គការជាតិ អន្តរជាតិនានាដែលកំពុងកៀកស្មាសហការយ៉ាងស្វាហាប់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេចឱ្យបាននូវទិសដៅដែលរាជរដ្ឋាភិបាលបានដាក់ចុះ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់មន្ត្រីអ្នករាជការគ្រប់ជាន់



*កូនត្រីពូជត្រៀមលែងក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាគោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ថ្នាក់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសបងប្អូនប្រជាពលរដ្ឋទាំងអស់សូមអញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នានៅថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ នេះ កុំបីអាក់ខានឡើយ។ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្ដាប្រទេសជាមិត្ត អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយអភិវឌ្ឍវិស័យកសិកម្ម ជាពិសេស វិស័យជលផលដ៏មានសារសំខាន់នេះ ដើម្បីបុព្វហេតុនៃការអភិវឌ្ឍនិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងសូមបន្តនូវប្រពៃណីនេះឲ្យកាន់តែជិតស្និទ្ធនិងទទួលបានផ្លែផ្កាល្អប្រសើរថែមទៀតនាអនាគតកាល។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរចំពោះព្រះតេជព្រះគុណ ព្រះមេគណ ព្រះគ្រូចៅអធិការ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស លោកយាយ លោកតា ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរព្រះគុណ និងអរគុណ!***

# របាយការណ៍

## ថ្លែងដោយឯកឧត្តមបណ្ឌិត ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ “រុក្ខទិវា” នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣

**- សូមក្រាបថ្វាយបង្គំព្រះមេគណ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់**

**- សូមក្រាបថ្វាយបង្គំ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

**- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**- សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត**

**- អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ**

**- លោកតា លោកយាយ លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ ក្មួយៗ សិស្សានុសិស្ស និងជនរួមជាតិ ជាទីមេត្រី**



*ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ “រុក្ខទិវា” នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ថ្ងៃនេះ ជាទិវាដ៏នក្ខត្តឫក្សក្រៃលែងដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរួមជាមួយអាជ្ញាធរខេត្តព្រះសីហនុ និងប្រជាពលរដ្ឋដ៏ច្រើនកុះករ មានមហាកិត្តិយសដ៏ឧត្តុង្គឧត្តម និងមានសេចក្តីសោមនស្សរីករាយជាអនេកប្បការ ដើម្បីសម្តែងនូវអភិវន្ទនាការ និងមហាបដិសណ្ឋារកិច្ចស្វាគមន៍ដ៏កក់ក្តៅបំផុតដើម្បីអបអរសាទរចំពោះព្រះរាជវត្តមានដ៏ថ្លៃថ្លាបំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដែលព្រះអង្គបានសព្វព្រះរាជហឫទ័យយាងជាព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យ “**រុក្ខទិវា**” នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាឱកាសដ៏មហាប្រសើរនេះ និងជាព្រះរាជបេសកកម្មលើកទី៩ របស់ព្រះអង្គ ដែលបានយាងចូលរួមជាព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត បន្ទាប់ពីព្រះអង្គបានយាងចូលរួមក្នុងពិធីបុណ្យរុក្ខទិវា នៅភូមិកំព្រហ្ម ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីឆ្នាំ២០១២ កន្លងទៅនេះ និងសូមសម្តែងនូវមនោសញ្ចេតនាអបអរសាទរយ៉ាងកក់ក្តៅចំពោះវត្តមាន ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលបានអញ្ជើញ ចូលរួមជាកិត្តិយសដ៏ឧត្តុង្គឧត្តម ញ៉ាំងឲ្យពិធីបុណ្យរុក្ខទិវានាឆ្នាំនេះប្រព្រឹត្តទៅក្នុងបរិយាកាសមួយវិសេសវិសាលយ៉ាងក្រៃលែង។ ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមស្វាគមន៍ចំពោះវត្តមានសម្តេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងជនរួមជាតិទាំងអស់ដែលបានយាង និងអញ្ជើញមកចូលរួមក្នុងពិធីដ៏មហោឡារិកនេះ។ ព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាពេលនេះ គឺជាការលើកទឹកចិត្តប្រកបដោយភាពកក់ក្តៅបំផុតដល់ខ្ញុំព្រះករុណាខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា ជាពិសេសជាទិវាប្រវត្តិសាស្ត្រសម្រាប់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ១ ឃុំអូរត្រេះ



*ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងឱកាសប្រារព្ធពិធីបុណ្យ "រុក្ខទិវា" នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ស្រុកស្ទឹងហាវ និងប្រជាពលរដ្ឋ ក្នុងខេត្តព្រះសីហនុដ៏ថ្លៃថ្លានេះ។

សម្រាប់ឆ្នាំ២០១៣នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនឹងអាជ្ញាធរខេត្ត ព្រះសីហនុ បានជ្រើសរើសកំណត់យកទីតាំងសម្រាប់ប្រារព្ធពិធីបុណ្យរុក្ខទិវាលើកទី២៣នេះ ស្ថិតនៅក្នុងភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្នុងតំបន់គ្រប់គ្រងធនធានធម្មជាតិ ព្រែកទឹកសាប ហើយប្រភេទឈើដែលយកមកដាំក្នុងពិធីនេះជាប្រភេទឈើក្រញូង គគីរ ឈើទាល នៅលើផ្ទៃដីទំហំ ២០ហ.ត ក្នុងគោលបំណងដើម្បីស្តារ និងដាំឡើងវិញនូវប្រភេទឈើមានរយៈពេលវែង ដើម្បីធ្វើឲ្យប្រសើរឡើងនូវសោភ័ណភាពទេសភាពធម្មជាតិ បរិស្ថាន រក្សានិយតភាពប្រភពទឹក និងចូលរួមចំណែកកាត់បន្ថយការឡើងកម្តៅនៅក្នុងពិភពផែនដី និងការប្រែប្រួលអាកាសធាតុ។

ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំបាទ សូមព្រះរាជាអនុញ្ញាតទូលថ្វាយជាព្រះសណ្តាប់ និងអនុញ្ញាតជម្រាបជូនជ្រាបអំពីប្រវត្តិភូមិសាស្ត្រនៃទីតាំងដែលប្រារព្ធពិធីបុណ្យរុក្ខទិវាថ្ងៃនេះដូចតទៅៈ ទីតាំងនេះស្ថិតនៅប៉ែកខាងជើងនៃក្រុងព្រះសីហនុ។ ឆ្លងកាត់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាង២ទសវត្សមក ព្រៃឈើតំបន់នេះបានទទួលរងនូវការដកហូតឈើមិនស្របតាមបច្ចេកទេស និងទទួលរងនូវការកាប់បំផ្លាញព្រៃឈើ និងកាប់ទន្ទ្រានយកដីព្រៃឈើដើម្បីយកធ្វើជាកម្មសិទ្ធិបណ្តាលឲ្យព្រៃឈើតំបន់នេះរេចរឹលជាបន្តបន្ទាប់។ ដោយមើលឃើញអំពីសារសំខាន់នៃព្រៃឈើតំបន់នេះ នៅក្នុងឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៧៦អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដើម្បីបង្កើតតំបន់នេះជាតំបន់គ្រប់គ្រងធនធានធម្មជាតិព្រែកទឹកសាប ដែលជាប្រភពតែមួយគត់សម្រាប់ផ្គត់ផ្គង់ទឹកស្អាត និងធានានិរន្តរភាពនៃការអភិវឌ្ឍសម្រាប់ក្រុងព្រះសីហនុ លើផ្ទៃដីសរុបទំហំ ៦.២០២ ហិកតា។ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ១៩៩៩ បើទោះបីជាសមត្ថកិច្ចជំនាញ និងអាជ្ញាធរមូលដ្ឋានបានខិតខំយកចិត្តទុកដាក់ការពារ និងអភិរក្សតំបន់នេះយ៉ាងណាក្តីក៏នៅតែមានការកាប់រានព្រៃឈើដើម្បីយកដីធ្វើជាកម្មសិទ្ធិក្នុងសណ្ឋានជាលក្ខណៈស្បែកខ្លា។ ពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ន រដ្ឋបាលព្រៃឈើបានសហការជាមួយដៃគូអភិវឌ្ឍន៍ DANIDA នៃប្រទេសដាណឺម៉ាក់ និងកងយោធពលខេមរភូមិន្ទបានដាំដុះព្រៃឈើនៅតំបន់នេះឡើងវិញលើផ្ទៃដីសរុបទំហំ ២.១៥០ហិកតា ក្នុងសណ្ឋានជាចម្ការឈើលក្ខណៈស្បែកខ្លា ក្នុងនោះ រដ្ឋបាលព្រៃឈើដាំដុះនៅលើផ្ទៃដីទំហំ ១.២៥០ ហិកតា កងយោធពលខេមរភូមិន្ទដាំនៅលើផ្ទៃដីទំហំ ៧០០ហិកតា និងក្រោមជំនួយរបស់ DANIDA ដាំនៅលើផ្ទៃដីទំហំ ២០០ហិកតា។ បើទោះបីជាមានកិច្ចខំប្រឹងប្រែងក្នុងការការពារ និងស្តារព្រៃឈើយ៉ាងនេះក៏ដោយ ក៏នៅមានសកម្មភាពលួចកាប់ដើមឈើ និងវាតយកដីចម្ការដែលបានដាំ យកធ្វើជាកម្មសិទ្ធិក្នុងការសាងសង់លំនៅដ្ឋាន និងបោះបង្គោលរបងហ៊ុមព័ទ្ធ ទុកលក់ឲ្យឈ្មួញកណ្តាលទៀតផង។ បច្ចុប្បន្នតំបន់នេះ នៅសល់ ផ្ទៃដីទំហំប្រមាណ ៥.៩០០ ហិកតា សម្រាប់ការពារ អភិរក្ស និងស្តារព្រៃឈើឡើងវិញ។

ជារួមព្រៃឈើនៅក្នុង និងជុំវិញតំបន់ក្បាលឆាយបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សានិយ័តកម្មប្រភពទឹកសាបតែមួយគត់សម្រាប់ផ្គត់ផ្គង់ដល់ក្រុងព្រះសីហនុទាំងមូល និងជាអាងស្តុកទឹកសាបក្រោមដីយ៉ាងធំ ព្រមទាំងមានតួនាទីសំខាន់ក្នុងការទប់ទល់ការជ្រៀតចូលទឹកប្រៃពីសមុទ្រ (Sea Water Intrution) មកក្នុងប្រព័ន្ធទឹកក្រោមដីបន្ថែមទៀត។ ជាក់ស្តែងនាកំឡុងខែមេសា ឆ្នាំ២០១៣ កន្លងទៅនេះ តំបន់ព្រែកទប់នៃក្រុងព្រះសីហនុជួបប្រទះការរីងស្ងួតទឹកក្នុងព្រែក ដែលបណ្តាលឲ្យមានកង្វះទឹកស្អាតសម្រាប់ប្រជាពលរដ្ឋនៅក្នុងក្រុងប្រើប្រាស់។ ដូចនេះ តម្រូវការទឹកស្អាតប្រើប្រាស់ក្នុងក្រុងព្រះសីហនុទាំងមូល គឺអាស្រ័យលើប្រភពទឹកក្បាលឆាយតែមួយគត់។ ជាពិសេសនៅរដូវប្រាំង ក្រុងព្រះសីហនុទាំងមូល



*ទិដ្ឋភាព ក្នុងឱកាសប្រារព្ធពិធីបុណ្យ “រុក្ខទិវា” នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ត្រូវការទឹកប្រើប្រាស់ពីទឹកក្រោមដី និងទឹកស្អាតពីតំបន់ក្បាលឆាយ។ ប្រសិនបើមិនមានព្រៃឈើជួយសម្រួលដល់ការជ្រាបចូលរបស់ទឹកភ្លៀងទៅក្នុងដីបានច្រើនទេនោះនឹងធ្វើឲ្យបរិមាណទឹកក្រោមដីថយចុះ សម្ពាធទឹកក្រោមដីខ្សោយ ដែលជាហេតុធ្វើឲ្យទឹកប្រៃពីសមុទ្រជ្រាបចូលបន្តិចម្តងៗរហូតដល់ទឹកទៅជាភ្លាវ ឬប្រៃ ប្រើប្រាស់លែងកើតតែម្តង។ ដោយយល់ពីសារៈសំខាន់នេះ ទើបពិធីបុណ្យរុក្ខទិវាប្រារព្ធឡើងក្នុងតំបន់ព្រែកទឹកសាបក្បាលឆាយនេះ ក្រោមប្រធានបទ “**ព្រៃឈើដើម្បីទឹក ទឹកដើម្បីអភិវឌ្ឍ**” ។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំបាទ សូមព្រះរាជានុញ្ញាតទូលថ្វាយ ប្រគេន និងជម្រាបជូនថា ក្នុងអាណត្តិទី៤នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បាននិងកំពុងបន្តធ្វើកំណែទម្រង់វិស័យព្រៃឈើ កំណែទម្រង់វិស័យដីធ្លី ដោយអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មី ផ្តល់ប័ណ្ណកម្មសិទ្ធិជូនដល់ប្រជាពលរដ្ឋប្រកបដោយសមធម៌។ ដោយឡែក កំណែទម្រង់វិស័យព្រៃឈើ គឺជាអាទិភាពមួយក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញការអនុវត្តកម្មវិធីព្រៃឈើជាតិជាពិសេសកម្មវិធីកំណត់ព្រំប្រទល់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ កម្មវិធីអភិរក្សធនធានព្រៃឈើ និងជីវចម្រុះ កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច និងកម្មវិធីសហគមន៍ព្រៃឈើជាដើម។ សមិទ្ធផលធំៗដែលសម្រេចបានក្នុងឆ្នាំ២០១២ មានដូចតទៅ ៖ ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍បាន៤.៩៦៨បង្គោល មានប្រវែងប្រមាណ ៥៥៩គីឡូម៉ែត្រ ស្ថិតក្នុងខេត្តចំនួន ១៣ គឺកំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ធំ កំពង់ចាម ព្រះសីហនុ ព្រះវិហារ កំពត ប៉ៃលិន កណ្តាល ក្រចេះ រតនគិរី មណ្ឌលគិរី និងកោះកុង។ ចំពោះការអភិរក្សធនធានព្រៃឈើ និងជីវចម្រុះ បានធ្វើការដាំដុះព្រៃឈើជាចម្ការសរុបបានទំហំ ១៣.៨៨៨ ហិកតា ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបាន ៤៨៨ ហិកតា ក្រុមហ៊ុនវិនិយោគឯកជនដាំបានចំនួន ១៣.៤០០ហិកតា។ ទន្ទឹមនឹងនេះ រដ្ឋបាលព្រៃឈើបណ្តុះកូនឈើនៅគ្រប់ទីកន្លែងក្នុងទូទាំងប្រទេសសម្រេចបានចំនួន ២,៦លានដើម និងចែកជូនដល់ប្រជាពលរដ្ឋ និងដាំតាមទីសាធារណៈបានជាង ២,៣ លានដើម ព្រមទាំងបានបង្កើតសួនអាពាហ៍ពិពាហ៍ ២៨កន្លែង មានផ្ទៃដីទំហំ ៣៤៩ ហិកតា ហើយផ្នែកឯកជនខ្នាតតូចនិងអង្គការក្រៅរដ្ឋាភិបាលបណ្តុះកូនឈើបានប្រមាណ ៤៥០ ពាន់ដើម។ ដោយឡែក ចំពោះការងារសហគមន៍ព្រៃឈើវិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសបង្កើតសហគមន៍ព្រៃឈើចំនួន ៧កន្លែង លើផ្ទៃដីសរុបទំហំ ៥.៨៤១ហ.ត មានសមាជិកចូលរួមចំនួន ៣.៣៣៥គ្រួសារ និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ២៤កន្លែង លើផ្ទៃដីសរុបទំហំ១១.៤៩៨ហិកតា។ គិតមកដល់បច្ចុប្បន្នសហគមន៍ព្រៃឈើនៅទូទាំងប្រទេសមានចំនួនសរុប ៤៥៧ កន្លែង មានផ្ទៃដីទំហំ ៣៩៩.៨៦៦ហិកតា ស្ថិតនៅក្នុងខេត្តចំនួន ២១ ដែលមានសមាជិកចូលរួមចំនួន ១១០.០២៩ គ្រួសារ មានប្រជាពលរដ្ឋសរុបចំនួន ៣១៤.៣៩៤នាក់ ក្នុងនោះមានស្ត្រីចំនួន ១៥០.៥០៨នាក់។ រីឯការប្រមូលចំណូលពីវិស័យព្រៃឈើសរុបបានចំនួនជាង ៣៣ពាន់លានរៀល ស្មើនឹង ១៥៥% នៃផែនការឆ្នាំ។

ជាងនេះទៅទៀត ការបង្ក្រាបបទល្មើសព្រៃឈើក្នុងឆ្នាំ២០១២កន្លងទៅនេះ ដោយអនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើបានសហការជាមួយកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ



*ទិដ្ឋភាព ក្នុងឱកាសប្រារព្ធពិធីបុណ្យ "រុក្ខទិវា" នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

ព្រះរាជអាជ្ញាអមសាលាដំបូង និងអាជ្ញាធរដែនដីរាជធានី-ខេត្ត បើកយុទ្ធនាការបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទនៅក្នុងទូទាំងប្រទេសបានចំនួន ១.០៩៩ករណី បានចាប់ឃាត់និងរឹបអូសឈើគ្រប់ប្រភេទសរុបចំនួន ៤.៦៩២ម៣ ហើយឈើទាំងនេះបានដាក់ដេញថ្លៃជាសាធារណៈចំនួន ០៦លើក ស្មើនឹង ២.៤២៥ម៣ ។ រដ្ឋបាលព្រៃឈើបានស្រង់ស្ថិតិដីព្រៃឈើដែលត្រូវបានរំលោភបំពានបានចំនួន ៧៨.៩៣៤ហិកតា និងបានចេញដីកាបដិសេធដកហូតដីព្រៃឈើមកវិញបានចំនួន ៦.៩៦៤ហិកតា និងដកហូតរណារយន្តបានចំនួន ១៦៤ គ្រឿង ។

សរុបសេចក្តីមក ក្រៅពីខ្លឹមសារដូចបានរៀបរាប់ខាងលើ ខ្ញុំព្រះករុណាខ្ញុំបាទ សូមព្រះរាជានុញ្ញាតនិងអនុញ្ញាតជម្រាបជូនថា តាមលទ្ធផលនៃការវាយតម្លៃបានបង្ហាញថានៅក្នុងឆ្នាំ ២០១២ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២៧,៥% ក្នុងផលិតផលសរុបក្នុងស្រុក(ផ.ស.ស) និងកំណើនវិស័យកសិកម្មមានប្រមាណ៤,៣%។ នៅក្នុងវិស័យកសិកម្មទាំងមូល ការចូលរួមពីផ្នែកដំណាំកសិកម្មមានប្រមាណ៥៤,៨% ផលិតកម្មនេសាទ២៥,៤% ផលិតកម្មសត្វ១៤,១% និងអាជីកម្មព្រៃឈើមានប្រមាណ៥,៧% ក្នុងសន្និសីទលើកទី៣៨ របស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) ដែលបានប្រព្រឹត្តទៅនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលីកាលពីថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០១៣កន្លងទៅនេះបានរកឃើញនិងទទួលស្គាល់ថាប្រទេសចំនួ៣៨ក្នុងចំណោមប្រទេស១៩៤ លើពិភពលោកមានភាពជឿនលឿនខ្លាំងក្នុងការប្រយុទ្ធនឹងភាពក្រីក្រ និងអត់ឃ្លានក្នុងនោះប្រទេសចំនួន១៨សម្រេចបានទាំងគោលដៅទី១នៃគោលដៅសហសវត្ស ពោលគឺបានកាត់បន្ថយអត្រានៃភាពក្រីក្របានចំនួនចាប់ពីពាក់កណ្តាលឡើងទៅនិងគោលដៅនៃសន្និសីទកំពូលស្បៀងអាហារពិភពលោកឆ្នាំ១៩៩៦ ដែលបានកាត់បន្ថយ ចំនួនប្រជាពលរដ្ឋដែលអត់ឃ្លានបានចាប់ពីពាក់កណ្តាលឡើងទៅ។ប្រទេសចំនួន២០ទៀតសម្រេចបានគោលដៅទី១នៃគោលដៅសហសវត្សឆ្នាំគោលឆ្នាំ២០០០ ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ។ ប្រទេសទាំង៣៨នេះបានទទួលដោយផ្ទាល់ពីអង្គការFAOនូវប័ណ្ណទទួលស្គាល់សមិទ្ធផលប្រយុទ្ធនិងភាពអត់ឃ្លាននៃគោលដៅសហសវត្សគិតត្រឹមចុងឆ្នាំ២០១២នេះ ពោលគឺ៣ឆ្នាំមុនឆ្នាំគោលដៅ២០១៥។

- ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនជនរួមជាតិជាទីមេត្រី

ជាថ្មីម្តងទៀត តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំបាទផ្ទាល់ ទូលព្រះបង្គំសូមថ្លែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅចំពោះព្រះរាជវត្តមានរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតក្នុងឱកាសដែលព្រះអង្គបានយាងមកចូលរួមក្នុងពិធីបុណ្យរុក្ខទិវា នៅក្នុងទឹកដីស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដ៏មហោឡារិកនេះ។ ព្រះរាជវត្តមានរបស់ព្រះករុណានាពេលនេះ គឺជាមហាកិត្តិយសដ៏ធំធេង និងផ្តល់នូវភាពសប្បាយរីករាយ ភាពកក់ក្តៅសម្រាប់ប្រជារាស្ត្រខេត្តព្រះសីហនុទាំងមូលដែលតែងតែទន្ទឹងរង់ចាំចង់ឃើញព្រះភ័ក្ត្រ និងបានស្តាប់ព្រះសូរសៀងដោយផ្ទាល់របស់ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង និងជាសក្ខីភាពបង្ហាញឲ្យឃើញអំពីការយកព្រះទ័យទុកដាក់ខ្ពស់បំផុតរបស់ព្រះករុណាចំពោះសម្បត្តិ









*ទិដ្ឋភាពទូទៅ ក្នុងឱកាសប្រារព្ធពិធីបុណ្យ "រុក្ខទិវា"
នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ
ខេត្តព្រះសីហនុ*

ព្រៃឈើជាតិ និងប្រជារាស្ត្ររបស់ព្រះអង្គតាមគន្លងនៃព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ព្រះវររាជបិតា និងព្រះវររាជមាតារបស់ព្រះអង្គ។

ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំបាទ សូមព្រះរាជានុញ្ញាត និងអនុញ្ញាតថ្លែងអំណរព្រះគុណព្រះករុណាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងអរគុណចំពោះវត្តមានដ៏ខ្ពង់ខ្ពស់សម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលតំណាងឲ្យប្រទេសអ្នកផ្ដល់ជំនួយ អង្គការជាតិ និងសហគមន៍អន្តរជាតិទាំងអស់ដែលបូជាកម្លាំងកាយចិត្តបានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងកិច្ចជួយស្ដារ និងអភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃនៅកម្ពុជា និងសូមអំពាវនាវបន្តជួយលើវិស័យនេះបន្ថែមទៀត ដើម្បីឲ្យកម្ពុជាបានទទួលនូវការរីកចម្រើន នាពេលអនាគតដ៏ខ្លីខាងមុខ។

ជាអវសានទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលំឱនកាយឧទ្ទិសដល់គុណបុណ្យព្រះរតនត្រ័យ និងបន់ស្រន់ដល់វត្ថុស័ក្ដិសិទ្ធិគ្រប់ទិសទីនៃមាតុភូមិអង្គរដ៏បវរនៃយើងសូមប្រោសប្រទានពរជ័យ បវរមហាប្រសើរ តាមជួយបីបាច់ថែរក្សាព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ សូមព្រះអង្គទាំងទ្វេមានព្រះជន្មាយុយឺនយូរមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះបញ្ញាញាណឈ្លាសវៃ និងមានជោគជ័យជានិច្ចនិរន្ដរ៍ ទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅជាប្រជារាស្ត្រទូទាំងប្រទេស និងសូមគោរពជូនពរជ័យបវរប្រសើរដល់សម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត សូមទទួលបានជោគជ័យដ៏ត្រចះត្រចង់បន្ថែមទៀតក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេសជាតិឲ្យមានភាពរីកចម្រើន ប្រកបដោយសុខសន្តិភាព និងវឌ្ឍនភាពសង្គមរុងរឿងតរៀងទៅ។ សូមប្រគេនពរ និងប្រសិទ្ធពរជ័យសិរីមង្គល ថ្វាយ និងជូន ចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ សម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមទទួលនូវពរជ័យទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និងអរគុណ!***

# របាយការណ៍

## ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធ "ទិវាមច្ឆជាតិ "នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ

ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣



*ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្ងៃងក្នុងឱកាសប្រារព្ធ "ទិវាមច្ឆជាតិ " នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

- សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរព

- ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- លោកតា លោកយាយ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងជនរួមជាតិជាទីមេត្រី !

ជាបឋមតាងនាមឲ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំព្រះករុណាខ្ញុំសូមធ្វើគារវកិច្ចដោយស្មោះស និងសូមថ្លែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ជាពិសេសវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដែលជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រារព្ធ "ទិវាមច្ឆជាតិ១កក្កដា លើកទី១១" នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ នាពេលនេះនិងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ លោកតា លោកយាយ បងប្អូនជនរួមជាតិ និងក្មួយៗសិស្សានុសិស្សទាំងអស់ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងពិធីដ៏មានអត្ថន័យនាថ្ងៃនេះ។ ឆ្លៀតក្នុងឱកាសដ៏មហោឡារិកនេះខ្ញុំព្រះករុណាខ្ញុំសូមជម្រាបជូនថា គឺជាលើកទី១១ហើយដែលយើងបានរៀបចំប្រារព្ធទិវាមច្ឆជាតិនេះ ហើយយើងនឹងរៀបចំលែងកូនត្រី កូនបង្កង និងវារីសត្វផ្សេងៗសរុបជាង១លានក្បាល ដើម្បីធ្វើឱ្យអាងទឹក១មករានេះ សម្បូរត្រី និងបង្កងជាប្រយោជន៍បម្រើតម្រូវការហូបចុករបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះផងដែរ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំសូមអនុញ្ញាតពិតពុទ្ធដីកានិងជម្រាបជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រីនិងបងប្អូនជនរួមជាតិទាំងអស់មេត្តាជ្រាបអំពីប្រវត្តិខ្លះៗនៃអាងទឹក១មករានេះ គឺត្រូវបានសាងសង់ឡើងក្នុងជំនាន់ ប៉ុល ពត នាឆ្នាំ១៩៧៧-៧៨ ដែលទប់កាត់ស្ទឹងជីនិត សម្រាប់បម្រើការងារបង្កបង្កើនផលកសិកម្មក្នុងស្រុកសន្ទុក និងស្រុកបារាយណ៍។ ក្រោយមកអាងទឹកនេះត្រូវបានជួសជុល និងកែលម្អតាមដំណាក់កាលជាបន្តបន្ទាប់ដូចតទៅនេះ៖

ក្នុងឆ្នាំ ១៩៨០ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា បានជួសជុលដោយស្បៀងពលកម្ម

ក្នុងឆ្នាំ១៩៨៨ សម័យរដ្ឋកម្ពុជា បានប្រើប្រាស់ថវិកា

ជាតិជួសជុល ដោយនាយកដ្ឋានធារាសាស្ត្រឧតុនិយម និងផលសាស្ត្រ

ក្នុងចន្លោះឆ្នាំ២០០២ ដល់ឆ្នាំ២០០៦ បានជួសជុលដោយក្រសួងធនធានទឹក និងឧតុនិយម ដោយមានការជួយឧបត្ថម្ភថវិកាកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងជំនួយឥតសំណងពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) រួមជាមួយនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា សរុបប្រមាណ ២១លាន ដុល្លារសហរដ្ឋអាមេរិក ដែលបច្ចុប្បន្នហៅថា ប្រព័ន្ធស្រោចស្រពស្ទឹងជីនិត ឬអាងទឹក១មករា។

ប្រព័ន្ធស្រោចស្រពស្ទឹងជីនិតនេះ មានប្រភពទឹកចេញពីក្រោមដី គួបផ្សំ ជាមួយនឹងទឹកភ្លៀងហូរធ្លាក់មកពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ ដែលមានផ្ទៃក្រឡាអាងសរុបទំហំ ២.៥២០ហិកតា អាចស្តុកទឹកបានចំនួន ៣៨លានម៉ែត្រគូប មានទំនប់សណ្តរ២ខ្សែប្រវែងសរុប ១៥គីឡូម៉ែត្រ សំណង់ទ្វារទឹកធំចំនួន២ផ្លូវ ចរាចរត្រីចំនួន១ សំណង់បង្ហៀរទឹក១ ប្រវែង ៧៥០ម៉ែត្រ មានប្រឡាយមេប្រវែងសរុប ៩.៦០០ម៉ែត្រ និងមានប្រឡាយចែកចាយទឹកស្រោចស្រពសរុបប្រវែង ៤២ គីឡូម៉ែត្រ។ សព្វថ្ងៃនេះ ប្រព័ន្ធស្រោចស្រពស្ទឹងជីនិតមានលទ្ធភាពស្រោចស្រព លើផ្ទៃដីនៅក្នុងស្រុកចំនួន២គឺស្រុកសន្ទុក និងស្រុកបារាយណ៍ដែលអាចស្រោចស្រពក្នុងរដូវវស្សាលើផ្ទៃដីសរុប ២២.០០០ហិកតា និងរដូវប្រាំងលើផ្ទៃដីសរុប៥.០០០ ហិកតា។

- ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ !
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព !
- អង្គពិធីទាំងមូលជាទីមេត្រី !

ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល កន្លងមករដ្ឋបាលជលផលបានខិតខំរិះរកវិធានការធ្វើឱ្យផលត្រីកើនឡើងវិញតាមរយៈ ទី១: ការលុបបំបាត់បទល្មើសបំផ្លិចបំផ្លាញខ្លាំងក្លា ជាពិសេសការប្រើឧបករណ៍ស្ប៉ៃមុង និងឧបករណ៍ឆក់ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើបរិមាណផលត្រី។ ហេតុនេះហើយទើបយើងបានបង្កើនសកម្មភាពបង្ក្រាបបទល្មើសទាំងនេះនៅគ្រប់ទីកន្លែងទូទាំងប្រទេស ទី២: ការបំផុសចលនាលែងកូនត្រី លែងកូនបង្កងក្នុងដែនទឹកធម្មជាតិ ទី៣: ការអភិរក្សស្រះជម្រកត្រីមេពូជ និងទី៤:



*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួមក្នុងឱកាសប្រារព្ធ "ទិវាមច្ឆជាតិ "នៅអាងទឹក ១មករា ភូមិតាគោគ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ការការពារ និងដាំឡើងវិញនូវព្រៃលិចទឹក និងព្រៃកោងកាង។

ដោយឡែក ក្នុងឆ្នាំ២០១២កន្លងមកនេះ យើងសង្កេតឃើញថា ដាយត្រីបានបន្តចាប់បានទាំងខ្មែត និងរនោច ហើយមានហ្វូងត្រីប្រាធំធ្វើចរាចរចុះពីបឹងទន្លេសាប ដែលអាចនេសាទបានដោយដាយត្រីជាច្រើនដែរ។ម្យ៉ាងទៀតប្រភេទត្រីព្រួលក៏បានបង្ហាញមុខឡើងវិញនៅក្នុងផលនេសាទផងដែរ។សភាពការណ៍នេះ យើងអាចវាយតម្លៃបានថា នយោបាយកែទម្រង់វិស័យជលផលស៊ីជម្រៅរបស់សម្តេច តេជោសែន កំពុងបានផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋទូទាំងប្រទេសហើយ តាមរយៈការកើនឡើងនៃផលនេសាទតាមគ្រួសារដែលមានប្រជានេសាទប្រមាណ១,៥លាននាក់ មានជីវភាពពឹងផ្អែកលើរបរនេសាទនេះ និងប្រមាណ ៦លាននាក់ទៀតមានមុខរបរពាក់ព័ន្ធនឹងអាជីវកម្មនេសាទ។ បងប្អូនប្រជាពលរដ្ឋទូទៅបានអបអរសាទរនិងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ តេជោសែន ដែលបានលុបឡូត៍នេសាទទូទាំងប្រទេសធ្វើឱ្យប្រជាពលរដ្ឋបាននេសាទយ៉ាងទូលំទូលាយ។ ឆ្លៀតឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំបាទសូមអនុញ្ញាតធ្វើរបាយការណ៍សង្ខេបអំពីការអភិវឌ្ឍវិស័យជលផលជាពិសេសឆ្នាំ២០១២ កន្លងមកនេះ ដែលមានខ្លឹមសារដូចតទៅ៖

១. បរិមាណផលនេសាទ: ផលត្រីសរុបឆ្នាំ២០១២ មានចំនួន ៦៨២ពាន់តោន កើនលើសឆ្នាំមុន១៤% ត្រូវជា ៧៤ពាន់តោន ក្នុងនោះមានផលនេសាទទឹកសាបប្រមាណ ៥០៩ពាន់តោន ផលនេសាទសមុទ្រ ៩៩ពាន់តោន ផលវារីវប្បកម្ម ៧៤ពាន់តោន។

២- ការអភិវឌ្ឍវារីវប្បកម្ម: មានជាអាទិ៍ការចិញ្ចឹមត្រី



*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួមក្នុងឱកាសប្រារព្ធ “ទិវាមច្ឆជាតិ “នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

ការផលិតកូនត្រីពូជ កន្លែងភ្ញាស់ត្រីមាន ២៨០កន្លែង ដែលក្នុងនោះមាន ២៦៧កន្លែង ជារបស់ប្រជាជន តាមរយៈការផ្ដល់បច្ចេកទេសពីរដ្ឋបាលជលផល ការបណ្ដុះបណ្ដាលអ្នកបច្ចេកទេសចិញ្ចឹម ភ្ញាស់ត្រីនិងបង្កងបានចំនួន ៣៥០នាក់ ក្នុងនោះមានកសិករ ១៥៤នាក់ជាគ្រូបង្គោល និងជាអ្នកផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងមានប្រជាពលរដ្ឋប្រមាណ ៦១.000គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ហើយអាចរកប្រាក់ចំណូលគ្រួសារបានយ៉ាងច្រើនគួរជាទីពេញចិត្ត។

៣- ការអភិវឌ្ឍសហគមន៍នេសាទៈ ក្រោយកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផលឆ្នាំ២០១២ សហគមន៍នេសាទចំនួន៤៧ ត្រូវបានបង្កើតឡើងបន្ថែមទៀត ពង្រីកសហគមន៍ចំនួន៣៣ ដូច្នេះសហគមន៍នេសាទសរុបទាំងអស់មានចំនួន៥១៦បានគ្របដណ្ដប់ស្ទើរគ្រប់កន្លែងសំខាន់ៗនៃដែននេសាទទូទាំងប្រទេសអស់ហើយ និងមានប្រជាពលរដ្ឋប្រមាណ ១៤៦.៣១៥គ្រួសារ ត្រូវជា ៣២៥.២៣៩នាក់ ជាសមាជិកសហគមន៍នេសាទ។ ដោយឡែកការបង្កើតធនាគារក្ដាមអនុវត្តបានចំនួន៣១កន្លែងស្មើនឹង៩២បៃ ដែលបានផ្ដល់កូនក្ដាមចំនួនប្រមាណ២០៧.១៦៣លានក្បាលចូលទៅក្នុងសមុទ្រវិញ។ សកម្មភាពនេះ តាមការស្រាវជ្រាវរបស់វិទ្យាស្ថានឃើញថា បានធ្វើឲ្យផលក្ដាមសេះមានកំណើនប្រមាណ ៤ដងបើប្រៀបធៀបមុនពេលបង្កើតធនាគារក្ដាម ហើយបានធ្វើឱ្យបងប្អូនអ្នកនេសាទមួយចំនួនបានប្ដូរមុខរបរផ្សេងៗមកនេសាទដោយមងក្ដាមវិញនិងបានធ្វើឱ្យជីវភាពអ្នកនេសាទនៅតំបន់ឆ្នេរបានធូរធារមួយកម្រិតដែរ។

<u>៤- ការបង្កើតស្រះជម្រកត្រីសហគមន៍ៈ ផ្អែកតាម</u>អនុសាសន៍ដ៏ថ្លៃថ្លារបស់តេជោ **សែន** កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ក្នុងឱកាសទិវាមច្ឆជាតិនៅខេត្តកែប ដែលតម្រូវឱ្យរៀបចំស្រះជម្រកត្រីសហគមន៍ឱ្យបានមួយកន្លែងក្នុង ១ឃុំនោះ ឥឡូវនេះរៀបចំបានចំនួន៧៦៥កន្លែងរួចហើយ ដែលក្នុងនោះខេត្តកំពង់ស្ពឺបានច្រើនជាងគេចំនួន១៧៤កន្លែង កន្លែងដែលបានរៀបចំហើយធ្វើឱ្យផលត្រីតាមវាលស្រែកើនពី៤-៦ដងជាមធ្យម និងបានចូលរួមចំណែកបង្កើនផលស្រូវក្នុងស្រែទៀតផង ព្រោះកាលណាត្រីច្រើនអាចជួយស៊ីសត្វល្អិតដែលបំផ្លាញស្រូវ។

៥- ការអភិរក្សធនធានជលផលៈ ក្រោយពីការកែទម្រង់ស៊ីជម្រៅលើវិស័យជលផល រដ្ឋបាលជលផលបានខិតខំរៀបចំបង្កើតកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង ដែលមានផ្ទៃសរុប៩៧.៥០៣ហិកតា។ សរុបទាំងកន្លែងអភិរក្សដែលបង្កើតពីមុនផងមានចំនួនសរុប ៩៥កន្លែង ស្មើនឹង ២០៣.៣៤៧ហិកតា ដែលក្នុងនោះនៅតំបន់ទឹកសាបមាន ៧៩កន្លែង និងសមុទ្រ ១៦កន្លែង។ រហូតមកដល់សព្វថ្ងៃនេះ កន្លែងអភិរក្សជលផលទាំងនេះ កំពុងត្រូវបានបោះបង្គោលព្រំប្រទល់បេតុងជាបន្តបន្ទាប់ ឯកន្លែងដែលមិនទាន់មានបង្គោលបេតុងគឺប្រើបង្គោលឈើចំនួនជាង ៦០០ បង្គោលជាបណ្ដោះអាសន្នសិន និងរៀបចំស្នាក់ការយាមប្រចាំការ និងល្បាតជាប្រចាំ ដោយសហការជាមួយអាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធ និងតំណាងសហគមន៍នេសាទនៅតាមមូលដ្ឋាន។ រីឯសកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានជាអាទិ៍ ការបង្កើតតំបន់អភិរក្សនៅតាមសហគមន៍នេសាទ អភិរក្សថ្កាថ្ម ស្មៅសមុទ្រ ការដាំព្រៃលិចទឹក និងព្រៃកោងកាង ការរៀបចំអន្លង់ត្រីមេពូជនៅតាមដងទន្លេមេគង្គ ក៏ដូចជាការបន្តការអភិរក្សប្រភេទធនធានជលផលដូចជា ផ្សោតទន្លេមេគង្គ កន្ធាយក្បាលកង្កែប អណ្ដើកហ្លួង អណ្ដើកសមុទ្រ សេះសមុទ្រ ក្រពើត្រី ត្រីរាជ និងត្រីគល់រាំង បានធ្វើឲ្យចំនួនមច្ឆជាតិទាំងនេះកើនឡើងជារៀងរាល់ឆ្នាំ។

៦ ការបង្ក្រាបបទល្មើសជលផលៈ ក្នុងឆ្នាំ២០១២ នេះ ដោយមានការចង្អុលបង្ហាញពីសំណាក់ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **ឃឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់បានសហការជាមួយគណៈបញ្ជាការឯកភាពខេត្ត ស្រុក ឃុំ និងសមត្ថកិច្ចពាក់ព័ន្ធបំពេញការងារ យ៉ាងសកម្មទោះបីខ្វះកម្លាំង មធ្យោ



*កូនត្រីពូជត្រៀមលែងក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាកោត ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

បាយធ្វើដំណើរ និងថវិកាក៏ដោយ ជាពិសេសយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផល មិនឲ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ឯលទ្ធផលជាក់ស្តែងគឺបង្ក្រាបបទល្មើសបាន ៥.៣០៧ករណី ប្រៀបធៀបឆ្នាំ២០១១ កើនឡើង ៨៣៨ករណី ដោយបានរិបអូសនិងបំផ្លាញចោលរបាំងសាច់អួនក្រឡាញឹកនិងស្បៃមុងជាង ១លានម៉ែត្រ និងឧបករណ៍សម្ភារៈនេសាទជាច្រើនទៀត។

៧- ការងារស្រាវជ្រាវ ផ្សព្វផ្សាយនិងសហប្រតិបត្តិការអន្តរជាតិ

រដ្ឋបាលជលផលបានខិតខំជំរុញដល់រាជធានី ខេត្តទាំងអស់ ឱ្យដាក់តាំងរូបភាពប៉ាណូរូបភាពផ្សព្វផ្សាយនៅតាមទីប្រជុំជននានា អំពីការហាមឃាត់ប្រព្រឹត្តបទល្មើសនេសាទ និងការចូលរួមអភិរក្សប្រភពធនធានជលផល។ ក្រៅពីនេះមានបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដល់សមាជិកសហគមន៍ អាជ្ញាធរ ដែនដី និងកងកម្លាំងប្រដាប់អាវុធលើប្រធានបទការអភិវឌ្ឍន៍វារីវប្បកម្ម ការអភិរក្សធនធានជលផល ការកែច្នៃក្រោយការប្រមូលផល។ល។ដោយឡែកការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុវត្តបានចំនួន៧១៧វគ្គ ដែលមានអ្នកពាក់ព័ន្ធចូលរួមប្រមាណ ៣៩.៥៥៥នាក់ ក្នុងនោះស្រីចំនួន ១៧.១១៨ នាក់។ រីឯការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការដោយរលូន ដោយបានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានា ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍជលផលទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ដោយឡែកក្នុងដើមឆ្នាំ២០១៣នេះ មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្មសមុទ្រនៅក្រុងព្រះសីហនុ ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនបានសម្រេចជោគជ័យលើកដំបូងក្នុងការថែរក្សាត្រីឆ្ពង់ឈ្មោលឱ្យប្រែភេទទៅជាញី និងការបង្កាត់ភ្ញាស់កូនត្រីឆ្ពង់ទទួលបានលទ្ធផលល្អ ដោយមានការជួយឧបត្ថម្ភបច្ចេកទេសពីជំនាញការជប៉ុនផងដែរ។ ជាមួយគ្នានេះដែរ ក្រុមការងារបច្ចេកទេសចម្រុះ កំណែទម្រង់ជលផលកំពុងពិនិត្យកែលម្អផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏វិស័យជលផល(២០១០-២០១៩) ក្រោយពីការអនុវត្តរយ:ពេល៣ឆ្នាំរួចមក ដើម្បីធ្វើបច្ចុប្បន្នកម្មឱ្យស្របតាមសភាពការណ៍បច្ចុប្បន្ន ក្រោយពីមានកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល។ បន្ថែមលើនេះទៀត ក្នុងដើមឆ្នាំ២០១៣នេះ រដ្ឋបាលជលផលបានកសាងរួចហើយនូវសមិទ្ធផលថ្មីមួយទៀតគឺវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្មសម្តេចតេជោ ហ៊ុន សែន ដែលឥឡូវនេះកំពុងដំណើរការស្រាវជ្រាវនិងភ្ញាស់កូនត្រី និងកូនបង្កងប្រកបដោយលទ្ធផលល្អគួរជាទីសង្ឃឹម។ វិទ្យាស្ថាននេះនឹងត្រូវរៀបចំសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលខាងមុខនេះ។

សរុបសេចក្តីមក តាមលទ្ធផលនៃការវាយតម្លៃបានបង្ហាញថានៅក្នុងឆ្នាំ ២០១២ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២៧,៥% ក្នុងផលិតផលសរុបក្នុងស្រុក (ផ.ស.ស) និងកំណើនវិស័យកសិកម្មមានប្រមាណ៤,៣%។ នៅក្នុងវិស័យកសិកម្មទាំងមូល ការចូលរួមពីផ្នែកដំណាំកសិកម្មមានប្រមាណ៥៤,៨% ផលិតកម្មនេសាទ២៥,៤% ផលិតកម្មសត្វ១៤,១% និងអាជីកម្មព្រៃឈើមានប្រមាណ៥,៧%។ ស្ថិតក្នុងបរិយាកាសថ្ងៃថ្លានេះខ្ញុំព្រះករុណាខ្ញុំមានមោទនភាពសូមអនុញ្ញាត ជម្រាបជូនផងដែរថានៅក្នុងសន្និសីទលើកទី៣៨របស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) ដែលបានប្រព្រឹត្តទៅនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលីកាលពីថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០១៣កន្លងទៅនេះបានរកឃើញនិងទទួលស្គាល់ថាប្រទេសចំនួ៣៨ក្នុងចំណោមប្រទេស១៩៤លើពិភពលោកមានភាពជឿនលឿនខ្លាំងក្នុងការប្រយុទ្ធនឹងភាពក្រីក្រនិងអត់ឃ្លានក្នុងនោះប្រទេសចំនួន១៨សម្រេចបានទាំងគោលដៅទី១នៃគោលដៅសហសវត្ស ពោលគឺបានកាត់បន្ថយអត្រានៃភាពក្រីក្របានចំនួនចាប់ពីពាក់កណ្តាលឡើងទៅនិងគោលដៅនៃសន្និសីទកំពូលស្បៀងអាហារពិភពលោកឆ្នាំ១៩៩៦ ដែលបានកាត់បន្ថយចំនួនប្រជាពលរដ្ឋដែលអត់

ឃ្លានបានចាប់ពីពាក់កណ្ដាលឡើងទៅ។ ប្រទេសចំនួន២០ទៀតសម្រេចបានគោលដៅទី១នៃគោលដៅសហសវត្សឆ្នាំគោលឆ្នាំ២000 ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ។ប្រទេសទាំង៣៨នេះបានទទួលដោយផ្ទាល់ពីអង្គការ FAOនូវប័ណ្ណទទួលស្គាល់សមិទ្ធផលប្រយុទ្ធនិងភាពអត់ឃ្លាននៃគោលដៅសហសវត្សគិតត្រឹមចុងឆ្នាំ២០១២នេះ ពោលគឺ៣ឆ្នាំមុនឆ្នាំគោលដៅ២០១៥។ ជារួមសមិទ្ធផលដូចបានរៀបរាប់ខាងលើនេះ គឺមិនអាចកាត់ផ្ដាច់បានពីការដឹកនាំប្រកបដោយគតិបណ្ឌិតនិងបញ្ញាញាណដ៏ឈ្លាសវៃបំផុតរបស់ តេជោសែន បានឡើយ។

- ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !
-ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!
- អង្គពិធីទាំងមូលជាទីមេត្រី !

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែងជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិនានា និងសង្គមស៊ីវិល ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ក្នុងការជួយអភិវឌ្ឍ និងគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមទុកក្នុងចិត្តប្រកបដោយភាពកក់ក្ដៅថា ការថែរក្សាការពារ អភិរក្ស និងទប់ស្កាត់បទល្មើសជលផលជាភារកិច្ចរួមដែលទាមទារកិច្ចសហការយ៉ាងពេញលេញពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋនៅមូលដ្ឋាន តាមពាក្យស្លោក ” ត្រីដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីត្រី” ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ យ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិ ក្រោមការជួយជ្រោមជ្រែងយ៉ាងពេញទំហឹងពីអាជ្ញាធរខេត្តកំពង់ធំ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ក្នុងការរៀបចំទិវាមច្ឆជាតិនេះឡើង ក្នុងន័យបំផុសចលនាមហាជនឲ្យចេះជួយថែរក្សាការពារ និងចូលរួមអភិវឌ្ឍធនធានមច្ឆជាតិឱ្យមាននិរន្តរភាព សម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

ជាទីបញ្ចប់នេះ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមគោរពជូនពរបវរមហាប្រសើរដល់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ លោកតា លោកយាយ បងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់ សូមទទួលនូវពរជ័យទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។



*សកម្មភាពលែងត្រីក្នុងឱកាស ទិវាមច្ឆជាតិ នៅអាងទឹក ១មករា ភូមិតាភោគ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ*

នាឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំតាងនាមឱ្យមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាអាជ្ញាធរដែនដីខេត្ត មន្ត្រីរាជការ អ្នកមុខអ្នកការ និងប្រជាពលរដ្ឋទាំងអស់ក្នុងខេត្តកំពង់ធំទាំងមូលមានមោទនភាព និងកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអនុញ្ញាតគោរពអញ្ជើញ ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទតំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាផ្ដល់នូវមតិសំណេះសំណាល និងអនុសាសន៍ដ៏មានតម្លៃដើម្បីជាប្រទីបសម្រាប់យើងខ្ញុំទាំងអស់គ្នាបន្តអនុវត្តកែទម្រង់ស៊ីជម្រៅលើវិស័យជលផលឲ្យបានទទួលជោគជ័យជាផ្លែផ្កាតរៀងទៅ។

**សូមគោរពអញ្ជើញឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**

**សូមអរព្រះគុណ និងសូមអរគុណ!**

# បច្ចេកទេស ដាំដំណាំ
# ប៉េងប៉ោះ ម្ទេស និង ត្រប់ (១)

## ការរៀបចំដី និងការលើករង




ការភ្ជួររាស់ដី | វាស់ទីតាំងតាមដំណាំ | ការលើករង | ការដាក់ជីសរីរាង្គ ទ្រាប់បាត | កម្ពស់រង



ការគ្របរង | ជ្រៀកឬស្សីខ្វាស់ | ខ្វាស់ជម្រៀកឬស្សីនៅក្បាលរង តែមរង ហើយលាតដុំប្លាស្ទិចគ្របដីតាមបណ្ដោយរង



ទាញប្លាស្ទិកគ្របដីរង | គ្រប ត្រឹមត្រូវ | គ្រប មិនត្រូវ



ការកំណត់ចំងាយគុម្ព | ការចុះរណ្ដៅដោយប្រើកំប៉ុងក្ដៅ




ប្លង់ដាំ ប៉េងប៉ោះ ម្ទេសហិល និងហាវ៉ៃ | ប្លង់សម្រាប់ដាំដំណាំត្រប់

*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប( TSTD-TA 735-CAM )*

# បច្ចេកទេស ដាំដំណាំ
# ប៉េងប៉ោះ ម្ទេស និង ត្រប់ (២)

## ការគ្រប់គ្រងគ្រាប់ និងការថែទាំកូនដំណាំ



លីងល្បាយដី ដីសរីរាង្គ សម្រាប់បណ្តុះកូន

ផេះអង្កាម ដីស្រទាប់លើ ដីកំប៉ុស្ត ច្របល់គ្នា

ក្រណាត់សូត គ្រាប់មានដំណុះ ផ្អាប់គ្រាប់ក្នុងក្រណាត់សើម

ដាក់គ្រាប់១/រន្ធ



ស្រោចទឹកក្រោយដាក់ គ្រាប់ និងដាក់ក្នុងរោង

រោងសំណាញ់កាត់ពន្លឺ និងការពារសត្វល្អិតបំផ្លាញ

កូនប៉េងប៉ោះ ម្ទេស ដាំបានអាយុ២១ ថ្ងៃ និងកូនត្រប់ដាំបានអាយុ១ខែ

## ការដាំកូន



យកកូនបន្លែចេញពីថាសកុំឲ្យដាច់ឫសដាក់ដាំ

សង្កត់ដីថ្នមៗជុំវិញគល់

គ្រប់ដីឬចំបើង

## ការធ្វើទ្រើង








ធ្វើទ្រើងក្រោយដាំកូនរួច ដើម្បីទ្រផ្លែ និងការពារការដួលរលំពេលមានខ្យល់ខ្លាំង

*រៀបចំដោយ: គម្រោងបណ្តាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប* (TSTD-TA 735-CAM)

# បច្ចេកទេស ដាំដំណាំ
# ប៉េងប៉ោះ ម្ទេស និង ត្រប់ (៣)

## ការដាក់ជី



ដាក់ជីសម៉ាស់ទ្រាប់បាត មុនពេលដាំ៥-៧ថ្ងៃមិនដាំ



ដាក់ជីបំប៉នពេលអាយុ៧-២១ថ្ងៃ ចំងាយ១០ស.មពីគល់




## សត្វល្អិត និងជំងឺ



ដង្កូវស៊ីផ្លែ និងស្លឹក



ដង្កូវស៊ីរូងផ្លែ និងត្រួយ



ចៃ



ពីងពាងក្រហម



មមាចខៀវ



រុយស




ដង្កូវស៊ីញ៉ែ



ប្រ៉េដម៉ាយ



ជំងឺស្រពោន



ជំងឺរួញលឿង



ជំងឺអង់ត្រាកណូស



ជំងឺផ្សិតរលួយគល់



ជំងឺហ្វូម៉ូស៊ីសប្លៃ



ជំងឺរលួយធ្យូងគូទ

## ការប្រមូលផល



*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប*( TSTD-TA 735-CAM )

# បច្ចេកទេស ដាំដំណាំ

## ម្រះ នននោង ឃ្លោក និង ត្រឡាច (១)

### ការរៀបចំដី និងលើករង







ទាញ ប្លាស្ទិក គ្របដី រង










*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប( TSTD-TA 735-CAM )*

# បច្ចេកទេស ដាំដំណាំ

## ម្រះ នននោង ឃ្លោក និង ត្រឡាច (២)

### ការត្រៀមត្រៀមគ្រាប់ និងការថែទាំកូនដំណាំ




ការលាយច្របល់ជីសម៉ាស់ → លីងល្បាយដី និងជី → ដាក់គ្រាប់ផ្អាប់២-៣ថ្ងៃ → ដាក់១ គ្រាប់ ក្នុង ១ រន្ធ



ស្រោចទឹកក្រោយដាក់គ្រាប់ចូល → រោងសំណាញ់ដាក់កូនបណ្ដុះ → កូនម្រះ អាយុ ៨-១០ ថ្ងៃអាចយកទៅដាំបាន

### ការដាំកូនដំណាំ



យកកូនបន្លែចេញពីថាសបណ្ដុះ → ដាំតាមរន្ធចុះ → ដាំកូនបន្លែនៅពេលល្ងាយ

### ការធ្វើទ្រើង



ត្រូវធ្វើរងមុនពេលដាំ ដើម្បីឲ្យកូនបន្លែលូតលាស់បានឆាប់ ប្រើបង្គោលឬស្សី ឬ មែកឈើដែលមានស្រាប់ក្នុងមូលដ្ឋាន

*រៀបចំដោយ: គម្រោងផ្សព្វផ្សាយបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប*( TSTD-TA 735-CAM )

# បច្ចេកទេស ដាំដំណាំ

## ម្រះ ននោង ឃ្លោក និង ត្រឡាច (៣)

### ការដាក់ជី




ដាក់ជីសមាសទ្រាប់បាតមុនពេលដាំ៥-៧ថ្ងៃ

ដាក់ជីបំប៉នក្រោយដាំ៧-២១ថ្ងៃ ចម្ងាយ២0cm

ចោះរន្ធ១ តឹកពីគល់ ឬ ចោះរន្ធជីនៅចន្លោះគុម្ព

### សត្វល្អិតចង្រៃ និងជំងឺ



ដង្កូវកាត់ស្លឹក | ដង្កូវមូរស្លឹក | ចៃ | ដង្កូវចោះផ្លែ




អណ្តើកមាស | ជំងឺទុំលឿងស្លឹក | ជំងឺអុចស្លឹក

### ការប្រមូលផល



*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប*( TSTD-TA 735-CAM )

# បច្ចេកទេសដាំដំណាំ

# ត្រសក់ទ្រើង (១)

## ការរៀបចំដី និងការលើករង







ប្លង់សម្រាប់ដាំដំណាំត្រសក់ទ្រើង



*រៀបចំដោយៈ គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប( TSTD-TA 735-CAM )*

# បច្ចេកទេសដាំដំណាំ

## ត្រសក់ទ្រើង (២)

### ការគ្រប់គ្រង និងថែទាំកូនដំណាំ



លាយដីស្រទាប់លើជាមួយជីសម៉ាស់ → លីង្គដីជាមួយជីសរីរាង្គ និងផេះអង្កាម → ផ្អាប់គ្រាប់ជាមួយក្រណាត់សើម រយៈពេល១ថ្ងៃ → ដាក់គ្រាប់១ គ្រាប់ /១ រន្ធថាស



ក្រោយបណ្ដុះរួច ត្រូវស្រោចទឹក → រោងសំណាញ់ដាក់កូនបណ្ដុះរួច → ត្រសក់អាយុពី ៨-១០ ថ្ងៃ អាចយកទៅដាំបាន

### ការដាំកូនដំណាំ




ដកកូនពីថាសបណ្ដុះដាក់ដាំក្នុងរណ្ដៅ → ដាំនៅពេលល្ងាច ដោយសង្កត់ដីថ្នមៗ

### ការធ្វើទ្រើង




ធ្វើទ្រើងមុនដាំដើម្បីបង្កការងាយស្រួលដល់ការលូតលាស់របស់ដំណាំ ដោយប្រើបង្គោលឫស្សី និងមែកឈើ

*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប*( TSTD-TA 735-CAM )

# បច្ចេកទេសដាំដំណាំ

# ត្រសក់ស្រូវ (៣)

## ការដាក់ជី






| ដាក់ជីសមាសធាតុទ្រាប់បាត មុនដាំ រយៈពេលពី៥ទៅ៧ ថ្ងៃ | ដាក់ជីបំប៉ន នៅអាយុ៧-២១ថ្ងៃ | ចោះរន្ធជី ចំងាយ១តឹក | ឬ | ចោះរន្ធនៅ ចន្លោះកណ្ដាលគុម្ព |
| --- | --- | --- | --- | --- |

## សត្វល្អិតចង្រៃ និងជំងឺ



| ដង្កូវកាត់ស្លឹក | ដង្កូវមូរស្លឹក | ចៃ | ទ្រីប |
| --- | --- | --- | --- |



| អណ្ដើកមាស | ជំងឺលឿងទុំស្លឹក | ជំងឺផ្សិតម្សៅ | ជំងឺមូសាអ៊ិក |
| --- | --- | --- | --- |

## ការប្រមូលផល



រៀបចំដោយៈ គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប( TSTD-TA 735-CAM )

# បច្ចេកទេសដាំដំណាំ

## ពោត (១)

### ការរៀបចំដី និងការលើករង




ការភ្ជួររាស់ដី | វាស់វែងទីតាំងរង | កម្ពស់រង



ការដាក់ជីសរីរាង្គ ទ្រាប់បាត | គ្របចំបើងដើម្បីកាត់បន្ថយស្មៅ




ទទឹងរង១ម៉ែត្រ ដាំពីរជួរ ឬ ទទឹងរង ០.៥ម៉ែត្រ ដាំ ១ជួរ

### ការដាក់ជី






*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប( TSTD-TA 735-CAM )*

# បច្ចេកទេសដាំដំណាំ

## ពោត (២)

## សត្វល្អិតចង្រៃ និងជំងឺ




ដង្កូវកាត់ស្លឹក




ដង្កូវស៊ីរូងដើម



ស្រឹងខៀវ



ជំងឺលីហ្វប្លាយ



ជំងឺលឿងស្លឹក



ជំងឺច្រែះ



ជំងឺរលួយដើម



ជំងឺរលាកស្រទបស្លឹក



ជំងឺស្មាត់

## ការថែទាំ និងប្រមូលផល



*រៀបចំដោយៈ គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប*( TSTD-TA 735-CAM )

# បច្ចេកទេសដាំដំណាំត្រសក់ផ្អែម




## ក. សេចក្ដីផ្ដើម

បច្ចេកទេសដាំដំណាំត្រសក់ផ្អែម នេះ ត្រូវបានរៀបចំឡើងសម្រាប់កសិករ ដោយផ្អែកលើបទពិសោធន៍ធ្វើបង្ហាញបច្ចេកទេសដាំដំណាំនេះ ក្នុងរដូវប្រាំង ដើមឆ្នាំ ២០១២ នៅ ខេត្តកំពង់ចាម និង កំពង់ធំ។ ខ្លឹមសារលំអិត រៀបរាប់ក្នុងខិត្តប័ណ្ណនេះ មានក្នុង *សៀវភៅណែនាំបច្ចេកទេសកសិករ ស្ដីពីដំណាំត្រសក់ផ្អែម* ដែលអាចរកបាន តាមមន្ទីរកសិកម្មខេត្តគោលដៅ និងមណ្ឌលព័ត៌មានកសិករជនបទ ហើយអាចរកបានជាទម្រង់អេឡិចត្រូនិច តាមអាសយដ្ឋានវេបសាយ www.telecentercambodia.org។ ខ្លឹមសារស្ដីពីសត្វល្អិត និងជម្ងឺ និង ការគ្រប់គ្រងការពារ សម្រាប់ដំណាំត្រសក់ផ្អែមនេះ មិនមានបញ្ចូលក្នុងខិត្តបណ្ណ័ នេះឡើយ។



| រូបភាព | ពិពណ៌នា | អាយុត្រសក់ |
|---|---|---|
| ១ | • រៀបចំរង (លើកពូនរង ដាក់ជីទ្រាប់បាត រៀបប្រព័ន្ធស្រោចស្រពតំណក់ទឹក និងក្រាលកៅស៊ូគ្របរង) | ថ្ងៃទី ១ |
| ២ | • បណ្ដុះកូន | ថ្ងៃទី ២ |
| ៣ | • ថែទាំកូន ក្នុងរោងកូនធ្វើសំណាញ់មុងពណ៌ស (ដាំនៅពេលកូនមានអាយុ ១២ថ្ងៃ) | ថ្ងៃទី ១២ទៅទី ១៤ |
| ៤ | • ការដាំកូន (ចោះកៅស៊ូគម្របរងដោយកំប៉ុងក្ដៅ ភ្លាមមុនពេលដាំ (ហាមចោះទុកយូរ ក្រដាំ) | ថ្ងៃទី ១៤ |
| ៥ | • រៀបចំទ្រើង ខ្សែចងដើម និង ការថែទាំ<br>• កាត់តែងមែកផ្កា កាត់ខ្នែង និងផ្កាក្លិបដែលមិនត្រូវការ និងការរុំដើមឱ្យតោងខ្សែទ្រើង ។ (ចាប់ពី១២ថ្ងៃ បន្ទាប់ពីដាំ ហើយបន្តកាត់ត្រួយខ្នែង/ផ្កា រហូតដល់ពេលប្រមូលផល)<br>• ប្រើប្រាស់ជីកំប៉ុស្ដិ៍ទឹកជំនួយដើមស្លឹក ចាប់ពីក្រោយដាំបាន ៧ ថ្ងៃ (៥ ថ្ងៃម្ដង) ដើម្បីឱ្យដើមលូតលាស់បានល្អ រហូតដល់ទុកបានក្លិប ទើបប្ដូរទៅប្រើប្រាស់ ជីទឹកជំនួយផ្លែវិញ | ថ្ងៃទី ១៤ ដល់ ថ្ងៃទី ៧៥ |
| ៦ | • រើសបំរុងក្លិបកាន់ផ្លែ (ចំនួន ៣ នៅថ្នាំងពីទី ៨ ដល់ ១៣)<br>• កាត់ត្រួយខ្នែងដែលទុកក្លិប និងតាមដានសត្វល្អិតចង្រៃ ជម្ងឺ និង ការវិវឌ្ឍន៍របស់ដំណាំ | ថ្ងៃទី ៤៥ (៣០ថ្ងៃបន្ទាប់ពីដាំ) |
| ៧ | • ជ្រើសរើសយកក្លិប ១ ទុកឱ្យធំយកផ្លែ (ចន្លោះពី ៣០ ទៅ ៤៥ ថ្ងៃ បន្ទាប់ពីដាំកូន)<br>• ចងយួរបន្ថោងផ្លែ ឱ្យផុតពីដី (✽ មិនត្រូវទាញខ្នែងមានក្លិបខ្លាំងពេក ប្រយ័ត្នកាច់ត្រចខ្នែងផ្លែ) | ថ្ងៃទី ៤៥ ដល់ថ្ងៃទី ៦០ |
| ៨ | • ក្រៀកត្រួយដើមមេ បន្ទាប់ពីចេញផុតស្លឹកទី ២៣ ដល់ ២៥ ។ | ថ្ងៃទី ៦០ |
| ៩ | • ថែទាំដើម ផ្លែ និង ស្រោចទឹក។<br>• ស្រោចទឹក រៀងរាល់ ២ថ្ងៃម្ដង និងជីកំប៉ុស្ដិ៍ទឹកជំនួយផ្លែផ្អែម រៀងរាល់ ៥-៧ ថ្ងៃម្ដង។ | ថ្ងៃទី៤៥ ដល់ថ្ងៃទី៧៥ |
| ១០ | • ដំណាក់កាលទុំ ។ ជាទូទៅវាអាចចាប់ផ្ដើមទុំចាប់ពីអាយុកាល ៦០ ថ្ងៃ បន្ទាប់ពីដាំកូន អាស្រ័យលើលក្ខខណ្ឌអាកាសធាតុ (រដូវប្រាំង ក្ដៅ ឆាប់ទុំ)។ | ថ្ងៃទី ៧០ ដល់ថ្ងៃទី៨០ |
| ១១ | • ប្រមូលផល ។ ការថែទាំ ដើមឱ្យនៅរស់រហូតដល់ដំណាក់កាលប្រមូលផល។<br>• ប្រមូលផលបណ្ដើរៗ តែផ្លែទុំល្អ និង រើសផ្លែធំស្មើ វេចខ្ចប់ដាក់កេះ/ឡាំង សម្រាប់លក់ | ថ្ងៃទី ៧០ - ៨០ (អាស្រ័យតាមពូជ) |

## ខ. តម្រូវការទូទៅ និង រដូវកាលដាំដុះ

ត្រសក់ផ្អែម ត្រូវការពន្លឺថ្ងៃ ហើយងាយនឹងរងការបំផ្លាញពីជម្ងឺ និងសត្វល្អិត។ ត្រសក់នេះងាយរងជម្ងឺផ្សិត និងសត្វល្អិតបំផ្លាញជាងដំណាំក្នុងអំបូរវា (ដូចជា ត្រសក់ ឪឡឹក ត្រឡាច) ដូច្នេះ មិនត្រូវដាំវាជាប់កៀេរ ក្រោមខ្យល់ដំណាំទាំងនេះ ឬ ដំណាំស្ថែខាត់ណាឡើយ។ ជាទូទៅត្រសក់ផ្អែម តែងជួបប្រទះ ជម្ងឺ និងការបំផ្លាញពីសត្វល្អិត ប៉ុន្តែការបំផ្លាញ អាចជះផលប៉ះពាល់អាក្រក់ខ្លាំងដល់ផលត្រសក់ដោយសារតែដំណាំនេះ ទុកតែមួយផ្លែ។ បើជម្ងឺ ឬ សត្វល្អិតធ្វើឱ្យខូចខាតដល់មួយដើម គឺ បាត់ផល ១ដើម តែម្ដង។ ដូច្នេះ វិធានការបង្ការការពារ (ការរើសទីតាំងចំការ ការថែទាំកូន និង ការសំអាត អនាម័យចំការ) អាចរួមចំណែកកាត់បន្ថយការខូចខាត។ ការថែទាំ និងពិនិត្យតាមដានដំណាំ ជាប្រចាំ គឺជាការចាំបាច់។

រដូវដាំដុះដែលល្អបំផុត សម្រាប់ដំណាំនេះ នៅកម្ពុជា គឺ រដូវប្រាំង បន្ទាប់ពីភ្លៀងចាប់ផ្ដើមអស់ និងទឹកស្រកចុះ ទៅតាមទីតាំងចំការ (ដីទួល ឬ ដីស្រែ)។ ពេលសមស្របខ្លាំង សម្រាប់ចាប់ផ្ដើមដាំ គឺ ពីខែធ្នូ ដល់ ខែកុម្ភៈ។ ដីស្រែមានល្បាយខ្សាច់ ផ្ដល់ផ្លែតូច តែស្រួយ និង ផ្អែមជាង ដីល្បាប់កណ្ដេង។ ដើម្បីដាំដំណាំនេះ ឱ្យបានផល និង គុណភាពល្អ កសិករត្រូវការជីកំប៉ុស្ដិ៍ ៣ ប្រភេទ គឺ កំប៉ុស្ដិ៍គោក កំប៉ុស្ដិ៍ទឹកបំប៉នស្លឹកដើម និង កំប៉ុស្ដិ៍ទឹកជំនួយផ្លែឱ្យផ្អែម។ របៀបធ្វើ និង ប្រើជីទាំងនេះ មាននៅក្នុងខិត្តប័ណ្ណធ្វើជីកំប៉ុស្ដិ៍ និងសៀវភៅណែនាំបច្ចេកទេស ស្ដីពីដំណាំនេះ។

## គ.វិធីដាំ និង ថែទាំ

### គ.១. ការបណ្ដុះកូនត្រសក់

ថ្នាលបណ្ដុះកូន ត្រូវដាក់នៅកន្លែង ដែលមានកំដៅថ្ងៃល្អ។ គេអាចប្រើដីបណ្ដុះកូនលាយស្រាប់ ដែលអាចទិញបានពីផ្សារ ឬ រៀបចំដីបណ្ដុះកូន ដែលផ្សំ (ក្នុងបរិមាណស្មើគ្នា) ពី៖ ស្រកីដូងម៉ដ្ឋ ដីស្រទាប់លើ ដីកំប៉ុស្ដិ៍គោក និង ផេះធ្យូងអង្កាម ហើយចំអិនសំលាប់មេរោគបានល្អ។ ខាងក្រោម ជាវិធីបណ្ដុះកូនត្រសក់៖



- ដាស់ដំណេកគ្រាប់សិន ដោយដាក់គ្រាប់ត្រាំក្នុងទឹកក្ដៅអ៊ុនៗ
- យកដីខ្សាច់ លាងឱ្យស្អាត រួចដាក់ហាលថ្ងៃ ឬ លីងដីខ្សាច់ឱ្យបានស្ងួតល្អ រួចទុកមួយឡែក។



- ចាក់ទឹកក្ដៅ១កូនកែវ សម្រាប់ដីខ្សាច់ ១គីឡូ(ផ្សើមដីតិចៗ)។
- ដាក់ក្រណាត់ដែលមានពង្រាយគ្រាប់ត្រសក់ នៅលើដីខ្សាច់នោះ រួចខ្ចប់រុំក្រណាត់ឱ្យជិតល្អ ហើយដាក់ដីខ្សាច់គ្របពីលើផ្អាប់ក្នុងធុងទឹកកក ដែលដាក់ហាលថ្ងៃរយៈពេល ២៤ ម៉ោង ទើបយកគ្រាប់ចេញពន្លក ទៅដាក់លើថាសបណ្ដុះកូន។
- ដាក់ថាសបណ្ដុះ ក្នុងរោងបណ្ដុះកូន ហើយដាក់ឱ្យត្រូវពន្លឺថ្ងៃ ស្រោចទឹកពេលព្រឹក មួយដង ក្នុងមួយថ្ងៃ ។




រោងបណ្ដុះកូន ធ្វើពីសំណាញ់ល្អិត (ពណ៌ស ដោយសារ វា មិនសូវទាក់ទាញសត្វល្អិត)។ ផ្ទៃដី ៣ អារ ត្រូវការកូនពី ៧០០ ទៅ ៨០០ដើម បណ្ដុះក្នុងរោងទំហំ ១,៥ម៉ែត្រ x ២ម៉ែត្រ កំពស់ ១,៥ ម៉ែត្រ។ រោងបណ្ដុះកូន ត្រូវធ្វើផុតពីដី ហើយឱ្យអាចចល័តផ្លាស់ប្ដូរទីតាំងបាន ដើម្បីផ្ដល់លក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់ (ពង្រឹងកូន ដោយវាឱ្យត្រូវពន្លឺថ្ងៃខ្លាំង និង បន្ថយស្រោចទឹក ២ថ្ងៃ មុនដាំ) និង បង្ការពីការយាយីពីសត្វល្អិត ដល់កូនត្រសក់។ កូនត្រសក់ អាចយកទៅដាំបាន ពេលវាមានអាយុពី១០ ទៅ ១២ថ្ងៃ។

### គ.២. ការរៀបចំរងសម្រាប់ដាំកូន

ការរៀបចំរងដាំ ចាប់ផ្ដើមពីការរៀបចំដី (ភ្ជួរហាលដី ១៥ថ្ងៃ មុនដាំកូន) និង រាស់បំបែកឱ្យបានល្អ មុននឹងលើករង។ ការលើករង ត្រូវដាក់ជីកប់រងទ្រាប់បាត និង រៀបចំដាក់ប្រព័ន្ធស្រោចស្រព ដោយដំណក់ទឹក (ខ្សែ៧) និង ស្រោចទឹកឱ្យជោគល្អ រួចគ្រប់រងនឹងកៅស៊ូគម្របរង យ៉ាងតិច ៧ថ្ងៃ មុនដាំ។

| វត្ថុធាតុ | កម្រិតប្រើ (គីឡូ) | ផ្ទៃដីរង (ម៉ែត្រការ៉េ) |
|---|---|---|
| ជីបារ៉ (ប្រភេទ 20-20-15) | ១,៥ | ១០០ |
| ដីកំប៉ុស្ដិ៍គោក | ពី ២០០ ទៅ ៣០០ | ១០០ |
| កំបោរស | ពី ៣ ទៅ ៤ | ១០០ |

លើករងកំពស់ពី ២ ទៅ ៤តឹក អាស្រ័យតាមរដូវ (ប្រាំង / វស្សា) និង ទីតាំងចំការ (រដូវវស្សា)។ បន្ទាប់ពីលើករងរួច ត្រូវស្រោចទឹកឱ្យជោគល្អ រួចគ្រប់រងនឹងកៅស៊ូគម្របរង យ៉ាងតិច ៧ថ្ងៃ មុនដាំ។ មុននឹងដាំ ត្រូវចោះថង់ប្លាស្ទិចគ្របរង តាមចន្លោះគុម្ពគំរូ។




ត្រូវដាំកូនត្រសក់ នៅពេលរសៀល ត្រជាក ។ ដើម្បីដាំកូន ឱ្យបានត្រឹមត្រូវ និង រហ័ស យើងត្រូវ ៖

- ដាក់រាយជីកំប៉ុស្ដិ៍សម្រាប់ទ្រាប់បាតរណ្ដៅកូន នៅលើរងក្បែរៗរណ្ដៅ ដែលទើបចោះកៅស៊ូគ្របរងរួច។
- កាយដីក្នុងរណ្ដៅចេញបន្តិច រួចកាយដីកំប៉ុស្ដិ៍ចូលបន្តិច ច្របល់ឱ្យសព្វ ហើយកាយដី វែកជារណ្ដៅ។
- ដកកូនចេញពីកន្ទោង/ថាសបណ្ដុះដោយថ្នមៗ រួចហើយដាក់កូនត្រសក់ចូលក្នុងរណ្ដៅរួចកាយដីកំប៉ុស្ដិ៍ លុបរណ្ដៅកប់ត្រឹមគល់ (ដីបណ្ដុះ) កូនត្រសក់ ។
- ស្រោចទឹកល្មម ដើម្បីឱ្យដីចូលកប់ជិតជុំវិញឫស បានល្អ ។



### គ.៣. វិធីចងចំណារទ្រើងត្រសក់

ប្រើខ្សែវេញចងក្រវាត់ ស្រាក់លើបង្គោលទ្រើង ជា ៣ជាន់ (ខ្សែខាងក្រោម ជាប់នឹងថងគម្របដី ខ្សែកណ្ដាល កំពស់ប្រហែល ១ ម៉ែត្រ និង ខ្សែទី ៣ កំពស់ប្រហែល ១,៥ ម៉ែត្រ ពីដី)។ ប្រើខ្សែនីឡុង អំបោះវេញតូច ចងប្រទាក់នឹងខ្សែបង្គោលទ្រើង ៣ជាន់ តាមដើមនីមួយៗ សម្រាប់ឱ្យដើមត្រសក់ តោងវាឡើង។



### គ.៤. ការតាក់តែងមែក

ត្រសក់ចាប់ចេញផ្កា តាំងពីគល់ធាងស្លឹកដំបូង ប៉ុន្តែគេត្រូវកាត់វាចេញ ដើម្បីឱ្យដើម និង ក្តិបទុកយកផ្លែ ថ្លោសល្អ និង លូតលាស់ឆាប់រហ័ស ។ ឧបករណ៍ដែលអាចប្រើកាត់ គឺ កន្ត្រៃ ដោយមានទឹកសាប៊ូ/អាល់កុល សម្រាប់សម្លាប់មេរោគ ។ ត្រូវចាំថា បន្ទាប់ពីកាត់ខ្នែងដើមនីមួយៗហើយ ត្រូវជ្រលក់កន្ត្រៃនឹងទឹកសាប៊ូ ឬ អាល់កុល ម្ដង។ ខ្នែង និងស្លឹកដែលកាត់ ត្រូវប្រមូលដាក់ថង់ប្លាស្ទិច ឬ ធុង យកទៅដុត ឬ កប់ចោល ឱ្យឆ្ងាយពីចំការ កុំឱ្យឆ្លងជម្ងឺ។ ស្លឹកខាងក្រោមៗ ពិសេស ស្លឹកជាប់នឹងប្លាស្ទិចគ្របដី ត្រូវកាត់ចោលឱ្យស្រឡះគល់ ដើម្បីកុំឱ្យចំលងជម្ងឺ ពីដី មកដើម និងទៅស្លឹកខាងលើៗ ហើយអាចឆ្លងរាលដាល ពេញដើមទាំងមូល។




ខ្នែងដែលត្រូវទុកយកក្តិប(ផ្លែ) គឺ ចាប់ពីខ្នែង ទី ៨ ដល់ ទី១២ ។ ហើយបន្ទាប់ពីក្តិបផ្លែ កាន់ហើយ គេត្រូវកាត់ (ក្រៀវ) ត្រួយខ្នែងទុកក្តិប ត្រឹមថ្នាំងទី២ (បន្ទាប់ពីថ្នាំងមានក្តិប) ចោល ដើម្បីឱ្យដើមចិញ្ចឹមក្តិប ដែលទុកយកផ្លែនោះ ឱ្យបានល្អ។




### គ.៥. ការចងផ្លែ

បន្ទាប់ពីសំរេចទុកផ្លែចុងក្រោយមួយហើយ ត្រូវកាត់ក្តិបផ្សេងទៀតចោល។ ចំពោះផ្លែដែលត្រូវទុកនោះ ត្រូវចងបន្តោងវានឹងខ្សែទ្រើង ដើម្បីជួយទប់ដើម និងការពារ កុំឱ្យវា ប៉ះនឹងដី ឬ កៅស៊ូគម្របដី ដែលអាចធ្វើឱ្យផ្លែរលួយ មានស្នាម ឬ ក្រិនគូច ឬសត្វល្អិតចោះ។



ការចងបន្តោងផ្លែ គឺ ប្រើខ្សែប៉ៃ ចងសម្លាប់មុខ (កុំឱ្យរអិលរូតរឹត) កណ្ដាង់ទងផ្លែ ដោយទុកចន្លោះឱ្យរលុង រវាងខ្សែ និង ទងផ្លែ។ គួរប្រើខ្សែប៉ៃ មានពណ៌មិនស្រស់ឆើត ដូចជា ពណ៌ខ្មៅ ទឹកប្រាក់/ប្រផេះ ឬ ពណ៌ស ដែលជាពណ៌មិនសូវទាក់ទាញសត្វល្អិត។

បន្ទាប់ពីទុកក្តិបយកផ្លែហើយ ត្រូវបន្តកាត់ខ្នែង ផ្កា និងក្តិប ដែលមិនត្រូវការចោល។ ពេលត្រសក់ចេញផុតស្លឹកទី ២៤ ហើយ ត្រូវក្រៀវត្រួយដើមមេ ចោល។ ការកាត់ត្រួយ ខ្នែង និង ផ្កា ដែលមិនត្រូវការចោល ក្រៅពីជួយសន្សំដី និងសារធាតុចិញ្ចឹមសម្រាប់ផ្លែ វាក៏អាចជួយកាត់បន្ថយសត្វល្អិតបំផ្លាញដើមត្រសក់។ ហើយអាចជួយលាងសំអាតប្រព័ន្ធទុយោស្រោចដំណក់ទឹក ដែរ។ ការស្រោចជីកំប៉ុស្តិ៍ទឹកជំនួយដើមស្លឹក ធ្វើឡើង បន្ទាប់ពីដាំកូនបាន ៧ថ្ងៃ រហូតដល់បានត្រសក់មានអាយុ ៤៥ ថ្ងៃ (ក្រោយដាំកូន) ឬ រហូតដល់ការទុកក្តិបល្អ មួយ (សម្រាប់យកផ្លែធំ)។

## ឃ. ការប្រមូលផល

ជាទូទៅ ផ្លែត្រសក់អាចទុំពីអាយុ ៦៥ថ្ងៃ ឬ ៧៥ថ្ងៃ បន្ទាប់ពីដាំកូន (តាមពូជ K2122 ឬ T778)។ ដើម្បី ឱ្យផ្លែមានរសជាតិផ្អែមល្អ គួរផ្ដាច់ទឹក(ឈប់ស្រោច) មុនពេលបេះ យ៉ាងតិច ២ថ្ងៃ ។ ប៉ុន្តែ បើផ្ដាច់ទឹក មុនយូរពេក អាចធ្វើឱ្យដើមស្វិត ហើយប៉ះពាល់ដល់ផ្លែ ។ គេអាចសំគាល់ផ្លែត្រសក់ទុំ សម្រាប់ពូជសំបករលោង (K2122) ដោយសំបកខាងក្រៅវា ឡើងរលោង ពណ៌ស លាយលឿងព្រឿងៗ។



# បច្ចេកទេសចិញ្ចឹមកង្កែបក្នុងអាង





## សេចក្តីផ្តើម

ការចិញ្ចឹមកង្កែបក្នុងអាង ជារបៀបចិញ្ចឹមថ្មីមួយ ដែលងាយស្រួលក្នុងការថែទាំ គ្រប់គ្រង។ ការចិញ្ចឹមកង្កែបក្នុងអាង មិនសូវត្រូវការទីកន្លែងធំ និង ទឹកច្រើនទេ ដូច្នេះវាមានសមស្រមសម្រាប់អ្នកចង់ចិញ្ចឹម ដែលមានដីតូច និង គ្រាន់តែមានទឹកអណ្តូងមួយ ឬ ស្រះទឹក តូចល្មមមួយ ប៉ុណ្ណោះ។ ម្យ៉ាងទៀត ការចិញ្ចឹមកង្កែបបែបនេះ ប្រើប្រាស់រយៈពេលខ្លី គឺ ពី ២ខែកន្លះ ទៅ៣ ខែ យ៉ាងយូរ ដែលជាហេតុ ធ្វើឱ្យអ្នកចិញ្ចឹម មានលទ្ធភាពចំណេញច្រើន បើសិនជាគាត់អនុវត្តបាន ត្រឹមត្រូវតាមបច្ចេកទេស និងឧស្សាហ៍ព្យាយាម។

ជាទូទៅ ការចិញ្ចឹមកង្កែប អាចប្រើចំណីគ្រាប់ ក៏បាន ឬ កូនត្រីល្អិតៗ ក៏បាន តាមលទ្ធភាពដែលអាចរកបាន ។ ពូជកង្កែប ដែលយកមកចិញ្ចឹម ទទួលបានលទ្ធផលល្អ គឺជា កូនកង្កែប ដែលបានពីការបង្កាត់ ពីព្រោះវាមានភាពស៊ាំទៅ នឹងមជ្ឈដ្ឋានក្នុងអាងចិញ្ចឹម និង ចំណីផ្សំដែលផ្តល់ស៊ី។

## គុណសម្បត្តិនៃការចិញ្ចឹមកង្កែប

✧ ប្រើកន្លែងតូច តែបានទិន្នផលខ្ពស់។
✧ អាចផលិត/ចិញ្ចឹមបានច្រើនដង ក្នុងមួយឆ្នាំ។
✧ ការចិញ្ចឹមកង្កែបក្នុងអាង មានលក្ខណៈសមស្រម សម្រាប់កសិករដែលមិនសូវមានដីធំ ហើយសមស្របសម្រាប់ស្ត្រីទៀតផង។



## តើត្រូវការបច្ចេកទេសអ្វីខ្លះដើម្បីទទួលបានជោគជ័យ ?

### ១. ការជ្រើសរើសទីតាំងសម្រាប់សាងសង់អាង



✧ ជិតលំនៅដ្ឋាន
✧ មិនលិចទឹក នៅរដូវវស្សា
✧ កន្លែងដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និង មានប្រភពទឹកស្អាត នៅជិត។

### ២. ការសាងសង់អាង

<u>*២-១ ប្រភេទអាង:*</u> អាងចិញ្ចឹមកង្កែបអាចធ្វើពីស៊ីម៉ង់ ឬ តង់





<u>*២-២ បាតអាង:*</u>

➢ បាតអាងចិញ្ចឹមកង្កែប ត្រូវធ្វើឱ្យរាបស្មើ ហើយរលោង ដើម្បីបន្ថយភាពកកិត ដែលអាចធ្វើឱ្យកង្កែបរលាក របាត់ស្បែក ដែលជាហេតុងាយឆ្លងនូវជម្ងឺ ។
➢ បាតអាងចិញ្ចឹមកង្កែប ត្រូវធ្វើឱ្យមានជម្រេលបន្តិច ដែលអាចឱ្យទឹក ងាយស្រួលហូរចេញអស់ពីអាង នៅពេលយើងលាងសំអាតបាតអាង ម្តងៗ។





រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD - TA 7305-CAM)

### ២-៣ ប្រព័ន្ធបញ្ចេញ-បញ្ចូលទឹក

- បំពង់បង្ហូរទឹកចេញ គួរប្រើបំពង់ទីបជ័រ ដែលមានទំហំ (មុខកាត់) ពី ៤០ ទៅ ៦០ មីលីម៉ែត្រ ។
- បំពង់បង្ហូរទឹកចេញ ត្រូវដាក់ត្រង់កន្លែងដែលទាបជាងគេ (នៃបាតអាង) ដើម្បីឱ្យអាចបង្ហូរទឹកអស់។
- បំពង់បង្ហូរទឹកចូលអាចប្រើបំពង់ជ័រ (ទីប) ហើយ បើបានរៀបជាប់(នឹងអាង)អចិន្ត្រៃយ៍ រឹតតែល្អ ពីព្រោះវាចំណេញពេលវេលា និង កំលាំងពលកម្ម ក្នុងការផ្លាស់ប្ដូរទឹក។
- បំពង់បង្ហូរទឹកចូលត្រូវដាក់ខ្ពស់ជាងមាត់អាងបន្តិចនិងដាក់ត្រង់កន្លែង ដែលមានបាតខ្ពស់ជាងគេ។




### ២-៤ ដំបូល

- ដំបូលអាងចិញ្ចឹមកង្កែប គួរធ្វើអំពីស្បែម្លប់ដើម្បីកាត់បន្ថយកំដៅថ្ងៃ។ ស្បែម្លប់ វាមានលក្ខណៈល្អត្រង់ថាវា អាចទប់កំដៅ មិនឱ្យក្ដៅខ្លាំងពេក និង ត្រជាក់ពេក។
- ដំបូល មិនគួរធ្វើទាបពេកទេ ពីព្រោះធ្វើឱ្យកង្កែបក្ដៅខ្លាំង ។ កំពស់សមស្រប គឺ ប្រហែល ២ម៉ែត្រ។




## ៣. បច្ចេកទេសចិញ្ចឹមក្នុងអាងស៊ីម៉ង់ត៍ ឬ អាងតង់

- ទំហំអាងសមស្រប គឺពី ២ ទៅ ៥០ ម៉ែត្រការ៉េ (បាត)
- កំពស់អាង ៨០ សង់ទីម៉ែត្រ (៨តឹក) ទៅ ១ម៉ែត្រ
- បាតអាង ត្រូវធ្វើឱ្យមានផ្ទៃរលោង និង ជម្រាលទៅម្ខាង។
- កំពស់ទឹកក្នុងអាង មាន ពី ២ ទៅ ៥ សង់ទីម៉ែត្រ ។
- ប្រក់ដំបូលដោយស្បៃម្លប់ ឬ ស្បៃកាត់បន្ថយកំដៅថ្ងៃ។
- ដង់ស៊ីតេ (ចំនួនក្បាល) ដាក់ចិញ្ចឹមមាន ពី ៨០ ទៅ ១០០ ក្បាល ក្នុងផ្ទៃបាតអាងមួយម៉ែត្រការ៉េ ។
- ត្រូវឧស្សាហ៍ពិនិត្យមើលចាប់កូនកង្កែបណាដែលធំ ទៅដាក់ចិញ្ចឹមក្នុងអាងផ្សេង ដើម្បីកាត់បន្ថយការស៊ីគ្នា ។
- ប្ដូរទឹករៀងរាល់មុនការឱ្យចំណី គឺ នៅពេលព្រឹក និង ពេលល្ងាច




## ៤. ប្រភេទចំណី និង របៀបប្រើចំណី

### ៤-១ ប្រភេទចំណី

- *ចំណីស្រស់:* ត្រីល្អិតគ្រប់ប្រភេទ សាច់គ្រុំ សាច់ខ្យង កូនក្ដាម សត្វល្អិត ជន្លេន កាកសំណល់កែច្នៃមាន់ ទា...។




- *ចំណីផ្សំ:* គឺជាចំណី ដែលផ្សំបញ្ចូលគ្នានូវសមាសធាតុ (វត្ថុធាតុផ្សំ) ច្រើនមុខ ដូចជា ម្សៅត្រី ឬ ត្រីល្អិតៗ សណ្ដែកសៀង កន្ទក់ពោតក្រហម អំបិល...។ អាចជាចំណីគ្រាប់ស្រាប់ ឬ ចំណីស្ងោរ ។




### ៤-២ របៀបប្រើចំណី

| ទំហំគ្រាប់ចំណី | កម្រិតប្រូតេអ៊ីន (%) | ដំណាក់កាល (អាយុ) | កម្រិតផ្ដល់ និង ការផ្ដល់ |
|---|---|---|---|
| ១ (ម.ម) | ៣៥% | ១៥ ថ្ងៃដំបូង | ៧ ទៅ ១០% នៃទម្ងន់ខ្លួនសរុប ផ្ដល់ពី ៤ ទៅ ៦ដង |
| ២ ទៅ ២,៥ ម.ម | ៣០% | ៣០ថ្ងៃ បន្ទាប់មកទៀត | ៥ ទៅ ៧% នៃទម្ងន់ខ្លួនសរុប ផ្ដល់ពី ៤ ទៅ ៦ដង |
| ៣ ទៅ ៥ ម.ម | ២៥% | ៣០ថ្ងៃ បន្ទាប់មកទៀត | ៣ ទៅ ៥% នៃទម្ងន់ខ្លួនសរុប ផ្ដល់ពី ២ ទៅ ៤ដង |
| ៨ ទៅ ១០ ម.ម | ២២% | លើសពី៧៥ថ្ងៃ ឡើងទៅ | ៣ ទៅ ៥% នៃទម្ងន់ខ្លួនសរុប ផ្ដល់ពី ២ ទៅ ៣ដង |

## ៥.ប្រភេទថ្នាំពេទ្យ សម្រាប់ព្យាបាល

### ក). ជម្ងឺហើមពោះ

ប្រើ Metronidazle ចំនួនពី ២ ទៅ ៣ក្រាម សម្រាប់ចំណី ១ គីឡូក្រាម ដាក់ឱ្យកង្កែបស៊ី ពី៣ ទៅ ៥ថ្ងៃ។

ឬ ប្រើ Sulphadiazin ចំនួន ពី៤ ទៅ ៥ក្រាម សម្រាប់ចំណី ១គីឡូក្រាម ឱ្យស៊ី ពី៣ ទៅ ៥ ថ្ងៃ។

### ខ). ជម្ងឺរលាកស្បែក

ប្រើ Oxytetracycline ចំនួន ពី២ ទៅ ៣ក្រាម សម្រាប់ចំណី ១គីឡូក្រាម ដាក់ឱ្យកង្កែបស៊ី ពី ៣ ទៅ ៥ថ្ងៃ។

ឬ ប្រើ Norfloxaxine ចំនួន ៥ក្រាម សម្រាប់ចំណី ១គីឡូក្រាម ដាក់ឱ្យកង្កែបស៊ី ពី៣ ទៅ ៥ថ្ងៃ ។

*រៀបចំដោយ: គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD - TA 7305-CAM)*

# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**តពីលេខ ៤៦**

*ដោយៈ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល*

## ៧. ការថែទាំ កូនផ្តាច់ដោះ ជ្រូកជំទង់ និងជ្រូកសាច់

ការផ្តាច់ដោះគឺជាការបំបែកកូនចេញពីមេ ។ នៅពេលកូនជ្រូកមានអាយុ ៣សប្តាហ៍ មេជ្រូកមិនអាចផលិតទឹកដោះឲ្យបានគ្រប់គ្រាន់សម្រាប់កូនរបស់វាបៅទេ ជាពិសេសនៅពេលបរិមាណកូនជ្រូកមានពី ៨-៩ក្បាល ក្នុងមួយសំបុក ។ដូចនេះ ត្រូវបង្ហាត់កូនជ្រូក ឲ្យចេះស៊ីចំណីនៅពេលដែលវាមានអាយុចាប់ពី ៧-១០ថ្ងៃ ។

ត្រូវផ្តល់ចំណីដែលមានប្រូតេអ៊ីនខ្ពស់ ២២% ដោយកិនឲ្យម៉ដ្ឋ ។ យកល្អគួរផ្តាច់ដោះនៅពេលដែលកូន មានអាយុ ២៨ថ្ងៃ និងមានទម្ងន់ ៨គក្រ ។



*ដាក់ចំណីបន្ថែមដល់កូនជ្រូក ក្នុងបរិមាណតិចតួច*

### ១. ការផ្តាច់ដោះ

ចំណុចសំខាន់នៃការផ្តាច់ដោះគឺ ៖

- កូនជ្រូកមានអាយុ ៤សប្តាហ៍
- មានសុខភាពល្អ
- ផ្តាច់ដោះកូនជ្រូកទាំងអស់ក្នុងសំបុក ពេលតែមួយ
- យកមេចេញពីទ្រុងបង្កើតកូន
- ចាប់កូនជ្រូកយកទៅដាក់ក្នុងទ្រុងដែលសមស្រប
- មិនត្រូវដាក់កូនជ្រូកទាំងតូច ទាំងធំ នៅលាយឡំគ្នាឡើយ ។

#### ១.១. ការរៀបចំទ្រុងផ្តាច់ដោះ

ប្រសិនបើអាច ត្រូវធ្វើឲ្យឆ្ងាយពីគេ ដើម្បីចៀសវាងកុំឲ្យឆ្លងមេរោគ ព្រោះកូនជ្រូកលែងទទួលភាពស៊ាំពីមេហើយប្រព័ន្ធការពារជំងឺរបស់វានៅខ្សោយ មិនអាចទប់ទល់នឹងមេរោគបាន ។

ទ្រុងកូនផ្តាច់ដោះ គួរសង់ខ្ពស់ផុតពីដីប្រហែល(០.៥-១ម) កម្រាលជាបន្ទះឬស្សី ឬឈើតូចៗ ឬដែក ដើម្បីកុំឲ្យទ្រុងសើម ដោយសារលាមករបស់វាមិនជាប់នៅលើកម្រាល មានខ្យល់ចេញចូលបានល្អ និងកាត់បន្ថយ ការចម្លងមេរោគ ធ្វើឲ្យឆ្ងាយពីគេ ដើម្បីចៀសវាងកុំឆ្លងមេរោគ ព្រោះកូនជ្រូកលែងទទួលភាពស៊ាំពីមេ ហើយប្រព័ន្ធការពារជំងឺរបស់វានៅខ្សោយ មិនអាចទប់ទល់នឹងមេរោគបាន ។

ទ្រុងដែលមានកម្រាលស៊ីម៉ងត៍ ជាកន្លែងស្នាក់នៅរបស់ពពួកបាក់តេរី ។ ជាពិសេសទ្រុងគគ្រើមពេក បណ្តាលឲ្យពួកមេរោគលាក់ខ្លួនចេញពីការបោសសំអាតបាន ដូចនេះត្រូវធ្វើការបោសសំអាតជាប្រចាំ និងត្រូវបាញ់ថ្នាំសម្លាប់មេរោគឲ្យបានញឹកញាប់ ។

យកល្អគួរមានទ្រុងផ្តាច់ដោះពីរ ព្រោះងាយស្រួលបំបែកកូនជ្រូកទៅតាមមាឌរបស់វា ។ ពេលផ្តាច់ដោះ ដំបូងចាំបាច់ត្រូវការពារកុំឲ្យកូនជ្រូកត្រូវខ្យល់ខ្លាំង ។ ទីធ្លាទូលាយកន្លែងរស់នៅកក់ក្តៅ ចំណី និងទឹកមានគុណភាពល្អ ត្រូវមានគ្រប់ពេល នៅពេលដែលកូនជ្រូកត្រូវការ ។ ត្រូវតាមសង្កេតដោយយកចិត្តទុកដាក់ និងព្យាបាលភ្លាមៗចំពោះកូនជ្រូកណាមួយដែលមានបញ្ហា ។

#### ១.២. ក្រោយពេលផ្តាច់ដោះ

មុននឹងបំបែកទៅដាក់ទ្រុងថ្មី ត្រូវទុកកូនដែលទើបផ្ដាច់ដោះឲ្យនៅក្នុងទ្រុងចាស់ ១សប្ដាហ៍សិន ។ ដោយគ្មានការថៃទាំពីមេ បើសិនជាប្ដូរទៅនៅទ្រុងថ្មីភ្លាម អាចបណ្ដាលឲ្យកូនជ្រូកត្រេសខ្លាំងឡើង ជាហេតុធ្វើឲ្យកូនជ្រូកងាយទទួលជំងឺ ។

កូនជ្រូកត្រូវរស់នៅជាមួយជ្រូកផ្សេង ឬបំបែកចេញពីគ្នាទៅតាមមាឌ ជាហេតុធ្វើឲ្យពួកវាភ័យខ្លាច និងខាំគ្នា។ ត្រូវផ្ដល់កំដៅដល់ពួកវា ព្រោះវាលែងបានទទួលកំដៅពីមេទៀតហើយ ។


ទ្រុងធំ និងសើម មិនល្អសម្រាប់កូនជ្រូកទើបផ្ដាច់ដោះ


ទ្រុងត្រូវតែស្អាត និងស្ងួត


បន្ទាប់ពីផ្ដាច់ដោះជ្រូកខាំគ្នា


ស្នាកស្នាមក្រោយពេលខាំគ្នា


កូនជ្រូករងារ និងស្រកទម្ងន់


កូនជ្រូកមានភាពកក់ក្ដៅ ក្រោមកំដៅ

### ១.៣.ការផ្ដល់ទឹក និងចំណីដល់កូនជ្រូកផ្ដាច់ដោះ

កូនជ្រូកតូចៗលូតលាស់លឿនណាស់ ប្រសិនបើការថែទាំបានល្អ ផ្ដល់ចំណី និងទឹកបានគ្រប់គ្រាន់ ។

#### ការផ្ដល់ទឹក

- ត្រូវឲ្យកូនជ្រូកផឹកទឹកបានគ្រប់គ្រាន់ ពិសេសក្បាលបឺត មិនត្រូវដាក់ខ្ពស់ពេកទេ
- ក្នុងទឹកអាចមានមេរោគជាច្រើនដូចជា អ៊ីកូលី ស្ដាហ្វីឡូកុកគូស ជាដើម ។ ដូច្នេះដើម្បីការពារ កុំឲ្យកូនជ្រូករាគ ត្រូវលាយក្ល័រីន (Chlorine) ក្នុងទឹក ២-៣ក្រាម/១០០លីត្រ



កូនជ្រូកផឹកទឹកតាមក្បាលបឺត



ការផ្ដល់ទឹកមិនសមស្រប ខ្ជះខ្ជាយទឹក ទ្រុងសើម

#### ការផ្ដល់ចំណី

- ចាប់ផ្ដើមការផ្ដល់ចំណីលើកទី ១ ដល់កូនជ្រូកអាយុ ២៨ថ្ងៃ ពី ២០០-២៥០ក្រាម/ក្បាល/ថ្ងៃ
- បង្កើនរបបអាហារ ១០០ក្រាម/ក្បាល/ថ្ងៃ នៅអាទិត្យនីមួយៗបន្តបន្ទាប់
- នៅអាយុ ៨សប្ដាហ៍ ត្រូវផ្ដល់ចំណីពី ៦០០-៧០០ក្រាម/ក្បាល/ថ្ងៃ
- ក្រោយពេលផ្ដាច់ដោះកូនជ្រូកងាយនឹងទទួលមេរោគដូចជា អ៊ីកូលី (E.Coli) (បង្កឲ្យរាគ) មីកូប្លាស្មា (Mycoplasma) បង្កឲ្យក្អក ដូច្នេះក្រោយពេលផ្ដាច់ដោះភ្លាម ត្រូវលាយអង់ទីប៊ីយ៉ូទិក ក្នុងចំណីឲ្យកូនជ្រូកស៊ីរយៈពេល ១០ថ្ងៃ ដូចជា ៖
  - កូលីស្ទីន ជាមួយទីឡូស៊ីន (Colistin + Tylosin)
  - ហ្ល័រហ្វេនីកុល (Florfenicol)



ការលាយអង់ទីប៊ីយ៉ូទិកក្នុងចំណីកូនជ្រូក



ព្រូនធ្វើឲ្យកូនជ្រូកលូតលាស់យឺត និងខ្សោយ

- បើសិនជាមិនបានចាក់ថ្នាំអ៊ីវែម៉ិចទីន (Ivermectine) លើមេធើមមុនពេលកើតកូន ២សប្ដាហ៍ទេ នោះនៅពេលផ្ដាច់ដោះត្រូវតែចាក់ អ៊ីវែម៉ិចទីនដល់កូនជ្រូក
  - អ៊ីវែម៉ិចទីន ១% ប្រើ ០.២៥សេសេ/ក្បាល
  - អ៊ីវែម៉ិចទីន ០.២៥% ប្រើ ១សេសេ/ក្បាល

## ២. ជ្រូកជំនង់ និងជ្រូកសាច់

សំដៅចាប់ពីផ្ដាច់ដោះរហូតដល់ពេលលក់ ។ នៅពេលដែលកូនជ្រូកមានអាយុ ១២សប្ដាហ៍ ឬនៅពេលដែលវាមានទម្ងន់ ១៨-២០គក្រ ត្រូវបំបែកយកទៅដាក់ក្នុងទ្រុងជ្រូកសាច់ ។ ការបំបែកនេះបើធ្វើនៅពេល ជ្រូកនៅក្មេងពេក ឬទម្ងន់ស្រាលពេក អាចកាត់បន្ថយសមត្ថភាព និងលទ្ធភាពនៃការលូតលាស់របស់ជ្រូក ។

ទំហំទីធ្លា និងការផ្ដល់ចំណី មានសារៈសំខាន់ណាស់ ពិសេសនៅពេលដែលពួកវាកាន់តែធំ ។ ជ្រូក ដែលខ្សោយ និងតូច មិនអាចប្រជែងស៊ីជាមួយគេបាន ធ្វើឲ្យពួកវាស៊ីមិនបានគ្រប់គ្រាន់ នាំឲ្យវាកាន់តែតូចជាងគេ ។ ក្នុងទ្រុងនីមួយៗ យ៉ាងហោចណាស់ក៏មានក្បាលបឺតទឹកពីរដែរ និងមានទឹកគ្រប់ពេល ដោយត្រួតពិនិត្យ មើលទឹកជារៀងរាល់ថ្ងៃ ។

ក្នុងទ្រុង យកល្អគួរតែដាក់សីតុណ្ហមាត្រ ដើម្បីតាមដានសីតុណ្ហភាពក្នុងទ្រុង (២៥-២៨អង្សាសេ) ។





## ៨. ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ

ដើម្បីការពារជំងឺបាន គឺការរៀបចំកសិដ្ឋានឲ្យមានអនាម័យល្អ ។ ពោលគឺត្រូវសំអាតលាមកចេញពីទ្រុង ជារៀងរាល់ថ្ងៃ ។ការបោសសំអាតក្នុងទ្រុងជារៀងរាល់ថ្ងៃ ជួយកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺ ។ រាល់ពេលសំអាត គួរប្រើជាមួយថ្នាំសម្លាប់មេរោគ ដូចជាហ្វ័រម៉ាដែន ធីអេដ ៤ អ៊ីយ៉ូដាវិច បាយអូគ្លីន ។

ការសម្លាប់មេរោគ និងការធ្វើអនាម័យបានល្អ កាត់បន្ថយការីករាលដាលនៃជំងឺឆ្លងទាំងឡាយ ។ ម្យ៉ាងទៀតការដាក់ជ្រូកតាមប្រភេទ និងទម្ងន់ ក៏ជាវិធីមួយជួយកាត់បន្ថយការឆ្លងជំងឺ និងការរីករាលដាលនៃជំងឺ ផងដែរ ។

យកល្អគួរតែបំបែកកូនជ្រូកដែលតូច ឬខ្សោយជាងគេ ចេញពីកូនជ្រូកដែលមានមាឌធំ ឬខ្លាំងជាង ដើម្បីឲ្យកូនជ្រូកដែលមានមាឌតូច បានស៊ីចំណីគ្រប់គ្រាន់ ។

### ១. សកម្មភាពទូទៅ

- សំអាត និងបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ហើយផ្តល់ទឹក និងចំណីដែលមានគុណភាព ឲ្យបានគ្រប់គ្រាន់
- ទ្រុងត្រូវមានខ្យល់ចេញ ចូលបានល្អ (មិនត្រជាក់ពេក និងមិនក្តៅពេក)
- កម្រាលត្រូវស្ងួត និងមានអនាម័យ
- មិនត្រូវដាក់ជ្រូកក្នុងទ្រុងចង្អៀតពេក គួរដាក់តាមទម្ងន់ ប្រភេទ និងតាមអាយុ
- លុបបំបាត់ប្រភពបង្កើតមេរោគ ដូចជាលាមក ទឹកនោម កម្រាលរបស់ជ្រូកឈឺ និងជ្រូកស្លាប់
- បំបែកជ្រូកឈឺចេញពីជ្រូកជា ។ ឯជ្រូកស្លាប់ត្រូវយកទៅកប់ក្នុងរណ្ដៅជម្រៅយ៉ាងតិច ១ម៉ែត្រ
- ត្រួតពិនិត្យចរាចរសត្វចេញ និងចូលក្នុងភូមិ ។

### ២. ការការពារជំងឺដោយការដាក់ដោយឡែក

- មុននឹងដាក់បញ្ចូលជ្រូកថ្មីក្នុងហ្វូង ចាំបាច់ត្រូវបង្ខាំងទុកក្នុងទ្រុងមួយដោយឡែក រយៈពេលពី ២-៣សប្តាហ៍សិន ដោយផ្តល់ទឹក និងចំណីដល់ជ្រូកឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យប្រាកដថាជ្រូកថ្មីនោះមានជំងឺ ឬគ្មានជំងឺ ។

### ៣. ការណែនាំ

- មិនត្រូវប្រើវ៉ាក់សាំងដែលហួសថ្ងៃកំណត់ ត្រួតពិនិត្យមើលពណ៌របស់វ៉ាក់សាំង និងអានការណែនាំប្រើប្រាស់ឲ្យបានច្បាស់លាស់ ចៀសវាងការប្រើលើសកម្រិត ឬចាក់បញ្ចូលថ្នាំខុសទីតាំង អាចបណ្តាលឲ្យជ្រូកអាប់សែនៅកន្លែងចាក់ ។
- វ៉ាក់សាំងត្រូវរក្សាទុកក្នុងទូទឹកកក ក្នុងសីតុណ្ហភាព ២-៨ អង្សាសេ ។ ករណីបើកលាយហើយ គួរតែប្រើឲ្យអស់ក្នុងរយៈពេល ២-៣ម៉ោង ក្រោយពេលលាយ ហើយរក្សាទុកក្នុងធុងទឹកកក ជាប្រចាំ ។ តែបើវ៉ាក់សាំងងាប់ (វ៉ាក់សាំងមានលាយជាតិប្រេង) អាចរក្សាទុកបាន ១សប្តាហ៍។
- ត្រូវស្ងោរសឺរ៉ាំង និងម្ជុល ដើម្បីសម្លាប់មេរោគ ។
- សំបក ឬសំណល់ ក្រោយពេលប្រើរួចត្រូវកប់ឲ្យបានត្រឹមត្រូវ ចៀសវាងការចម្លងជំងឺ ។
- ត្រូវចាក់វ៉ាក់សាំងលើសត្វដែលមានសុខភាពល្អ ។

## ៩. ជំងឺដែលច្រើនកើតមានលើមេជ្រូក និងកូនជ្រូក

ដើម្បីធ្វើការព្យាបាលឲ្យមានប្រសិទ្ធិភាព សំខាន់បំផុតគឺការធ្វើរោគវិនិច្ឆ័យបានច្បាស់លាស់ បើសន្និដ្ឋាន រោគសញ្ញាមិនបានត្រឹមត្រូវ មុខជាប្រើថ្នាំខុស ព្រោះថ្នាំមានប្រសិទ្ធិភាពជាក់លាក់ផ្សេងៗគ្នា ។

រោគសញ្ញា គឺជាសញ្ញាដ៏ច្បាស់នៃជំងឺ ដែលបានលេចឡើងខុសធម្មតាលើខ្លួនសត្វ ។ ដូចនេះដើម្បីធ្វើ រោគវិនិច្ឆ័យបានច្បាស់លាស់ គួរអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម ៖

- ចូលឲ្យជិតសត្វ ពិនិត្យមើលលើដងខ្លួនទាំងមូលរបស់សត្វ (ក្បាល ត្រចៀក ច្រមុះ ការដកដង្ហើម ជើង មាត់ ... តើមានស្លាកស្នាមអ្វីដែរឬទេ ?
- សង្កេតមើលការក្រោក និងការផ្លាស់ទីរបស់សត្វ
- ត្រូវប្រើសីតុណ្ហមាត្រ សម្រាប់វាស់កំដៅសត្វ
- ពិនិត្យមើលការស៊ីចំណីរបស់សត្វ
- ពិនិត្យមើលស្បែក
- ពិនិត្យមើលភ្នែក
- ពិនិត្យមើលដុំពក
- ពិនិត្យមើលទ្វារធំ និងលាមក
- ពិនិត្យមើលផ្លូវបន្តពូជ និងទឹកនោម
- ពិនិត្យមើលកន្ទ្រាមដោះ
- ពិនិត្យមើលប្រព័ន្ធប្រសាទ

### ១. រលាកស្បែក

បណ្ដាលមកពីស្តាហ្វីឡូកុកគូស ។ កើតលើកូន ជ្រូកមិនទាន់ផ្ដាច់ដោះ ។

#### ១.១ រោគសញ្ញា



កូនជ្រូកមានខ្ទាញ់រដើមលើស្បែក

- ដំបូងចំណុចតូចៗពណ៌ត្នោតចាស់ ចាប់ផ្ដើមចេញពីផ្នែកមុខ ឬជើង
- បន្ទាប់មកប្រែទៅជាពណ៌ត្នោត ហើយរាលដាលបន្តិចម្ដងៗរហូតដល់ពេញខ្លួនទាំងមូល ។

#### ១.២. ការការពារ

- ចៀសវាងកម្រាលស្ងួតពេក
- លាងសំអាតដោះមេជ្រូកជាមួយអ៊ីយ៉ូឌីន ២ដង/ថ្ងៃ

#### ១.៣. ការព្យាបាល

- ការព្យាបាលគ្មានប្រសិទ្ធិភាព
- ការចាក់អាម៉ុកស៊ីលីន អិលអេ ឡាំងកូមីស៊ីន ដើម្បីការពារជំងឺឆ្លៀតឱកាស

### ២. ជំងឺក្រញ៉ិល

#### ២.១ រោគសញ្ញា

- ផ្ទាំងក្រហមធំៗនៅលើស្បែក ប្រែទៅជាខ្មៅ
- ជ្រូកស្លាប់យ៉ាងទាន់ហន់ (ករណីស្រួចស្រាវ
- កំដៅឡើងដល់ ៤១អង្សាសេ

#### ២.២. ការការពារ

- ចាក់វ៉ាក់សាំងការពារ នៅពេលជ្រូកមាន អាយុ ៣ខែ ។



ផ្ទាំងក្រហមលើស្បែក

#### ២.៣. ការព្យាបាល

- ចាក់ប៉េនីស៊ីលីន អាម៉ុកស៊ីលីន ពី ៣-៥ថ្ងៃ

## ៣. អង្គែ

បង្កឡើងដោយបរាសិតនៅលើស្បែក ។

### ៣.១. រោគសញ្ញា

- មានចំណុចក្រហមៗជាច្រើននៅលើស្បែកសំខាន់នៅត្រង់ខ្នង និងពោះ
- ជ្រូកនៅមិនសុខ និងត្រដុសច្រើន
- បក់ត្រចៀកចុះឡើង
- ប៉ះពាល់ដល់កំណើនទម្ងន់ប្រចាំថ្ងៃ ។



*ផ្ទាំងក្រហមលើស្បែក*

### ៣.២. ការការពារ

ព្យាបាលជ្រូករាល់ ២-៣ខែម្ដង ។

### ៣.៣. ការព្យាបាល

- ចាក់អ៊ីវ៉ឺមិច ១មល/៣០គក្រ ១ថ្ងៃចាក់ ២ដង រយៈពេល ១សប្ដាហ៍ ។



*រោគសញ្ញាអង្គែនៅត្រចៀក*



*ចាក់អ៊ីវ៉ឺមិចនៅក្រោមស្បែក*

## ៤. សត្វល្អិតខាំ

### ៤.១. រោគសញ្ញា

- មានស្នាមអុចៗក្រហម និងរលាត់តិចៗ លើស្បែក
- មានការបាត់បង់ឈាម និងការលូតលាស់ តិចតួច



*ស្នាមអុចបន្ទាប់ពីមូស/រុយខាំ*

### ៤.២. ការការពារ



*រុយ/មូស ខាំ រួមជាមួយការចម្លងជំងឺបន្ទាប់បន្សំ ដូចជាស្តាហ្វីឡូកុកគូស (Staphylococcus)*

- ប្រើថ្នាំបាញ់សម្លាប់សត្វល្អិត (ទ្រិចល័រហ្វុង) លើជម្រករុយ ព្យាបាលជ្រូក
- ថ្នាំប៉ុយតុកលើខ្លួនសត្វ រាល់ ២ខែម្ដង
- បើស្បែករលាត់ខ្លាំង ចាក់ថ្នាំ ដិចសាមេតាសូន
- បាញ់ថ្នាំប៉ុយតុកលើខ្លួនសត្វ រាល់ ២ខែម្ដង
- បើស្បែករលាត់ខ្លាំង ចាក់ថ្នាំ ដិចសាមេតាសូន ។

## ៥. ស្បែកក្រហមដោយកំដៅថ្ងៃ

### ៥.១. រោគសញ្ញា

- ស្បែកក្រហម
- ស្បែករលាក ហើយសើម
- ជ្រូកបង្ហាញការឈឺចាប់ និងនៅមិនសុខ។

### ៥.២. ការការពារ

- ត្រូវមានម្លប់នៅក្នុងទ្រុង ។

### ៥.៣. ការព្យាបាល

- បាញ់ទឹក
- មានទឹកគ្រប់គ្រាន់សម្រាប់ជ្រូកផឹក
- ចាក់ថ្នាំប៉ារ៉ាសេតាម៉ុល ។



ស្បែកក្រហមដោយសារកំដៅថ្ងៃ

## ៦. ជំងឺប៉េស្ត

ជាជំងឺបង្កឡើងដោយពួកវីរុស អាចកើតឡើងលើជ្រូកគ្រប់អាយុ និងបណ្ដាលឲ្យកូនជ្រូកស្លាប់ស្ទើរ ១០០% ។ ជំងឺនេះអាចកើតមានជាសណ្ឋានស្រួចស្រាវ (ជ្រូកអាចស្លាប់យ៉ាងរហ័ស) និងមិនស្រួចស្រាវ (ជ្រូកមិនស្លាប់ តែវាខ្សោយ លូតលាស់យឺត) ។

ជាទូទៅជំងឺប៉េស្តមិនស្រួចស្រាវ ច្រើនបណ្ដាលមកពីការចាក់វ៉ាក់សាំងមិនមានគុណភាព វ៉ាក់សាំងមិនបានថែរក្សាក្នុងធុងទឹកកកត្រឹមត្រូវ មិនបានអនុវត្តតាមកម្មវិធី ។

### ៦.១. រោគសញ្ញា

- កំដៅឡើងពី ៤០-៤១អង្សាសេ
- លាមករាគពណ៌លឿងប្រផេះ បន្ទាប់មកគៀនពណ៌ខ្មៅមូលតូចៗ
- ដំណើរទ្រេតទ្រោត ច្រើនអង្គុយចុះ នៅមិននឹង
- ស្បែកមានស្នាមអុចៗក្រហមនៅលើដងខ្លួន
- រលាកកែវភ្នែក ដោយមានហូរទឹកភ្នែក ឬឈាមចេញពីភ្នែក ។



### ៦.២. ការព្យាបាល

ជំងឺនេះគ្មានថ្នាំព្យាបាលទេ តែអាចប្រើអង់ទីប៊ីយ៉ូទិក ដូចជាអាម៉ុកស៊ីលីន អុកស៊ីតេត្រាស៊ីគ្លីន ជាដើម ហើយក៏ត្រូវប្រើថ្នាំបញ្ចុះកំដៅ និងវីតាមីនផងដែរ ដើម្បីឲ្យប្រព័ន្ធការពាររបស់ជ្រូកបានប្រសើរឡើង អាចទប់ទល់ នឹងជំងឺឱកាសនិយម ដូចជា មីកូប្លាស្មា សារទឹក ស្រ្ដិបតូកុកគុស ... ។



រលាកកែវភ្នែក និងឈាមហូរចេញពីភ្នែក

៦.៣. ការការពារ

ចាក់វ៉ាក់សាំងឲ្យកូនជ្រូកនៅអាយុ ៣ សប្តាហ៍ ៧ សប្តាហ៍ និង ១១សប្តាហ៍ រួចបន្ទាប់មករាល់ ៦ខែម្តង ។

## ៧. ជំងឺត្រចៀកខៀវ (PRRS)

ជំងឺនេះបង្កឡើងដោយវីរុស ដែលអាចកើតលើជ្រូកគ្រប់អាយុ ជាពិសេសបង្កលើមេជ្រូក និងជ្រូកបា ។ ចំពោះមេដើមអាចរលូតកូន ឯជ្រូកបាអសមត្ថភាព ។

៧.១. រោគសញ្ញាលើមេជ្រូក

- ត្រចៀកមានពណ៌ខៀវ
- មិនសូវស៊ីចំណី ១ ទៅ ២អាទិត្យ
- រលូតកូន។



៧.២. រោគសញ្ញាលើកូនជ្រូក

- រោគសញ្ញាមានការប្រែប្រួល
- ក្អកតិចៗ
- ពិបាកដកដង្ហើម
- ស្គម មានរោមច្រើន
- ខ្សោយ ធំមិនស្មើគ្នា ងាយទទួលជំងឺ ផ្សេងទៀត



ដូចជា សាល់ម៉ូណែលឡា (រាគខៀវ) និងមីកូប្លាស្មា (ក្អកខ្លាំង)

- ស្បែកក្រហម រោមបាស់
- មិនស៊ីចំណី និងអស់កម្លាំង
- លូតលាស់យឺត សភាពដងខ្លួនមិនល្អ
- រលាកស្រោមសួត ហើមកូនកណ្តុរ ។

៧.៣.ការព្យាបាល

- គ្មានការព្យាបាលទេ
- តែអាចប្រើអង់ទីប៊ីយ៉ូទិក អង់រ៉ូហ្លុកសាក់ស៊ីន ដើម្បីប្រឆាំងនឹងបាក់តេរី សាល់ម៉ូណែលឡា ប៉ាស្ទ័ររ៉ែលឡា និងមីកូប្លាស្មា
- ត្រូវចាំថាម្ចូលគឺជាអ្នកចម្លងវីរុស ។

៧.៤.ការការពារ

- លាយម្សៅហ្វ័រហ្វេនីកុល ក្នុងចំណីឲ្យកូនជ្រូក ២ សប្តាហ៍ (មុនផ្តាច់ដោះ ១សប្តាហ៍ និងក្រោយផ្តាច់ដោះ ១សប្តាហ៍)

## ៨. ជំងឺក្អក

បណ្តាលមកពីមេរោគមីកូប្លាស្មា (Mycoplasma) ដែលកើតឡើងលើកូនជ្រូកទើបផ្តាច់ដោះ ។ មេរោគ នេះបង្កជាបញ្ហាដល់សួត ហើយកូនជ្រូកនឹងក្អកនៅពេលវាមានអាយុពី ១០-១២សប្តាហ៍ ។

៨.១. ការព្យាបាល

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ហ្វ័រហ្វេនីកុល (Florfenicol) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine)
- ប្រើរយៈពេល៥ថ្ងៃ ដោយថ្ងៃទី១ ចាក់កម្រិតទ្វេដង

៨.២. ការការពារ

- នៅពេលឃើញជ្រូកទម្ងន់ ២០-៤០គក្រ មានបញ្ហាក្អក ចាំបាច់ត្រូវលាយអង់ទីប៊ីយ៉ូទិកក្នុងចំណី
- អង់ទីប៊ីយ៉ូទិកដូចជាហ្វ័រហ្វេនីកុល (Florfenicol) ឬ ទីឡូស៊ីន (Tylosin) ឬអុកស៊ីតេត្រាស៊ីគ្លីន (Oxy-tetracycline) លាយក្នុងចំណីឲ្យកូនជ្រូកផ្តាច់ដោះស៊ីរយៈពេល ១០ថ្ងៃ ។

សូមរង់ចាំអានវគ្គបញ្ចប់នៅលេខ៤៨

# បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

តពីលេខ ៤៦

ដោយៈ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

នៅជុំវិញទ្រុង ជាការល្អត្រូវដាំដើមកន្ទំថេត ដើមងប់ ត្រកួន ដំឡូងឈើ ដើម្បីផ្ដល់ជាអាហារបន្ថែមដ៏ល្អសម្រាប់មាន់។

### ៣.២. ទ្រនំ ឬ ធ្នើរសម្រាប់មាន់ដេក

- ទ្រនំងាយស្រួលប្រមូលលាមកធ្វើជី និងងាយស្រួលសម្អាត
- ទ្រនំត្រូវទាបជាងសំបុក
- ចន្លោះធ្នើរបង្គងមានប្រវែង ២០សង់ទីម៉ែត្រ ឬ ២តឹក



ធ្នើទ្រនំសម្រាប់មាន់ដេកធ្វើពីបន្ទះឬស្សី

### ៣.៣. សំបុកមេមាន់

- ត្រូវរៀបចំសំបុកមុនមេមាន់រកពង
- ចំនួនសំបុកត្រូវឱ្យស្មើគ្នាជាមួយចំនួនមេមាន់
- សំបុកអាចធ្វើពីបង្គីរ ឬស្សី កេស ។ល។
- សំបុកដាក់ ឬ ចងជាប់នឹងទ្រុង នៅកន្លែងមិនសូវមានពន្លឺ
- សំបុកអាចធ្វើពីចំបើងស្ងួត ឬស្លឹកចេក ដាក់ឲ្យក្រាស់ ដើម្បីផ្ដល់កំដៅដល់ស៊ុតញាស់ល្អ
- ដើម្បីកំចាត់ស្រមើរក្នុងសំបុកត្រូវដាក់កំទេចថ្នាំជក់ ស្លឹកចេក ឬ ស្លឹកសាវម៉ាវព្រៃ ដាក់នៅពីក្រោមសំបុក។



សំបុកសម្រាប់មាន់ពង

## ៤. ស្នូកចំណី និងស្នូកទឹក

ត្រូវដាក់ស្នូកទឹក និងស្នូកចំណីឱ្យបានគ្រប់គ្រាន់សម្រាប់មាន់ ។ ដើម្បីកាត់បន្ថយការចំណាយទិញ និងការកំពប់បាត់បង់ចំណី កសិករគួរកែច្នៃនូវសម្ភារដែលមានស្រាប់នៅក្នុងភូមិ ឬមានតម្លៃថោកៗ សម្រាប់ធ្វើជាស្នូកចំណី ។ អ្នកចិញ្ចឹមអាចយកបីដុង ឬកានជ័រមកច្នៃជាស្នូកចំណីដែលបង្ហាញដូចរូបខាងក្រោម ៖



ស្នូកចំណីកូនមាន់ធ្វើពីដបជ័រ



ស្នូកចំណីកូនមាន់ជំទង់ធ្វើពីធុងជ័រ



ស្នូកចំណីកូនមាន់ជំទង់ធ្វើពីប៊ីដុងជ័រ



កំប៉ុងទឹកជ័រសម្រាប់មាន់ផឹក



# ពូជ និងការបង្កាត់ពូជមាន់

ពូជមាន់ក្នុងស្រុក មានលក្ខណៈសម្បត្តិល្អសមស្របសម្រាប់កសិករចិញ្ចឹម និងពង្រីកផលិតកម្ម ។មាន់ឈ្មោលអាចបង្កាត់ពូជបាន លុះត្រាតែវាមានអាយុ ៦ខែ ចំណែកឯមាន់ញីពេញវ័យ និងចាប់ផ្តើមពងនៅពេលដែលវាមានអាយុ ៤-៥ខែ តែវាអាចបង្កកំណើតបាន លុះត្រាតែវាមានអាយុ ៥-៦ខែ ។ ប្រសិនបើ មេមាន់មានសុខភាពល្អ និងមានចំណីគ្រប់គ្រាន់ វានឹងផ្តល់ពងរៀងរាល់ពេលព្រឹកព្រលឹម ។

## ១. ការបង្កកំណើត

បន្ទាប់ពីពាក់មេ ស្តែមរស់នៅក្នុងបំពង់នាំអូវុលបាន ២-៣សប្តាហ៍ ។ ស្តែមអាចមានលទ្ធភាពបង្កកំណើតពេញលេញបានក្នុងរយៈពេល ៦ថ្ងៃ ។ បន្ទាប់ពីនេះលទ្ធភាពបង្កកំណើតរបស់វាថយចុះ ៖

- បន្ទាប់ពីពាក់រួច នៅថ្ងៃទី ១០ លទ្ធផលបង្កកំណើតបានត្រឹមតែ ៥០%
- បន្ទាប់ពីពាក់រួច នៅថ្ងៃទី ១៩ លទ្ធផលបង្កកំណើតបានត្រឹមតែ ១៥%

ជាទូទៅមេមាន់ពងក្នុងមួយលើកៗបានពី ៨-១៣គ្រាប់ ដោយមួយថ្ងៃពងមួយគ្រាប់ ។



*ការបង្កាត់ពូជមាន់*

## ២. ការបង្កជាស៊ុត និងការក្រាប

បន្ទាប់ពីផ្ទៃកលឿងនៃស៊ុតត្រូវបានបង្កកំណើតរួច មិនយូរប៉ុន្មានវានឹងក្លាយជាស៊ុតពេញលេញ ហើយត្រូវបានបញ្ចេញមកក្រៅ ។ អំប្រីយ៉ុងនឹងលូតលាស់ដោយខ្លួនឯង ដោយមិនត្រូវការជំនួយពីមេ លើកលែងតែការក្រាបផ្តល់កំដៅ ។

- ស៊ុតត្រូវការសំណើម និងសីតុណ្ហភាពសមស្រប ដើម្បីញាស់ (៣៨-៣៩អង្សាសេ)
- មេមាន់ក្រាបលើស៊ុតពី ៨-១៣គ្រាប់
- មេមាន់ប្រើចំពុះបង្វិលស៊ុតជាប្រចាំ ដើម្បីការពារកុំឲ្យអំប្រីយ៉ុងស្អិតជាប់សំបក និងដើម្បីផ្តល់អុកស៊ីសែន
- មាន់ក្រាបក្នុងរយៈពេល ២១ថ្ងៃ

## ៣. ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់

- ស៊ុតដែលត្រូវជ្រើសរើសយកមកភ្ញាស់ ត្រូវតែមានទំហំ រូបរាង និងពណ៌ល្អ
- មេមាន់ចាស់ និងមេមាន់ពងដំបូងតែងតែផ្តល់ស៊ុតដែលមានទំហំតូច ដូច្នេះកូនដែលញាស់មកក៏តូចដែរ
- មិនត្រូវភ្ញាស់ស៊ុតក្រខ្វក់ឡើយ
- មិនត្រូវធ្វើការលាងសំអាតស៊ុតទេ ព្រោះវានឹងបំផ្លាញប្រព័ន្ធការពារពីធម្មជាតិរបស់ស៊ុត ។

## ៤ .ការភ្ញាស់ស៊ុត និងការញាស់

ការភ្ញាស់មានពីររបៀប គឺការភ្ញាស់តាមធម្មជាតិ និងការភ្ញាស់ដោយម៉ាស៊ីន ។

### ការភ្ញាស់តាមធម្មជាតិ

- ទុកស៊ុតនៅស្ងៀមក្នុងសំបុក ដើម្បីទុកឲ្យមេក្រាបពង
- សំបុកត្រូវតែគ្មានស្រមោច ឬចៃ
- នៅពេលមេមាន់ពងអស់ វាចាប់ផ្តើមក្រាប
- ក្នុងកំឡុងពេលក្រាបនេះ មេមាន់តែងតែចាកចេញពីសំបុករយៈពេល ១៥នាទី ដើម្បីរកចំណី ពេលនេះមេមាន់មិនសូវស៊ីច្រើនទេ ដូចនេះមុន

ពេលក្រោយវា ត្រូវតែមានសុខភាពល្អ

- ដំណើរការញាស់មានរយៈពេលពី ៤-១២ម៉ោង (មុនពេលកូនមាន់បំបែកសំបកចេញ)
- កូនមាន់បំបែកសំបកចេញដោយខ្លួនឯង ហើយមានសភាពសើម និងអស់កម្លាំង
- រយៈពេល ២-៣ ម៉ោង ក្រោយពីញាស់ វានឹងដេក ហើយសម្រាក
- ក្រោយពេលរោមស្ងួត កូនមាន់នឹងធ្វើចលនា
- ផ្នែកលឿងនៃស៊ុតដែលមាននៅក្នុងខ្លួនវា នៅជាប់រហូតដល់ ៤៨ម៉ោង



### ការភ្ញាស់ដោយប្រើទូរភ្ញាស់

- មិនចាំបាច់ប្រញាប់យកស៊ុតទៅដាក់ក្នុងទូរភ្ញាស់ឡើយ
- គេអាចរក្សាស៊ុតបានរយៈពេល ៦ថ្ងៃ ដោយដាក់ក្នុងបន្ទប់ត្រជាក់
- ដើម្បីការពាររំហួតទឹកចេញ ត្រូវរក្សាស៊ុតក្នុងថង់ប្លាស្ទិក ឬថង់ធ្វើពីកប្បាសដែលស្អាតល្អ
- រក្សានៅកន្លែងដែលមានសុវត្ថិភាព
- ទូរភ្ញាស់ត្រូវធានាថាមានចរន្តខ្យល់នាំអុកស៊ីសែនចូល និងនាំឧស្ម័នកាបូនិកចេញ ព្រមទាំងនាំសំណើម
- រក្សាសីតុណ្ហភាពឲ្យនៅថេរ ក្នុងរង្វង់ ៣៧.៥ អង្សាសេ
- ត្រួតពិនិត្យសំណើម ដោយថ្លឹងស៊ុតមុនដាក់ក្នុងទូរភ្ញាស់ និងនៅពេលភ្ញាស់បាន ១៨ថ្ងៃ (ប្រសិនបើបាត់បង់សំណើមលើស ២០% បានន័យថាខ្យល់ស្ងួតខ្លាំង តែបើបាត់បង់តិចជាង ១០% គឺខ្យល់មានសំណើមខ្ពស់)



ទូរភ្ញាស់អគ្គិសនី

### ការបង្វិល

ការបង្វិលស៊ុត ជាគោលបំណងដ៏សំខាន់ដើម្បីឲ្យស៊ុតលឿង នៅចំកណ្ដាលស៊ុត ។ ប្រសិនបើគ្មានការបង្វិលទេអំប្រ៊ីយ៉ុងដំបូងនឹងងាប់ដូចនេះលទ្ធផលញាស់ទាប ។

ចំពោះការភ្ញាស់ដោយធម្មជាតិ មេមាន់តែងប្រើ



ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រ៊ីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់

ចំពុះ ដើម្បីបង្វិលស៊ុត ។ ប៉ុន្តែចំពោះការភ្ញាស់ដោយទូរភ្ញាស់វិញ ត្រូវបង្វិលស៊ុតឲ្យបាន ៤ដងក្នុងមួយថ្ងៃ ។ ក្រោយពេលភ្ញាស់បាន ១៤ថ្ងៃ មិនចាំបាច់បង្វិលស៊ុតទៀតទេ ជាពិសេស ៣ថ្ងៃចុងក្រោយនៃការភ្ញាស់ មិនត្រូវបង្វិលស៊ុតឡើយ ។

ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់

### ការឆ្លុះស៊ុត

ដើម្បីមើលពីសភាព ដែលមាននៅក្នុងស៊ុត។ បន្ទាប់ពីភ្ញាស់បាន ១សប្តាហ៍ តាមរយៈការឆ្លុះ យើងអាចឃើញបណ្តាញសរសៃឈាមព័ទ្ធជុំវិញចំណុចខ្មៅនោះមានន័យថាអំប្រីយ៉ុងលូតលាស់ល្អ ។

ការឆ្លុះនេះមានសារៈសំខាន់ណាស់សម្រាប់ឲ្យយើងយកស៊ុតដែលខូចចេញ ចៀសវាងក្លិនស្អុយ នៅក្នុងទូរភ្ញាស់ ។

ដើម្បីឆ្លុះស៊ុតបាន ត្រូវដាក់ពន្លឺក្នុងប្រអប់មួយដែលមានចោះប្រហោងប៉ុនទំហំស៊ុត ។



អំប្រីយ៉ុងលូតលាស់ល្អ

ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់

## ៥ ការជ្រើសរើសកូនមាន់ចិញ្ចឹម

- រាងល្អ ភ្លៀវភ្លា ជើងលឿង
- ចំពោះកូនមាន់ដែលរោមស្អិតជាប់គ្នា ហើយពស់ធ្លាក់ ឬ រឹង និងមានពណ៌ខៀវ មិនគួរយកមកចិញ្ចឹមទេ។



កូនមាន់មានសភាពរស់រវើក និងភ្លៀវភ្លា

## ៦ ការជ្រើសរើសបាមាន់

- រាងល្អ ភ្លៀវភ្លា ជើងលឿង
- មាឌធំ ទម្ងន់ ២,៥ គីឡូក្រាម
- ពូកែជាន់មេ (បង្កាត់ពូជ)
- មានអាយុចាប់ពី ៩ ខែ ឡើង តែមិនត្រូវលើសពី ៣ ឆ្នាំឡើយ
- មានមេបាដែលមានកូនច្រើន និងគ្មានជំងឺឆ្លង



បាមាន់មាឌធំ និងសុខភាពល្អ

## ៧ ការជ្រើសរើសមេមាន់

- រាងល្អ ខ្លាំងមាំ ជើងលឿង
- គ្មានជំងឺ និងសុខភាពល្អ
- ត្រូវមានអាយុ ៧ ខែឡើង និងមានទម្ងន់ច្រើនជាង ១,២ គីឡូក្រាម
- រើសចេញពីមេមាន់ដែលបានផ្ដល់កូន ៤ សារក្នុងមួយឆ្នាំយ៉ាងតិច
- ពងមួយសារពី ១០ ទៅ ១២ ពង ហើយអត្រាញាស់ ពី ៨ ក្បាលឡើង ហើយដែលកូនមាន់ទាំងនោះសកម្ម និងក្លៀវក្លា។




*ពូជមេមាន់មានមាឌធំ និងជើងសម្បុររមៀត*

## សម្គាល់

មេ និងបា គួរមានស្រកាជើងក្រាស់ល្អ ជើងមាំ សិរក្រហម ស្បែកកស្ដើងទន់ ។ បា១ក្បាល សម្រាប់មេ ៦ ទៅ ៧ ក្បាល។

## ៨. ការបង្កាត់ពូជមាន់

យើងអាចជ្រើសរើសពូជមាន់មកចិញ្ចឹម អាស្រ័យលើគោលបំណងរបស់អ្នកចិញ្ចឹម ។ ពូជមាន់ក្នុងស្រុកមានលក្ខណៈសមស្របបំផុតសម្រាប់ស្ថានភាពកសិករក្នុងពេលបច្ចុប្បន្ននេះ ។ បើអ្នកចិញ្ចឹម ចង់បានផលិតកម្មសាច់ខ្ពស់ និងលូតលាស់លឿន ត្រូវយកពូជមាន់មេក្នុងស្រុកបង្កាត់ជាមួយពូជកូនកាត់នាំចូល ដូចជា៖ ពូជកូនកាត់អ៊ីសាប្រោន (ខេអាយ) ជាដើម ។ ប៉ុន្តែត្រូវជ្រើសរើសប្រភេទពូជនាំចូលដែលមានសម្បុរប្រហាក់ប្រហែលពូជក្នុងស្រុក ទើបងាយស្រួលលក់ និងមានតម្រូវការសម្រាប់ទីផ្សារខ្ពស់ ។

### ពូជក្នុងស្រុក

- ស៊ាំទៅនឹងមជ្ឈដ្ឋានបានខ្ពស់
- សមស្របទៅនឹងអ្នកចិញ្ចឹមតូចតាច ព្រោះវាអាចដើរកកាយរកស៊ីដោយខ្លួនឯង និងងាយស្រួលចិញ្ចឹម
- វាមានដងខ្លួនតូច ដូចនេះវាត្រូវការចំណីតិចដែរ
- ពេញវ័យនៅអាយុ ២៨សប្ដាហ៍
- ផ្ដល់ស៊ុតតិច (៤០-៦០ គ្រាប់ក្នុងមួយឆ្នាំ) និង
- មានទម្ងន់មិនលើសពី ២៥-៤៥ក្រាម ក្នុងមួយគ្រាប់



- ចំនួនកូនមាន់ញាស់ក្នុងមួយសំបុកទាប (មួយសម្បុកជាមធ្យម ៧ក្បាល)
- វដ្ដផលិតកម្មវែង (ពង ១៦ថ្ងៃ ក្រាប ២១ថ្ងៃ បណ្ដើរកូន ៤២ថ្ងៃ)
- មេមាន់ភាគច្រើនផលិតកូនបានពី ៤-៥ដងក្នុងមួយឆ្នាំ
- បញ្ហាកង្វះចំណី ជំងឺ ពពួកសត្វចង្រៃ និងគ្រោះថ្នាក់ផ្សេងៗ ធ្វើឲ្យអត្រាស្លាប់មានដល់ពី ៦០-៧០%
- ស៊ុតភាគច្រើន ទុកសម្រាប់ភ្ញាស់ មិនមែនសម្រាប់លក់ ឬសម្រាប់ហូបទេ
- អាយុលើសពី ៦ខែ មានទម្ងន់ត្រឹមតែ ១.២-១.៥គ្រ
- បរិមាណសាច់ទាប តែមានរសជាតិ



មេមាន់ពូជក្នុងស្រុកបណ្ដើរកូន ៩ក្បាល



មេមាន់បណ្ដើរកូនលើស១ខែ ទោះកូននៅតែបីក្បាល





ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣០៣ សរណន កសក

## សារាចរណែនាំ
## ស្តីពី
## វត្តមានសមាសភាពចង្រៃ និងវិធានការកម្ចាត់ក្នុងរដូវវស្សាឆ្នាំ២០១៣

នៅរដូវវស្សាឆ្នាំ២០១៣នេះ ជាទូទៅអាកាសធាតុមានលក្ខណៈអំណោយផលល្អសមស្របដល់ការងារបង្កបង្កើនផលចាប់តាំងពីដើមរដូវមក ដោយមានការខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសការយកចិត្តទុកដាក់ឧបត្ថម្ភគាំទ្រតាមគ្រប់មធ្យោបាយពីសំណាក់រាជរដ្ឋាភិបាលផងនោះ ការងារបង្កបង្កើនផលស្រូវមានសន្ទុះលឿនគួរជាទីមោទនៈ ដែលគិតត្រឹមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ នេះ ស្រូវវស្សាអនុវត្តបានប្រមាណ៥០ភាគរយ (ស្ទូង និងព្រោះ) ស្មើនឹងជិត១,២លានហិកតានៃផែនការជាង២,៣៩លានហិកតា។

ទន្ទឹមនឹងលទ្ធផលខាងលើ យើងក៏ត្រូវចាប់អារម្មណ៍យកចិត្តទុកដាក់លើ **ប្រការអវិជ្ជមាន** មួយចំនួនដែលអាចនឹងកើតឡើងជាយថាហេតុ មានដូចជា គ្រោះរាំងស្ងួតពាក់កណ្តាលរដូវ (កូនរដូវប្រាំង) និងការទទួលរងការបំផ្លាញដោយខ្យងមាស ដែលថ្មីៗនេះមានលេចចេញវត្តមានដ៏ច្រើននៅខេត្តព្រះសីហនុ កំពត តាកែវ ពោធិ៍សាត់ និងខេត្តកណ្តាល។

គួរកត់សម្គាល់ថា សត្វខ្យងស្រុកខ្មែរមិនស៊ីស្រូវឡើយ ប៉ុន្តែសត្វខ្យងមាសជាសត្វចង្រៃដែលបំផ្លាញដំណាំស្រូវ។ ខ្យងមាសបានបំផ្លាញដំណាំស្រូវយ៉ាងធ្ងន់ធ្ងរនៅប្រទេសមួយចំនួនដូចជាវៀតណាម ហ្វីលីពីន ហើយកំពុងរាតត្បាតនៅប្រទេសថៃនិងឡាវ។ ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជាយើង បានរកឃើញវត្តមានខ្យងមាសនេះតាំងពីឆ្នាំ១៩៩៤មកម្ល៉េះ តែត្រូវបានកម្ចាត់ដោយក្រុមអ្នកជំនាញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាបន្តបន្ទាប់។ តែទោះជាយ៉ាងនេះក៏ដោយក៏ខ្យងមាសនៅតែមានវត្តមាន និងបន្តពូជជាបន្តទៀត ហើយមានការបំផ្លាញជាទ្រង់ទ្រាយធំលើផ្ទៃដីប្រមាណ៣០០ហិកតា ក្នុងខេត្តព្រៃវែង នារដូវវស្សាឆ្នាំ២០១២កន្លងទៅ។ ខ្យងមាសមានរូបរាងដូចគ្នានឹងខ្យងស្រុកដែរ តែខុសគ្នាត្រង់វាមានពណ៌មាស និងមានទំហំតូចឬធំអាស្រ័យលើការរកចំណីស៊ីរបស់វា ហើយអាចរស់នៅបានយូររហូតដល់៦ឆ្នាំក្នុងស្រះ វាលល្បប់ ប្រឡាយ និងគ្រប់ទីកន្លែងដែលមានដក់ទឹក។ អាយុកាលក្រាំងរបស់វាមានរហូតដល់៦ខែ។ ខ្យងមាសទម្លាក់ពងជាកញ្ចុំពណ៌ផ្កាឈូកងាយសម្គាល់ភ្ជាប់ជាមួយស្មៅ ឬគុម្ពស្រូវ ឬបង្គោលផ្សេងៗផុតពីផ្ទៃទឹក។

ក្នុងគោលបំណងធានាបាននូវការអនុវត្តផែនការផលិតកម្មកសិកម្ម និងឈានសម្រេចបានតាមគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣ ២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

នេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្តទាំងអស់ ត្រូវយកចិត្តទុកដាក់ជំរុញបងប្អូនកសិករឱ្យចុះពិនិត្យសំណាប សន្ទូង និងពង្រោះទើបនឹងលាស់ខ្ចី(អាយុតិចជាង ៤៥ថ្ងៃ) ដែលជាដំណាក់កាលងាយរងការបំផ្លាញដោយខ្យងមាស។ ក្នុងករណីឃើញមានវត្តមានរបស់វា ត្រូវអនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួនដូចខាងក្រោម៖

- បង្ហូរទឹកចេញឱ្យអស់ពីស្រែដើម្បីឱ្យខ្យងមាសផ្តុំទៅនៅកន្លែងទំនាបដក់ទឹកងាយស្រួលប្រមូលដោយដៃយកមកកប់ចោល។ គ្រប់ស្រែសន្ទូង ឬស្រែពង្រោះត្រូវឆូតជាចង្អូរដែលមានគម្លាតពីគ្នា ១០-១៥ ម៉ែត្រ ដើម្បីឱ្យមានដក់ទឹកងាយស្រួលចាប់ប្រមូលខ្យងពេលបង្ហូរទឹកចេញពីស្រែ
- ចាប់ដោយដៃរួចកម្ទេចចោលទាំងពង កូន និងមេខ្យង(ពងខ្យងមាសពណ៌ផ្កាឈូកខុសពីខ្យងធម្មតាដែលមានពណ៌ស)
- ដោតបង្គោលឈើ ឬ ឫស្សី រាយក្នុងស្រែដើម្បីងាយស្រួលប្រមូលសម្បុកពងខ្យងមកកម្ទេចចោល
- យកសំបកខ្នុរទុំដែលនៅសល់ជញ្ជាំងទៅដាក់ក្នុងស្រែក្នុងចន្លោះពីកន្លែងមួយទៅមួយពី១០-១៥ម៉ែត្រ ដើម្បីឱ្យពពួកខ្យងមាសផ្តុំគ្នាស៊ី ងាយស្រួលដល់ការប្រមូលវាមកកម្ទេចចោល
- ប្រើប្រាស់សត្វទាឱ្យស៊ីសាច់ខ្យង និងកូនខ្យងតូចៗ និងស្រមោចក្រហមស៊ីពងសត្វខ្យងមាស។

ជារួមការប្រមូលទាំងពង កូន និងមេខ្យងដោយដៃមកកម្ទេចចោលតាមគ្រប់មធ្យោបាយដូចបានរៀបរាប់ខាងលើគឺជាវិធានការដ៏មានប្រសិទ្ធភាពបំផុតដែលត្រូវជំរុញឱ្យបងប្អូនកសិករអនុវត្តព្រមគ្នាក្នុងពេលតែមួយនិងគួរជៀសវាងការប្រើប្រាស់ថ្នាំកសិកម្ម។

អង្គភាពជំនាញថ្នាក់កណ្តាល និងមូលដ្ឋានរាជធានី-ខេត្តគ្រប់ជាន់ថ្នាក់ ត្រូវម្ចាស់ការបន្តយកចិត្តទុកដាក់តាមដានសភាពការណ៍និងជំរុញការងារផលិតកម្មជាប្រចាំ ព្រមទាំងរួមសហការដោះស្រាយការលំបាកផ្សេងៗជាមួយកសិករ ក៏ដូចជា ជាមួយផ្នែកពាក់ព័ន្ធហើយរាយការណ៍ឱ្យបានទាន់ពេលវេលា។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អនុវត្តតាមការណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-រាជធានី

"ដើម្បីជូនជ្រាប"

- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្មរាជធានី-ខេត្ត

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីថ្លែងការណ៍

## ដោយឯកឧត្ដមបណ្ឌិត ច័ន្ទ សារុន
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងវេទិកាពិសេសស្ដីពី
## ការទទួលស្គាល់នូវវឌ្ឍនភាពដ៏ប្រសើរក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន

**ក្នុងសន្និសីទលើកទី៣៨ របស់អង្គការស្បៀងអាហារ និងកសិកម្ម សហប្រជាជាតិ**

ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី
ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣

**សូមគោរព៖ ឯកឧត្តមប្រធាន**

**ឯកឧត្តមប្រធានាធិបតី និងនាយករដ្ឋមន្ត្រី**

**ឯកឧត្តមប្រធានប្រតិភូ**

**ឯកឧត្តមអគ្គនាយកអង្គការស្បៀងអាហារ និងកសិកម្ម សហប្រជាជាតិ**

**ឯកឧត្តម លោកជំទាវ គណៈប្រតិភូ និងអ្នកសង្កេតការណ៍ទាំងអស់ជាទីមេត្រី**

ក្នុងនាមរាជរដ្ឋាភិបាលនិងគណៈប្រតិភូកម្ពុជា ខ្ញុំសូមសម្ដែងនូវការកោតសរសើរដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃប្រទេសអ៊ីតាលី ដែលបានរៀបចំទទួលនិងស្វាគមន៍យ៉ាងរាក់ទាក់ដល់គណៈប្រតិភូកម្ពុជា។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ដែលបានចាត់ចែងរៀបចំនូវព្រឹត្តិការណ៍ដ៏ពិសេសនេះ។

ជាមួយមោទនភាពនិងកិត្តិយសដែលទទួលស្គាល់ដោយអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ក្នុងបរិបទនៃការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងការអត់ឃ្លាន កម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសនៅក្នុងពិភពលោកដែលបាន និងកំពុងខិតខំប្រឹងប្រែងក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជានៅក្នុងប៉ុន្មានឆ្នាំដ៏ខ្លីខាងមុខនេះ។ ជាមួយគ្នានេះ ខ្ញុំសូមចូលរួមចែករំលែកនូវបទពិសោធន៍នានាជាមួយបណ្ដាប្រទេសជាសមាជិកទាំងអស់ ពីការខិតខំរបស់កម្ពុជាក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយសង្កត់ធ្ងន់លើការធ្វើអន្តរាគមន៍គោលនយោបាយ និងការអនុវត្តសកម្មភាពជាសំខាន់ៗនានាក្នុងការអភិវឌ្ឍវិស័យកសិកម្ម។

ចាប់ផ្ដើមពីចំណុចសូន្យនៅក្នុងឆ្នាំ១៩៧៩ ជាឆ្នាំដែលកម្ពុជាមានភាពក្រីក្រទាំងស្រុង រហូតដល់កម្ពុជាទទួលបានសន្តិភាពពេញលេញនៅឆ្នាំ១៩៩៨ ក្រោមគោលនយោបាយឈ្នះ-ឈ្នះ ដែលនាំឲ្យមានស្ថេរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច កម្ពុជាទទួលបាននូវការវិវឌ្ឍរីកចម្រើនយ៉ាងខ្លាំងក្លា ហើយត្រូវបានចាត់ក្នុងចំណាត់ថ្នាក់លេខ១៥ ថាជាប្រទេសមានការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចលឿនក្នុងចំណោមប្រទេសលើពិភពលោក និងបានចាត់ថ្នាក់ជាប្រទេសទី៥ ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ផងដែរ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ប្រមាណថាកើនក្នុងរង្វង់ជាង៧ភាគរយក្នុងមួយឆ្នាំ ក្នុងរយៈពេលមធ្យមខាងមុខ។ អត្រាភាពក្រីក្របានធ្លាក់ចុះពី២៩,៩ភាគរយក្នុងឆ្នាំ២០០៨ មកត្រឹម២២,៩ភាគរយក្នុងឆ្នាំ២០០៩ ហើយអត្រានេះបានបន្តធ្លាក់ចុះដល់ ២១,១ភាគរយក្នុងឆ្នាំ២០១០ និង១៩,៨ភាគរយក្នុងឆ្នាំ២០១១ ដែលតាមការប៉ាន់ស្មានគឺកម្ពុជាអាចកាត់បន្ថយអត្រាភាពក្រីក្របានប្រមាណជាង១ភាគរយក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០១២ និង២០១៣ខាងមុខ។ បន្ថែមលើនេះ កម្ពុជាត្រូវបានវាយតម្លៃថាបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី១ លើផ្នែកកង្វះអាហារូបត្ថម្ភ ដែលអត្រាប្រេវ៉ាឡង់បានថយចុះពី៣៩,៩ភាគរយនៅក្នុងចន្លោះឆ្នាំ១៩៩០-៩២ មកត្រឹមតែ១៧,១ភាគរយក្នុងចន្លោះឆ្នាំ២០១០-២០១២។

ដោយបានកំណត់ពីតួនាទីដ៏សំខាន់នៃវិស័យកសិកម្មនៅក្នុងខឿនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងការប្រឹងប្រែងដើម្បីពង្រីកមូលដ្ឋានកំណើនរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាតែងតែចាត់

ទំព័រទី១

ទុកវិស័យកសិកម្មមានអាទិភាពខ្ពស់នៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ប្រទេសជាតិ។ សារសំខាន់របស់វិស័យកសិកម្មត្រូវបានស្ដែងឱ្យឃើញតាមរយៈក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ សម្រាប់កំណើន ការងារ សមភាព និងប្រសិទ្ធភាព ឆ្នាំ២០០៨-២០១២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ សុទ្ធតែឆ្លុះបញ្ចាំងឱ្យឃើញអំពីការជំរុញ និងលើកស្ទួយវិស័យ កសិកម្ម តាមរយៈការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ជាមួយនិងរបត់ថ្មីដើម្បីនាំឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។

ឯកសារគោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ត្រូវដាក់ឱ្យអនុវត្តនៅឆ្នាំ២០១០ ដោយបានកំណត់ចំណុចដៅលើការផលិតស្រូវលើសយ៉ាងហោចណាស់៤លានតោន និងត្រូវនាំចេញជាផ្លូវការយ៉ាងតិច១លានតោន ឆ្ពោះទៅទីផ្សារអន្តរជាតិ។ នេះជាមហិច្ឆតារបស់ប្រទេសកម្ពុជាដើម្បីឱ្យក្លាយទៅជាផ្នែកមួយដ៏សំខាន់នៃទីផ្សារស្រូវអង្ករលើពិភពលោក។

គោលនយោបាយនិងយុទ្ធសាស្ត្រជាច្រើនត្រូវបានអនុវត្តយ៉ាងទូលំទូលាយ។ ការកែទម្រង់វិស័យកសិកម្មមួយចំនួន និងការផ្ដួចផ្ដើមគំនិតថ្មីៗជាច្រើនត្រូវបានអនុវត្តដើម្បីផ្ដល់នូវសន្ទុះបន្ថែមទៀតដល់កិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនិងគ្រោះអត់ឃ្លាន។ កត្តាទាំងអស់នេះរួមមាន ការអនុវត្តលើ (១) គោលនយោបាយមិនយកពន្ធលើការប្រើប្រាស់ដីកសិកម្មរបស់ប្រជាកសិករតូចតាច (២) គោលនយោបាយចាស់សកម្មភាពថ្មីទាក់ទងទៅនឹងការកែទម្រង់ដីធ្លី ដោយការត្រៀមបម្រុងទុកដីធ្លី និងការផ្ដល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅជនបទ និងការធានាដល់ប្រជាកសិករកម្ពុជាគ្រប់រូបទទួលបានសុវត្ថិភាពដីធ្លីគ្រប់គ្រាន់ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន។ យោងតាមផែនការ គ្រោងទុក ផ្ទៃដីប្រមាណជាង២លានហិកតានឹងត្រូវបានធ្វើការវាស់វែងបែងចែកជូនប្រជាកសិករ។ (៣) ច្បាប់ស្ដីពីសហគមន៍កសិកម្មដែលត្រូវបានអនុម័តនៅក្នុងខែឧសភាឆ្នាំ២០១៣កន្លងមកនេះ បានផ្ដល់ជូនកសិករនូវសិទ្ធិធ្វើការសម្រេចចិត្តក្នុងការចងក្រងគ្នាជាក្រុមដើម្បីទទួលបាននូវការគាំទ្រនិងជំនួយឧបត្ថម្ភផ្សេងៗសម្រាប់ការងារបង្កបង្កើនផលកសិកម្មនិងការលក់ដូរផលិតផល។ (៤) សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ធនធានដីកសិកម្មសម្រាប់ផលិតកម្មស្បៀងអាហារ។ សកម្មភាពទាំងអស់នេះកំពុងទទួលបានការគាំទ្រយ៉ាងទូលំទូលាយនិងទទួលស្គាល់ថាជាវិធានការគន្លឹះចូលរួមកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា។

ចាប់តាំងតែពីឆ្នាំ២០០៦មក វិស័យកសិកម្មកម្ពុជាមានអត្រាកំណើនជាមធ្យមពី ៤-៥ភាគរយក្នុងមួយឆ្នាំ។ នេះគឺជាសមិទ្ធផលដែលសម្រេចបានតាមរយៈការទទួលយកទៅប្រើប្រាស់នូវបច្ចេកវិទ្យាសមស្រប ធាតុចូល និង សេវាគាំទ្រផ្សេងៗទៀតក្នុងចំណោមប្រជាកសិករ។ ផលិតកម្មស្រូវបានកើនឡើងជាលំដាប់ទាំងផ្ទៃដីដាំដុះនិងទិន្នផល។ ជាក់ស្ដែងក្នុងឆ្នាំ២០១២កន្លងមកនេះ ផ្ទៃដីប្រមូលផលស្រូវសម្រេចបានប្រមាណ២,៩៨លានហិកតា រីឯទិន្នផលស្រូវបានកើនដល់៣,១១តោនក្នុងមួយហិកតា បរិមាណផលស្រូវសរុបទទួលបានមានចំនួន៩,៣លានតោន។ ជាមួយនឹងបរិមាណផលស្រូវនេះ កម្ពុជានៅសល់ស្រូវលើសពីសេចក្ដីត្រូវការក្នុងស្រុកប្រមាណជា៤,៧លានតោន ឬស្មើនឹងប្រមាណ៣លានតោនអង្ករ។ ដំណាំផ្សេងៗទៀតដូចជាដំណាំបន្លែ ឈើហូបផ្លែ និង

ដំណាំឧស្សាហកម្មដ៏ទៃៗទៀតក៏បានកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ ក្នុងនោះផ្ទៃដីដំណាំកៅស៊ូបានកើនដល់ ២៨០ ពាន់ហិកតា។

ក្រៅពីផលិតកម្មដំណាំកសិកម្ម វិស័យចិញ្ចឹមសត្វនិងជលផលក៏មានតួនាទីដ៏សំខាន់ផងដែរក្នុងការចូលរួមចំណែកធានាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ។

ការចិញ្ចឹមសត្វបានចូលរួមដោយផ្ទាល់ក្នុងការបំពេញសេចក្តីត្រូវការចំណីអាហារ និងបង្កើនប្រាក់ចំណូលគ្រួសារសម្រាប់ប្រជាជនកម្ពុជាដ៏ច្រើនលើសលប់ដែលរស់នៅក្នុងទីជនបទ ជាពិសេសសម្រាប់គ្រួសារកសិករតូចតាច។ ជាទូទៅ ផលិតកម្មសត្វមានកំណើនប្រមាណ២ភាគរយក្នុងមួយឆ្នាំ ក៏ប៉ុន្តែវិស័យនេះនៅត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតសម្រាប់សម្រេចបានគោលដៅក្នុងការធានា ការផ្គត់ផ្គង់ក្នុងស្រុកឲ្យបានគ្រប់គ្រាន់និងការធ្វើពាណិជ្ជកម្មក្នុងរយៈពេលមធ្យមនិងវែង។ ជារួម កម្ពុជានៅមានសក្តានុពលជាច្រើនក្នុងការពង្រីកនូវវិស័យនេះដោយសារកម្ពុជាមានប្រភពចំណីសត្វច្រើន វាលស្មៅ និងធាតុអាកាសអំណោយផល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញការវិនិយោគក្នុងវិស័យនេះតាមរយៈការផ្តល់ជូនគ្រួសារកសិករខ្នាតតូចនូវកញ្ចប់សេវាកម្មរួមមានបច្ចេកវិទ្យា ពូជសត្វ ឥណទាន ដំណោះស្រាយទីផ្សារ។ល។ មកទល់ពេលនេះ កសិករប្រមាណ១៤ពាន់នាក់ត្រូវបានបណ្តុះបណ្តាលឲ្យក្លាយជាភ្នាក់ងារពេទ្យសត្វភូមិស្ម័គ្រចិត្តដើម្បីសហការជួយផ្តល់នូវសេវាចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងផលិតកម្មសត្វនិងបសុសត្វទៅដល់កសិករតាមមូលដ្ឋានរបស់ពួកគេ។

ដោយឡែកត្រី និងស្រូវគឺជាផ្នែកមួយនៃរបបអាហារប្រចាំថ្ងៃដ៏សំខាន់របស់កម្ពុជា។ ដើម្បីលើកស្ទួយជីវភាពប្រពលរដ្ឋក្រីក្រ និងជួយបង្កើនសន្តិសុខស្បៀង ព្រមទាំងអភិវឌ្ឍធនធានជលផលជាមូលដ្ឋានផងនោះ នាពេលកន្លងមកថ្មីៗនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានលុបបំបាត់ឡូត៍នេសាទ ១០០ ភាគរយ ក្នុងទំហំសរុប ៤១៥ ២១៨ ហិកតា ដោយបានរក្សាទុកតែផ្ទៃឡូត៍ចំនួន ២៣ភាគរយសម្រាប់ធ្វើជាកន្លែងអភិរក្សមេត្រី និងពូជ។ រីឯដែននេសាទដែលនៅសល់ត្រូវបានប្រគល់ជូនទៅសហគមន៍នេសាទជាអ្នកគ្រប់គ្រងដោយផ្ទាល់។

យោងតាមការសិក្សាស្រាវជ្រាវកន្លងមក ផលនេសាទប្រចាំឆ្នាំ ដែលរួមទាំងសមុទ្រ ទឹកសាប និងផលិតផលវារីសត្វផ្សេងទៀត មានចំនួនសរុបពី៤០០ ទៅ ៦០០ ពាន់តោន មានតម្លៃប្រមាណ ១,២ ទៅ ១,៦ ពាន់លានដុល្លាសហរដ្ឋអាមេរិចនិងបានចូលរួមប្រមាណ ១២ ភាគរយនៃផលទុនក្នុងស្រុកសរុប។ សូមជម្រាបជូនថា ប្រជាពលរដ្ឋកម្ពុជាប្រមាណជាង៦លាននាក់ ជាអ្នកធ្វើនេសាទពេញម៉ោង និង (ប្រមាណ៤៥%) មានការងារពាក់ព័ន្ធនឹងការនេសាទ។

ការនេសាទតាមវាលស្រែ ត្រូវបានគេយល់ឃើញថាជាផ្នែកមួយសំខាន់ក្នុងការបង្កើនផលចាប់ និងអាចចូលរួមចំណែកក្នុងតម្រូវការអាហារប្រចាំថ្ងៃ។ ផលត្រីតាមវាលស្រែបានចូលរួមរហូតដល់ ២៨ ភាគរយនៃផលនេសាទសរុបនៅកម្ពុជា។ លើសពីនេះទៀត សហគមន៍ស្រះជំរកត្រីចំនួន៧៣៨ ត្រូវបានបង្កើតឡើងនៅក្នុងចំណោម ១៦២៣ ឃុំសង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនផលិតផលត្រីប្រកបដោយនិរន្តរភាព។ ការបង្កើតសហគមន៍ស្រះជំរកត្រីនៅតាមភូមិឃុំអាចជួយផ្តល់សារៈសំខាន់ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានក្នុងការធ្វើនេសាទក្នុងដែនសាធារណៈ ជាពិសេសប្រជាពលរដ្ឋក្រីក្រ។

**ឯកឧត្តមប្រធានអង្គប្រជុំ**

**ឯកឧត្តម លោក និង លោកស្រី**

ការប្រែប្រួលអាកាសធាតុមានផលវិបាកយ៉ាងខ្លាំងលើវិស័យកសិកម្ម ដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាកសិករក្រីក្រ ។ ហានីភ័យខ្ពស់នៃការបរាជ័យលើការធ្វើកសិកម្មដំណាំ ការស្លាប់សត្វចិញ្ចឹម និងការធ្លាក់ចុះផលិតផលជលផល បានបង្កឲ្យមានការបាត់បង់សេដ្ឋកិច្ច និងធ្វើឲ្យអន្តរាយដល់សន្តិសុខស្បៀង។ ករណីនេះនឹងបង្កនូវផលប៉ះពាល់កាន់តែច្រើនឡើង ក្នុងខណៈដែលការកើនឡើងនៃកម្តៅផែនដីនៅតែបន្ត។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលជាប្រទេសចុះហត្ថលេខីលើសន្ធិសញ្ញាសហប្រជាជាតិនៃការប្រែប្រួលអាកាសធាតុនិងពិធីសាក្យូតូ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការជះឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ និងបានអនុវត្តនូវ**វិធានការឈ្នះ-ឈ្នះ** ដើម្បីគាំទ្រការអភិវឌ្ឍឲ្យមានចីរភាព ដូចជាគម្រោងយន្តការអភិវឌ្ឍស្អាត ការជម្រុញថាមពលកកើតឡើងវិញ យុទ្ធនាការ សន្សំប្រេងនិងថាមពល ការអនុវត្តកសិកម្មវៃឆ្លាតនឹងអាកាសធាតុ និងគំនិតផ្តួចផ្តើមបន្សាំកសិកម្ម ការអភិរក្សព្រៃឈើក្នុងអាងធម្មជាតិនិងតំបន់ព្រៃឈើដែលបានការពារ ព្រមទាំងសកម្មភាពស្ម័គ្រចិត្តរបស់វិស័យឯកជនក្នុងការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញពីកាកសំណល់កសិកម្មសម្រាប់ផលិតកម្ម ដូចជាការប្រើប្រាស់ជីវថាមពល (អង្កាមនិង ជីវឧស្ម័ន) សម្រាប់គោលបំណងផលិតកម្មអគ្គិសនី និងចម្អិននៅតាមជនបទ។

ស្របតាមការប្តេជ្ញាចិត្តក្នុងការអនុវត្តការងារខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជានិងបន្តអនុវត្ត "កម្មវិធីការងារបន្សាំថ្នាក់ជាតិ" និងបញ្ចប់ "ផែនការយុទ្ធសាស្ត្រលើការប្រែប្រួលអាកាសធាតុ" ដោយអនុលោមតាម "គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង" និង "ផែនការយុទ្ធសាស្ត្រជាតិលើការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០" ដោយផ្តោតការងារអាទិភាពលើដំណាំ និងបច្ចេកទេសដែលអាចធានានិរន្តភាពបរិស្ថាននិងការបន្សាំនិងការប្រែប្រួលអាកាសធាតុ។

**ឯកឧត្តមប្រធានអង្គប្រជុំ**

**ឯកឧត្តម លោក លោកស្រី**

ជាការពិតណាស់ ក្នុងការទទួលស្គាល់សារៈសំខាន់នៃសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសលើការកែទម្រង់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងបានចាត់ទុកការងារនេះជាការងារអាទិភាពបំផុត។ នៅក្រោមគោលដៅអភិវឌ្ឍសហស្សវត្សរបស់ប្រទេសកម្ពុជា សន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានសង្កត់ធ្ងន់នៅក្នុងគោលដៅទី១គឺ "លុបបំបាត់ឲ្យបានជាអតិបរមានូវភាពក្រីក្រនិងភាពអត់ឃ្លាន"។ បច្ចុប្បន្ន យើងបានសម្រេចនូវគោលដៅទី១នេះដែលស្របនឹងការបំពេញបាននូវគោលដៅអភិវឌ្ឍសហស្សវត្សទី១។

សមិទ្ធផលធំធេងនិងការប្រឹងប្រែងដ៏ជោគជ័យនេះនឹងមិនអាចទទួលបាន ប្រសិនបើគ្មានការគាំទ្រ និងការឧបត្ថម្ភពីដៃគូអភិវឌ្ឍនានានៅក្នុងប្រទេសកម្ពុជា ព្រមទាំងអង្គការនិង ស្ថាប័នអន្តរជាតិ ដូចជាអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ (FAO) ជាដើម។ អាស្រ័យហេតុនេះ ខ្ញុំសូមសំដែងនូវអំណរអគុណយ៉ាងជ្រាល

ជ្រៅដល់អ្នកទាំងអស់គ្នាដែលបានរួមចំណែកជួយដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងការស្ដារនិងអភិវឌ្ឍគ្រប់លើវិស័យក្នុងប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បី កាត់បន្ថយនូវភាពក្រីក្រថែមទៀតនោះ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសដ៏ទៃទៀត នឹងនៅតែត្រូវការកិច្ចសហការ និងជំនួយពីដៃគូអភិវឌ្ឍទាំងនេះថែមទៀត ដែលយើងត្រូវឈរនិងដើរជាមួយគ្នាដើម្បីសម្រេចគោលដៅចុងក្រោយរបស់យើង។

ដូចក្នុងរបាយការណ៍ FAO ឆ្នាំ២០១២ ការរីកចម្រើនសេដ្ឋកិច្ចគឺជាការចាំបាច់បំផុត ប៉ុន្តែពុំទាន់គ្រប់គ្រាន់នៅឡើយទេ ក្នុងការជំរុញការកាត់បន្ថយភាពអត់ឃ្លាននិងភាពខ្វះខាតអាហារូបត្ថម្ភ។ ពីចំណុចនេះមានន័យថា លទ្ធផលពីការរីកចម្រើននៃសេដ្ឋកិច្ច គួរចែករំលែកឲ្យបានស្មើភាពគ្នាក្នុងចំណោមអ្នកក្រីក្រ។ និយាយដោយសាមញ្ញ ប្រជាជនក្រីក្រ គួរតែមានចំណែកស្មើគ្នា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់របស់អ្នក ។**

ទំព័រទី៥

WWF for a living planet®

WILDLIFE CONSERVATION SOCIETY

WWF No:...057/13

12 July 2013

H.E. Dr. Chan Sarun
Minister of Ministry of Agriculture, Forestry and Fisheries
#200, Preah Norodom Blvd.
Tonle Bassac, Chamkarmon,
Phnom Penh, Cambodia

Your Excellency,

**Subject: Arbour Day dinner**

We present our highest regards to the Royal Government of Cambodia.

We would like to express our gratitude for your hospitality on the eve of Arbour Day. It was very kind of you to invite us to join you and your advisors for dinner, and we had a very enjoyable evening discussing the development of agriculture production, Australian and European university experiences, global cuisines and comedians in Cambodia.

We would also like to commend the Ministry of Agriculture, Forestry and Fisheries and the Forestry Administration (FA) for the organization of Arbour Day, which this year was one of the largest that we have experienced, and had the honor of not only being hosted by H.R.H. King Sihakmony, but also having participation by H.E. Samdech Hun Sen.

We hope that, in the future, we will be able to invite you for dinner in Mondulkiri, during a visit to see the work that the FA is conducting in Seima and Mondulkiri Protected Forests with the support of WCS and WWF.

Yours Sincerely,

WORLD WIDE FUND FOR NATURE WWF CAMBODIA

Ms. Michelle Owen
WWF Acting Country Director

WILDLIFE CONSERVATION SOCIETY

Dr. Tom Clements
WCS Country Director

## លក្ខណៈជីវសាស្ត្ររបស់បង្គាខ្លឹង *Penaeus monodon*



- នៅក្នុងធម្មជាតិ បង្គាខ្លឹងរស់នៅក្នុងរន្ធនាពេលថ្ងៃ ហើយចេញមកក្រៅនៅពេលយប់ដើម្បីរកចំណី។
- ជាទូទៅបង្គាពេញវ័យ រស់នៅតំបន់ដែលមានបាតជាខ្សាច់ ឬខ្សាច់លាយភក់ នៃតំបន់ដែលមានជម្រៅទឹកពី២០ ទៅ ៥០ម៉ែត្រ ។
- បង្គាឈ្មោលផ្ទុកស្ពែមទំងន់ប្រមាណ៣៥ក្រាម។ បង្គាញីមានពងខាងក្រៅទំងន់ ៧០ក្រាម។ បង្គាពាក់គ្នាពេលយប់ ។បង្គាញីមានពងពី៥០០ ០០០ ទៅ ៧៥០ ០០០ពង
- បន្ទាប់ពីញាស់ ឡាវ៉ាចរាចទៅពីតំបន់ទឹកជ្រៅទៅកាន់តំបន់ឆ្នេរ ព្រៃកោងកាង និងព្រែកទឹកសាប ដើម្បីបន្សាំ ។ បន្ទាប់មកវាធ្វើដំណើរទៅកាន់សមុទ្រទឹកជ្រៅវិញនៅពេលវាពេញវ័យ។



# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ឯកឧត្តម បណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី អញ្ជើញពិនិត្យស្ថានភាពដំណាំស្រូវរដូវវស្សា នៅខេត្តកំពត




សកម្មភាពសំណេះសំណាលជាមួយប្រជាកសិករបង្កបង្កើនផលស្រូវរដូវវស្សា នៅខេត្តកំពង់ឆ្នាំង




សកម្មភាពសំណេះសំណាលជាមួយប្រជាកសិករបង្កបង្កើនផលស្រូវរដូវវស្សា នៅខេត្តកំពង់ចាម




ការពិនិត្យស្ថានភាពដំណាំស្រូវ និងការចិញ្ចឹមត្រីក្នុងស្រែរបស់ប្រជាកសិករ
នៅខេត្តព្រះសីហនុ




សកម្មភាពពិនិត្យការងារផលិតកូនត្រីពូជ និងចិញ្ចឹមត្រីក្នុងស្រះ នៅខេត្តកំពង់ចាម




ការទស្សនាពិពរ័ណ៌ផលិតផលកសិកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម




ឯកឧត្តម **ច័ន្ទ តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញពិនិត្យការងារស្តារប្រព័ន្ធប្រឡាយជូនប្រជាកសិករបង្កបង្កើនផលស្រូវ នៅស្រុកអង្គរបូរី ខេត្តតាកែវ




ឯកឧត្តម **អ៊ឹក សុខុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញសាកសួរសុខទុក្ខកម្មករ និងពិនិត្យស្ថានភាពដំណាំកៅស៊ូ នៅខេត្តកំពង់ចាម




ឯកឧត្តម **តេង ឡៅ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងពិធីបិទវគ្គគ្រូបង្គោល នៅស្ថានីយ៍បាទី ខេត្តតាកែវ



ឯកឧត្ដម **អ៊ួង កុសល** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញសាកសួរសុខទុក្ខ បងប្អូនកងទ័ពឈរជើង នៅខេត្តកោះកុង



ឯកឧត្ដម **គិត សេង** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសសំណេះសំណាល ជាមួយប្រជាកសិករ នៅខេត្តតាកែវ



ឯកឧត្ដម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ប្រធានរដ្ឋបាលជលផល ក្នុងឱកាសកិច្ចប្រជុំបូកសរុបការងារជលផលឆ្នាំ២០១៣



ឯកឧត្ដម **លី ផល្លា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ អញ្ជើញពិនិត្យ ស្ថានភាពកូនកៅស៊ូ នៅខេត្តកំពង់ចាម



ឯកឧត្ដម **សូ ខនឫទ្ធីគុណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម អញ្ជើញពិនិត្យសត្វល្អិតបំផ្លាញឈើហូបផ្លែ នៅខេត្តពោធិសាត់



ឯកឧត្ដម **ឆេង គឹមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ប្រធានរដ្ឋបាលព្រៃឈើ អញ្ជើញផ្ដល់បាច់ផ្កាក្នុងឱកាស ទិវាសិទ្ធិនារី ៨ មីនា ឆ្នាំ ២០១៣



# បទដ្ឋានបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ

## ពាក្យភាព្យ

| | | | |
|---|---|---|---|
| ១. | ប្រើគ្រាប់ពូជសុទ្ធ | ជ្រើសរើសហ្មត់ចត់ | មានគុណភាពខ្ពស់ |
| ២. | សាបលើថ្នាលគោក | ដីមានមមោក | សំណាបថ្លោសល្អ |
| ៣. | ភ្ជួរឱ្យប្រសើរ | កៀរដីឱ្យស្មើ | រាស់ឲ្យបានម៉ដ្ឋ |
| ៤. | ប្រើសំណាបខ្ចី | ដកដោយថ្នមដៃ | មិនបាក់របួស |
| ៥. | ស្ទូងព្រោះជាជួរ | ចន្លោះសមគួរ | តាមប្រភេទដី |
| ៦. | គ្រប់គ្រងជីជាតិ | យកជីធម្មជាតិ | ជាមូលដ្ឋានគ្រឹះ |
| ៧. | ផ្តល់ទឹកគ្រប់គ្រាន់ | តម្រូវបន្ទាន់ | តាមដំណាក់កាល |
| ៨. | វិធានចម្រុះ | អនុវត្តឥតខ្ចោះ | ការពារដំណាំ |
| ៩. | ប្រមូលស្រូវដែលទុំ | សម្ងួតសមរម្យ | ទុកដាក់ត្រឹមត្រូវ ។ |

*និពន្ធដោយៈ លោក* ***ឌិន ធាយ***

*ប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម*

